ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីព និងយោបល់លើសិស្សនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តបន្ទាយមានជ័យ

# EFFECTIVENESS OF CAREER COUNCIL TEACHERS ON HIGH SCHOOL STUDENTS AT HIGH SCHOOL STUDENTS IN BANTEAY MEANCHEY PROVINCE

ដោយ/ By
ទៀប ឆវិន/ TEAP CHHORVIN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីព និងយោបល់លើសិស្សនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តបន្ទាយមានជ័យ

# EFFECTIVENESS OF CAREER COUNCIL TEACHERS ON HIGH SCHOOL STUDENTS AT HIGH SCHOOL STUDENTS IN BANTEAY MEANCHEY PROVINCE

**ដោយ**/ By

**ទៀប ឆវិន**/ TEAP CHHORVIN

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨-២០២០**

**សាស្ត្រាចារ្យដឹកនាំ ៖ បណ្ឌិត នី រដ្ឋា**

**សាស្ត្រាចារ្យដឹកនាំរង ៖ លោក លន លីណា**

# **សេចក្ដីអះអាងរបស់បេក្ខជន**

នាងខ្ញុំឈ្មោះ **ឡៀប ឆវិន** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីព និងយោបល់លើសិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តបន្ទាយមានជ័យ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះមិនទាន់ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬនៅសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារណាមួយត្រូវបានយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាស្រាវជ្រាវនិងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២០
**ហត្ថលេខា**

**ឡៀប ឆវិន**

# លិខិតបញ្ជាក់

**បណ្ឌិត នី រដ្ឋា** ជាសាស្ត្រាចារ្យដឹកនាំ

**លោក លន លីណា** ជាសាស្ត្រាចារ្យដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

កញ្ញា **ទៀប ឆវិន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីព និងយោបល់លើសិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តបន្ទាយមានជ័យ**»ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០

.................................. ..................................

**បណ្ឌិត នី រដ្ឋា** **លោក លន លីណា**

ប្រធានការិយាល័យសិក្សា មន្ត្រីដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៣០៤៧ **អយក.**ខប

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | ទី វង្សា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្ដិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **ឆៀប ឆវិន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃវិទ្យាស្ថានជាតិអប់រំ ជំនាន់ទី៧ ឯកទេសគ្រប់គ្រងអប់រំ។

*<u>សូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ៖</u>*

-លោកឪពុក**ឆៀប សុភហាក់** និងអ្នកម្ដាយ**យស សាវី** ដែលបានផ្ដល់កំណើតចិញ្ចឹមបីបាច់រូបនាងខ្ញុំ ព្រមទាំងផ្ដល់នូវជំបូន្មានល្អៗនិងបានបញ្ជូននាងខ្ញុំឱ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្ដមសិក្សាមិនគិតពីការនឿយហត់និងតស៊ូគ្រប់ឧបសគ្គ ដើម្បីកូនទទួលបាននូវអនាគតដ៏រុងរឿង។

-ថ្លែងអំណរគុណចំពោះឯកឧត្ដមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជននិងកីឡាដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំសម្រាប់បុគ្គលិកអប់រំនេះឡើងក្នុងន័យសម្រាប់យកទៅបម្រើការងារឱ្យវិស័យអប់រំប្រកបដោយប្រសិទ្ធភាពនិងគុណភាព។

-ថ្លែងអំណរគុណចំពោះឯកឧត្ដមបណ្ឌិត **សៀង សុវណ្ណា** ជានាយកវិទ្យាស្ថានជាតិអប់រំ ដែលជានិច្ចកាល ឯកឧត្ដមបណ្ឌិតលោកបានដឹកនាំវិទ្យាស្ថានជាតិអប់រំមួយនេះឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។

-ថ្លែងអំណរគុណចំពោះលោកបណ្ឌិត **នី រដ្ឋា** ជាសាស្ត្រាចារ្យដឹកនាំដែលជានិច្ចកាលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោកក្នុងការផ្ដល់គំនិតការណែនាំ និងផ្ដល់ទាំងកម្លាំងចិត្ត កម្លាំងកាយ បញ្ញា ស្មារតី សម្ភារ បច្ចេកទេស និងវិធីសាស្ត្រផ្សេងៗ។ មិនតែប៉ុណ្ណោះ លោកតែងបានជួយផ្ដល់ជាឯកសារផ្សេងៗទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបនាងខ្ញុំរហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ថ្លែងអំណរគុណចំពោះលោក **លន លីណា** ជាសាស្ត្រាចារ្យដឹកនាំរង និងមិត្តរួមជំនាន់ទី៧ និងមិត្តគ្រប់ជំនាន់ទាំងអស់ ដែលតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោកក្នុងការផ្ដល់គំនិត ការណែនាំល្អៗ និងយោបល់សមហេតុផលដែលជាកម្លាំងចិត្ត តាមរយៈការចែករំលែក ចំណេះដឹង បទពិសោធន៍

ព័ត៌មាន ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបនាងខ្ញុំ ហេតុការសិក្សាស្រាវជ្រាវនេះមានភាពងាយស្រួល។

-ថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបាន ផ្តល់ព័ត៌មានយ៉ាងលម្អិត និងគ្រប់ជ្រុងជ្រោយចំពោះការសម្ភាសន៍យកព័ត៌មានមកសរសេរក្នុងនិក្ខេបបទនេះរហូតបានបញ្ចប់ជាស្ថាពរ។

ជាទីបញ្ចប់នេះ នាងខ្ញុំសូមគោរពជូនពរនិងប្រសិទ្ធិពរ លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តមលោកជំទាវ លោក លោកស្រី ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យ មិត្តភក្តិទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមឱ្យជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ មានសុខភាពល្អ សម្រេចជោគជ័យ គ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប


មុខវិជ្ជាប្រឹក្សាអាជីព ត្រូវបានយកមកអនុវត្តនៅក្នុងបរិបទប្រទេសកម្ពុជានាអំឡុងឆ្នាំ២០១៨។ ការបញ្ចូលមុខវិជ្ជាប្រឹក្សាអាជីពនេះ ក្នុងគោលបំណងធ្វើឱ្យសិស្សជ្រើសរើសអាជីពដែលស័ក្តិសមនឹងទេពកោសល្យរបស់ខ្លួន ហើយរៀបចំគម្រោងអាជីពដោយពង្រឹងចំណុចខ្លាំង និងកែលម្អចំណុចខ្សោយរបស់ខ្លួនតាមរយៈការសិក្សាមេរៀនប្រឹក្សាអាជីព និងយោបល់ពីគ្រូបង្រៀនដោយមានជំនួយ និងធ្វើការសម្របសម្រួលពីលោកគ្រូ-អ្នកគ្រូ មិត្តរួមថ្នាក់និងនាយកសាលា។ម្យ៉ាងទៀត ការអនុវត្តការប្រឹក្សាអាជីពនេះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការសិក្សាមុខវិជ្ជាផ្សេងៗ ពិសេសបានត្រៀមខ្លួនរួចរាល់សម្រាប់ជ្រើសរើសមុខវិជ្ជាឬជំនាញនៅមហាវិទ្យាល័យ ពីព្រោះក្នុងមេរៀនសិស្សអាចដឹងពីចំណុចខ្លាំង ចំណុចខ្សោយរបស់ខ្លួន របៀបជ្រើសវិធីសាស្ត្រក្នុងការរៀនតាមទេពកោសល្យរបស់ខ្លួន និងអាចបង្កើតជាបណ្តាញជាគម្រោងសហគ្រិន ដាក់គោលដៅនិងវិធីសម្រេចបាននូវគោលដៅតាមរយៈខ្លឹមសារមេរៀន និងក្រោមការណែនាំនិងកែលម្អពីគ្រូដើម្បីឱ្យសិស្សមានសមត្ថភាពពេញលេញអាចដោះស្រាយបញ្ហាដែលកើតមានឡើង។ប្រធានបទស្តីពី «ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពនិងយោបល់លើសិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តបន្ទាយមានជ័យ» ត្រូវបានធ្វើឡើងដើម្បីពិនិត្យមើលពីស្ថានភាពបច្ចុប្បន្ននៃការរៀននិងការបង្រៀន និងរួមចំណែកជួយដោះស្រាយភាពអសកម្មមួយចំនួន ដែលកំពុងកើតមានឡើងតាមរយៈការបង្ហាញនូវមូលដ្ឋានទ្រឹស្តី និងការអនុវត្តឱ្យមានប្រសិទ្ធភាពប្រកបដោយគុណភាព និងធានាបានថាសិស្សានុសិស្សគ្រប់រូបទទួលបានចំណេះដឹង ជំនាញក្នុងការគិត និងហេតុផល មានបទពិសោធន៍ក្នុងការសិក្សាប្រកបដោយគុណភាព និងភាពឆ្លើយតប។ ការសិក្សានេះត្រូវបានអនុវត្តនៅវិទ្យាល័យចំនួន៤ នៅក្នុងខេត្តបន្ទាយមានជ័យ ដែលមានអ្នកចូលរួមជាគណៈគ្រប់គ្រងសាលាចំនួន១២រូប លោកគ្រូ អ្នកគ្រូចំនួន១២រូប សិស្សានុសិស្សចំនួន១២០នាក់ បំពេញកម្រងសំណួរ ។ ទិន្នន័យត្រូវបានវិភាគដោយប្រើកម្មវិធីSPSSនិងបង្ហាញជាតារាងស្ថិតិព័ណ៌នាដែលមានតម្លៃមធ្យម(Mean)និងគម្លាតស្តង់ដា(SD)ដើម្បីបកស្រាយពីការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីព និងយោបល់លើសិស្ស។

លទ្ធផលសំខាន់ៗនៃការស្រាវជ្រាវនេះបានបង្ហាញថា ប្រសិទ្ធភាពនៃការអនុវត្តការងារបង្រៀនរបស់គ្រូប្រឹក្សាអាជីព ក្នុងខេត្តបន្ទាយមានជ័យមានកម្រិតល្អបង្គួរ( Mean=3.67 )។ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស និងគណៈគ្រប់គ្រងបានពង្រឹងសមត្ថភាពខ្លួនដើម្បីពង្រឹងការបង្រៀន និងរៀនឱ្យបានតាមស្តង់ដា។ ក្នុងការទទួលការបែងចែកភារកិច្ចក្នុងការអនុវត្តការងារបង្រៀនរបស់គ្រូ នាយក សិស្សបាន តម្លៃ ( Mean=3.86 , 3.93 , 3.79 រៀងគ្នា) ដោយការពង្រឹងសមត្ថភាពគ្រូ នាយក សិស្សមានតម្លៃកម្រិត (Mean=3.65 .3.66 3.73)មានន័យថា ការពង្រឹងសមត្ថភាពខ្លួនមានកម្រិត (Mean=3.93 3.82 3.70) ប៉ុន្តែក្នុងបញ្ហាប្រឈមឃើញថា ( Mean =3.80 3.33 3.40) មានន័យថា លោកនាយកនិងសិស្សបានជួបប្រទះកម្រិតប្រឈមមធ្យម និងគ្រូបង្រៀនជួបប្រទះបញ្ហាប្រឈមកម្រិតខ្ពស់បង្គួរមកពីសមត្ថភាពខ្លួនមិនបានសមស្រប។ ចំពោះដំណោះស្រាយវិញលោកនាយក លោកគ្រូ អ្នកគ្រូ សិស្សបានរិះរកដំណោះស្រាយបានតម្លៃ (Mean= 3.59 3.72 3.74)មានន័យថា ទាំងគ្រូ នាយក សិស្សបានរកដំណោះស្រាយក្នុងការបង្រៀន និងរៀនបានកម្រិតល្អបង្គួរនៅក្នុងខេត្តបន្ទាយមានជ័យ។ យើងសង្កេតឃើញថា នាយក លោកគ្រូ អ្នកគ្រូនិងសិស្សបានពង្រឹងការអនុវត្តភារកិច្ចរបស់ខ្លួនបានតម្លៃ(Mean=3.79 3.57 3.58)មានន័យថាការពង្រឹងការងាររបស់នាយក គ្រូ សិស្សបានកម្រិតមធ្យមផ្នែកស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីពបានកម្រិត(Mean= 3.99 3.94 3.74)។ សរុបមក ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពរួមទាំងនាយក និងការចូលរួមរបស់សិស្សបានកម្រិតល្អបង្គួរ។

# Abstract

Career counseling was implemented in the Cambodian context during .2018The inclusion of this career counseling course aims to enable students to choose a career that suits their talents and plan their careers by strengthening their strengths and improving their weaknesses through study lessons, career counselling and advice from teachers with the help and coordination of teachers, classmates and principals. Also, the implementation of this career counseling is very important in studying various subjects, especially getting ready for a subject or major in college because in the lesson, students can know their strengths and weaknesses and how to choose a method to learn according to their talents and can form a network as a joint project, goal setting and ways to achieve goals through the content of the lesson and under the guidance and improvement of the teacher so that students are fully able to solve problems that arise. The topic of *"Effectiveness of Professional Counselors and Advice on High School Students in Banteay Meanchey Province"* was conducted to examine the current state of learning and teaching and to contribute to addressing some current inactivity by demonstrating the theoretical basis and practice effectively and qualitatively and ensuring that all students acquire knowledge, skills in thinking and reasoning, have experience in quality and responsive learning. The study was conducted at four high schools in Banteay Meanchey province, with 12 school administrators, 12 teachers, and 120 students completing the questionnaire. The data were analyzed using SPSS software and presented as a statistical table of mean, values, and standard deviations to interpret the performance appraisal of professional counselors and student feedback.

The main results of this research show that the effectiveness of teaching practice of professional counselors in Banteay Meanchey is relatively good (Mean = 3.67). Teachers, students and school council have strengthened their capacity to teaching and learning standard. In accepting the division of responsibilities in the performance of the teaching work of the teacher, school director, and the student is valuable (Mean = 3.86, 3.93, 3.79 respectively) by strengthening the capacity of teachers, students have a limited value (Mean = 3.65 .3.66 3.73) means that their capacity building is limited (Mean = 3.93 3.82 3.70), however, in the case of (Mean = 3.80, 3.33, 3.40), it means that the principal and students have encountered moderate levels and teachers have encountered relatively high levels due to their incompetence. As for the solution, the principal, teachers and students have found a solution worthwhile (Mean = 3.59 3.72 3.74), which means that both teachers and students have found a solution to teach and learn at a good level in Banteay Meanchey province, we observed that the directors, teachers and students have strengthened the performance of their duties (Mean = 3.79 3.57 3.58), meaning that the strengthening of the work of teachers and students is moderate. Insights into the content of career counseling are limited (Mean = 3.99, 3.94, 3.74).The result of the faec of processing for career's teaching is equal as the result of complementing to be counselors so we can assume that the effective of the counselor's work to help students do not have enough capacity being a standard career counselor .This result also indicate that teachers of counseling is not well qualified and possess the required students' needs yet because this program have just had in high school in Cambodia so If we want to get good result we have to find more solution and get more proper training strategies .It is essential to develop career management skills hence the involver. Overall, the effectiveness of the work of professional counselors, is not reach the standard yet.

# មាតិកា

ទំព័រ

សេចក្តីអះអាងរបស់បេក្ខជន

លិខិតបញ្ជាក់របស់សាស្ត្រាចារ្យដឹកនាំនិងដឹកនាំរង

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

សេចក្តីថ្លែងអំណរគុណ

មូលន័យសង្ខេប ........ i

មាតិកា. ........ iv

ចំណងជើងតារាងផ្នែកទីI. ........ vii

ចំណងជើងតារាងផ្នែកទីII ........ viii

បញ្ជីពាក្យកាត់. ........ ix

**ជំពូកទី១៖ សេចក្តីផ្តើម**

១.១-សាវតារ ........ ១

១.២-ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១.៣-គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ៣

១.៤-សំណួរស្រាវជ្រាវ ........ ៤

១.៥-សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

១.៦-វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ ........ ៥

១.៦.១-វិសាលភាពនៃការស្រាវជ្រាវ ........ ៥

១.៦.២-ដែនកំណត់នៃការស្រាវជ្រាវ ........ ៥

១.៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥

## ជំពូកទី២៖ ការរំលឹកទ្រឹស្តី


២.១-ប្រវត្តិនៃការប្រឹក្សាយោបល់ ........................................................ ៦

២.២-និយមន័យ ........................................................ ៦

២.២.១-ប្រឹក្សា ........................................................ ៦

២.២.២-អាជីព ........................................................ ៦

២.២.៣-ប្រសិទ្ធភាព ........................................................ ៨

២.២.៤-បញ្ហាប្រឈម ........................................................ ៨

២.២.៥-ការអនុវត្តការងារ ........................................................ ៨

២.៣-ប្រភេទនៃការប្រឹក្សាយោបល់ ........................................................ ៩

២.៤-ប្រឹក្សាអាជីពនិងយោបល់ ........................................................ ៩

២.៥-លក្ខណៈសម្បត្តិនៃអ្នកប្រឹក្សាអាជីព ........................................................ ១១

២.៦-សារៈសំខាន់នៃការប្រឹក្សាអាជីពនិងយោបល់ ........................................................ ១៥

២.៦.១-ការទទួលខុសត្រូវរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ........................................................ ១៥

២.៦.២-ការទទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សា ........................................................ ១៦

២.៧-របៀបធ្វើការប្រឹក្សាលើសិស្ស ........................................................ ១៧

២.៨-បញ្ហាប្រឈមនៃការប្រឹក្សាអាជីព ........................................................ ១៧


## ជំពូកទី៣៖ វិធីសាស្រ្តស្រាវជ្រាវ


៣.១-វិសាលភាពនិងដែនកំណត់ ........................................................ ១៨

៣.២-ការជ្រើសរើសភាគសំណាក ........................................................ ១៨

៣.៣-ឧបករណ៍ស្រាវជ្រាវ ........................................................ ១៩

៣.៤- ដំណើរការប្រមូលទិន្នន័យ ........................................................ ១៩

៣.៥-ការវិភាគទិន្នន័យ ........................................................ ២១

៣.៦-ក្រមសីលធម៌នៃការស្រាវជ្រាវ..........................................................................................................២១

**ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវនិងការពិភាក្សា**

៤.១-របៀបនៃការបង្ហាញព័ត៌មាន ..........................................................................................................២២

៤.២-លទ្ធផលនៃការស្រាវជ្រាវ..........................................................................................................២៣

ផ្នែកទីI

-តារាងទីI៖ ព័ត៌មានទូទៅរបស់នាយក (សាលា ភេទ អាយុ កម្រិតវប្បធម៌ ជំនាញឯកទេស បទពិសោធន៍បង្រៀន ភាសា)..........................................................................................................២៣

-តារាងទីII៖ព័ត៌មានទូទៅរបស់សិស្ស (ទីកន្លែង ភេទ អាយុ បណ្តុំមុខវិជ្ជាសិស្ស) ........២៥

-តារាងទីIII៖ ព័ត៌មានទូទៅរបស់គ្រូប្រឹក្សា(តួនាទី ភេទ ឈ្មោះសាលា/តំបន់ អាយុ កម្រិតវប្បធម៌គ្រូ ជំនាញឯកទេសគ្រូ ភាសា បទពិសោធន៍ការងារ)..................................២៧

ផ្នែកទីII

-តារាងមធ្យម គម្លាតស្តង់ដានិងអត្ថន័យផ្សេងៗ(គ្រូ សិស្សនិងនាយក) ......................៣០

៤.៣-ការពិភាក្សាការស្រាវជ្រាវ..........................................................................................................៥១

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

៥.១-សេចក្តីសន្និដ្ឋាន ..........................................................................................................៥២

៤.២-សំណូមពរ ..........................................................................................................៥២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ចំណងជើងតារាងផ្នែកទី I


តារាង ទំព័រ

តារាងទី១៖ឈ្មោះសាលាគិតជាភាគរយ………………………………………………………. ២៣

តារាងទី២៖ភេទគិតជាភាគរយ………………………………………………………… ២៣

តារាងទី៣៖អាយុគិតជាភាគរយ………………………………………………………… ២៤

តារាងទី៤៖កម្រិតវប្បធម៌របស់នាយក………………………………………………… ២៤

តារាងទី៥៖ជំនាញឯកទេសដើមរបស់នាយក…………………………………………… ២៤

តារាងទី៦៖បទពិសោធន៍បង្រៀនរបស់គ្រូ……………………………………………… ២៥

តារាងទី៧៖ភាសា………………………………………………………………………… ២៥

តារាងទី៨៖ទីកន្លែង……………………………………………………………………… ២៥

តារាងទី៩៖ភេទរបស់សិស្សគិតជាភាគរយ…………………………………………… ២៦

តារាងទី១០៖ អាយុសិស្សគិតជាភាគរយ……………………………………………… ២៦

តារាងទី១១៖បណ្តុំមុខវិជ្ជា…………………………………………………………… ២៦

តារាងទី១២៖ភាសា……………………………………………………………………… ២៧

តារាងទី១៣៖តួនាទីរបស់គ្រូ…………………………………………………………… ២៧

តារាងទី១៤៖ភេទរបស់គ្រូគិតជាភាគរយ……………………………………………… ២៧

តារាងទី១៥៖ឈ្មោះសាលា/តំបន់……………………………………………………… ២៧

តារាងទី១៦៖អាយុគិតជាភាគរយ………………………………………………………… ២៨

តារាងទី១៧៖កម្រិតវប្បធម៌របស់គ្រូ…………………………………………………… ២៨

តារាងទី១៨៖ជំនាញឯកទេសដើមរបស់គ្រូ……………………………………………… ២៩

តារាងទី១៩៖ភាសា……………………………………………………………………… ២៩

តារាងទី២០៖បទពិសោធន៍បង្រៀនរបស់គ្រូ…………………………………………… ២៩

# ចំណងជើងតារាងផ្នែកទីII

ទំព័រ

តារាងទី១៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃប្រសិទ្ធភាពសម្រាប់ការអនុវត្តការងារប្រឹក្សាអាជីព លើសិស្សរបស់គ្រូនៅមធ្យមសិក្សាទុតិយភូមិ(N=12)ព័ត៌មានពីគ្រូប្រឹក្សាអាជីព....................................៣០

តារាងទី២៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃការកសាងសមត្ថភាព ........................................៣១

តារាងទី៣៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃការកសាងសមត្ថភាពគ្រូ....................................៣២

តារាងទី៤៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃបញ្ហាប្រឈមរបស់គ្រូ.........................................៣២

តារាងទី៥៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យដំណោះស្រាយ ...................................................៣៣

តារាងទី៦៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យការពង្រឹងលើការអនុវត្តការងារ ................................៣៤

តារាងទី៧៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យផ្នែកស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីព ..........................៣៥

តារាងទី៨៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យតារាងសរុប ........................................................៣៦

តារាងទី៩៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃនាយកលើការអនុវត្តការងារគ្រូប្រឹក្សាអាជីព ............៣៧

តារាងទី១០៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃការកសាងសមត្ថភាពគ្រូ ..................................៣៨

តារាងទី១១៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃការកសាងសមត្ថភាពសិស្ស..............................៣៩

តារាងទី១២៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃបញ្ហាប្រឈមរបស់នាយក...............................៣៩

តារាងទី១៣៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃដំណោះស្រាយរបស់នាយក.............................៤០

តារាងទី១៤៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យការពង្រឹងការអនុវត្តការងាររបស់នាយក..................៤១

តារាងទី១៥៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យផ្នែកស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីពរបស់នាយក .......៤២

តារាងទី១៦៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យតារាងសរុប.......................................................៤៣

តារាងទី១៧៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យនៃប្រសិទ្ធភាពសម្រាប់ការអនុវត្តការងាររបស់គ្រូប្រឹក្សា អាជីពសួរទៅលើសិស្ស.......................................................................................................៤៤

តារាងទី១៨៖មធ្យម គម្លាតស្តង់ដានិងអត្ថន័យការប្រឹក្សាជួយឱ្យប្រែប្រួលបុគ្គលិកលក្ខណៈ .............៤៥

# បញ្ជីពាក្យកាត់

| | |
|---|---|
| -អយក | អប់រំ យុវជន និងកីឡា |
| -សណន | សេចក្តីណែនាំ |
| -វជអ | វិទ្យាស្ថានជាតិអប់រំ |
| -ផក | ផែនការ |
| -អនក្រ.បក | អនុក្រឹត្យស្តីពីបទប្បញ្ញត្តិទូទៅ |
| -STEM | Science,Technology,Engineering,Mathematic |

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១-សារចនា

ការអប់រំគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៃការកសាងធនធានមនុស្សប្រកបទៅដោយគុណភាព ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅដ៏ត្រចះត្រចង់និងគុណភាពនៃការអប់រំគឺត្រូវការធនធានមនុស្ស (ហង់ជួន ណារ៉ុន ២០១៨) ហើយស្របតាមនិន្នាការនៃការអប់រំសម័យទំនើប និងបរិបទសាកលលោកនេះ ក្រសួងបានធ្វើកំណែទម្រង់អប់រំដើម្បីឱ្យស្របតាមគោលនយោបាយរបស់ក្រសួងអប់រំឆ្នាំ២០១៥។ ដើម្បីសម្រេចតាមគោលនយោបាយនេះក្រសួងបានធ្វើកំណែទម្រង់១៥ចំណុចក្នុងនោះរួមមាន៖ (១)កំណែទម្រង់ហិរញ្ញវត្ថុ (២) ការពង្រាយគ្រូ(៣) ការបណ្តុះបណ្តាល(៤) លើកកម្ពស់គុណវុឌ្ឍិគ្រូ(៥) ការងារអធិការកិច្ច (៦) ការវង្វាយតម្លៃលទ្ធផលសិក្សាសិស្ស(៧) កំណែទម្រង់លើការប្រឡងមធ្យមសិក្សាទុតិយភូមិ(៨) កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (៩)ការសាងសង់អគារសិក្សានិងការជួសជុល(១០) ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា(១១) ការលើកកម្ពស់វិស័យកីឡា(១២) ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន(១៣) ការអប់រំបច្ចេកទេស(១៤) ការបង្កើតសាលាជំនាន់ថ្មី និង(១៥)ការរៀបចំគន្លងអាជីពនិងការបណ្តុះបណ្តាលនាយកសាលា (ហង់ជួន ណារ៉ុន ២០១៥)។ដោយផ្តោតលើលទ្ធផលសិក្សារបស់សិស្សនៅមានកម្រិតទើបបច្ចុប្បនេះសិស្សនៅមធ្យមសិក្សាបឋមភូមិបន្ទាប់ពីគេប្រឡងជាប់ថ្នាក់ទី៩ គេត្រូវទៅសិក្សានៅមធ្យមសិក្សាទុតិយភូមិ។ ពេលនោះគេមានអារម្មណ៍ថាមានសម្ពាធដោយសារពួកគេជួបប្រទះបញ្ហាពិបាកដោះស្រាយនិងមានអារម្មណ៍អវិជ្ជមាន ហើយពួកគេមិនដឹងពីការគ្រប់គ្រងពេលវេលារៀនសូត្ររបស់ពួកគេ ការកំណត់ និងការសម្រេចគោលដៅ ដោយខ្វះការជំរុញទឹកចិត្តពីខាងក្នុងនិងខាងក្រៅធ្វើឱ្យគេប្រើឥរិយាបថខុសឆ្គង។ មួយវិញទៀតគេពិបាកក្នុងការជ្រើសរើសមុខវិជ្ជាសិក្សាមិនដឹងត្រូវរើសផ្នែកវិទ្យាសាស្ត្រឬសង្គមនេះជាមូលហេតុដែលជះផលមិនល្អដល់ពេលគេប្រឡងចប់ហើយត្រូវទៅរៀននៅមហាវិទ្យាល័យ ត្រង់នេះហើយធ្វើឱ្យនិស្សិតខ្លះរៀនដល់ឆ្នាំទី២ឬឆ្នាំទី៣ ហើយត្រូវដូរជំនាញមករៀនជំនាញផ្សេងវិញធ្វើឱ្យខ្ជះខ្ជាយពេលវេលានិងប្រាក់កាក់។ ដោយឃើញបញ្ហាខាងលើនេះហើយទើបក្រសួងអប់រំ យុវជននិង កីឡាបានចងក្រងជាមុខវិជ្ជាប្រឹក្សាអាជីពនិងយោបល់លើសិស្សនេះក្នុងកម្មវិធីសិក្សាទុតិយភូមិ ក្នុងគោលបំណងដើម្បីគាំទ្រជួយសិស្សនៅមធ្យមសិក្សាទុតិយភូមិឱ្យមានការស្រឡាញ់ការសិក្សាចំណេះដឹងស្វែងយល់ពីចំណុចខ្សោយ ចំណុចខ្លាំងហើយចេះពង្រីកភាពខ្លាំងរបស់ខ្លួនហើយចេះរៀបចំផែនការជីវិតអាជីព ឬផែនការសកម្មភាពក្នុងការធ្វើការងារជា

ក្រុមដែលមានជំនាញក្នុងជីវិតការងារប្រកបដោយការសម្រេចចិត្តខ្ពស់ ក្នុងភាពជាអ្នកដឹកនាំ និងសហគ្រិនភាព។ លើសពីនេះទៀតគេចេះវាយតម្លៃខ្លួនឯង។ ដោយឃើញស្ថានភាពបែបនេះហើយ ទើបក្រសួងបានរៀបចំឱ្យមានក្រុមគ្រូប្រឹក្សាអាជីពនេះឡើងដើម្បីជួយសិស្ស។ ការប្រឹក្សាអាជីពត្រូវការក្រុមប្រឹក្សាអាជីពដែលមានជំនាញនិងបទបទពិសោធន៍ល្អក្នុងការប្រឹក្សានេះ។ មានវិធីមួយចំនួនដែលគេប្រើលើការប្រឹក្សាយោបល់ប្រកបដោយវិធីសាស្ត្រផ្សេងៗខ្លះ គេប្រើវិធីសាស្ត្រផ្ដាច់ការដែលប្រឹក្សាដើរតួនាទីជាអ្នកជំនាញចំពោះអ្វីដែលគេត្រូវបង្ហាញដោយដាក់កិច្ចការឱ្យសិស្សធ្វើដោយដោះស្រាយវិធីសាស្ត្រនេះ មានភាពច្បាស់លាស់ហើយបានលឿន។ វិធីសាស្ត្របែបជំរុញលើកទឹកចិត្ត(Catalyst style) គឺជាការប្រឹក្សាដែលផ្ដោតទៅលើការគិត និងការរកដំណោះស្រាយដោយខ្លួនឯងតែការសម្រេចចិត្តស្ថិតនៅក្នុងស្ថានភាពតូចចង្អៀត។ រីឯវិធីសាស្ត្របែបប្រឈមមុខដាក់គ្នា(ControntingStyle) គឺអ្នកប្រឹក្សាចង្អុលបង្ហាញពីភាពផ្ទុយគ្នាផ្សេងៗ ក្នុងការគិតរឿងរ៉ាវផ្សេងៗ។ ចំណែកឯវិធីសាស្ត្របែបស្រុះស្រួលគ្នាវិញ(Approving Style)មានលក្ខណៈទន់ភ្លន់។ អ្នកទទួលការប្រឹក្សាយោបល់ចូលចិត្តចូលរួមដោយអ្នកប្រឹក្សាបង្ហាញពីភាពគាំទ្រ និងយល់ចិត្តពីការវិវត្តមានភាពយឺតយ៉ាវទៅមុខយឺតៗ។ ចុងក្រោយការប្រើវិធីសាស្ត្រផ្សេងៗ (UseofStyle)។ ការប្រឹក្សាអាជីពផ្ដោតទៅលើដំណោះស្រាយ គឺស្វែងរកដំណោះស្រាយវិជ្ជមាន ចំពោះបញ្ហាការប្រឈមផ្សេងៗ (គ្រឹះស្ថានសិក្សាជំនាញ ២០១៦)។

## ១.២-ចំណោទបញ្ហានៃការស្រាវជ្រាវ

សិស្សខ្លះខ្វះខ្នាយពេលវេលាមិនចេះគ្រប់គ្រងពេលវេលា ហើយពួកគេខ្វះការសម្រេចចិត្តដែលជាមូលហេតុធ្វើអោយពួកគេជ្រើសរើសមុខវិជ្ជាខុសជំនាញខ្លួន។ ពួកគេគ្មានភាពទទួលខុសត្រូវជាពិសេសគេមិនដឹងពីគោលបំណងនៃការសិក្សាហើយនិងផែនការបន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យ។ដោយសារឃើញបញ្ហាបែបនេះហើយទើបក្រសួងរៀបចំបង្កើតមុខវិជ្ជាប្រឹក្សាអាជីពនេះឡើង ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្រដ៏ទូលំទូលាយនិងសក្ដានុពលធនធានមនុស្សឱ្យមានជំនាញគ្រប់កម្រិត ដែលអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការទីផ្សារពលកម្មបានពេញលេញ មានគំនិតច្នៃប្រឌិតខ្ពស់ មានស្មារតីទទួលខុសត្រូវសំដៅលើកកម្ពស់ការអភិវឌ្ឍប្រទេសជាតិគ្រប់វិស័យទើបមុខវិជ្ជាប្រឹក្សាអាជីព និងផ្ដល់យោបល់លើសិស្សត្រូវបានបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ដើម្បីជួយសិស្សក្នុងការរៀបចំផែនការអាជីពផែនការសិក្សាចេះដោះស្រាយបញ្ហាផ្ទាល់ខ្លួន និងចូលរួមកាត់បន្ថយការបោះបង់ការសិក្សាផងដែរ (Moeys, 2018)។ ការជំរុញសិស្សឱ្យស្វែងយល់ពីចំណុចខ្លាំង ចំណុចខ្សោយជំនាញបុគ្គលិក

លក្ខណៈល្អៗនិងរកឱ្យឃើញពីរបៀបនៃការអភិវឌ្ឍចំណុចខ្សោយ តាមរយៈការសិក្សានិងអនុវត្តឱ្យសិស្សស្គាល់ពីទិដ្ឋភាពពាក់ព័ន្ធដែលមានមុននឹងការខកចិត្តការរងសម្ពាធ និងការដោះស្រាយជម្លោះ។ ការស្គាល់ខ្លួនឯងជារឿងសំខាន់ដែលអាចឱ្យគេសង្កេតមើលនូវឱកាសទាំងឡាយ ដែលបរិស្ថានរស់នៅរបស់គេអាចផ្តល់ឱ្យគេបានហើយបានបង្កើនចំណេះពីខ្លួនឯងនិងបណ្តាញជាប្រចាំរបស់ពួកគេគឺជាជំហានសំខាន់បំផុត។ ទាក់ទងនឹងលំនាំនេះដែរនៅក្នុងសេចក្តីណែនាំស្តីពីការអនុវត្តសេវាប្រឹក្សាអាជីពនៅតាមគ្រឹះស្ថានមធ្យមសិក្សាលេខ៤០ អយក សណន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងអំពីការងារបណ្តាញក្នុងភារកិច្ចរបស់គ្រូប្រឹក្សាអាជីព។ គ្រូប្រឹក្សាអាជីពត្រូវសិក្សាស្រាវជ្រាវគោលដៅបណ្តាញ និងចុះធ្វើការទំនាក់ទំនងជាមួយគោលដៅបណ្តាញ ដើម្បីជាប្រយោជន៍ដល់សេវាប្រឹក្សាអាជីពនៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនដូចជា ចុះប្រមូលព័ត៌មាននិងទំនាក់ទំនងជាមួយមជ្ឈមណ្ឌលយុវជន គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ នៅក្នុងសហគមន៍របស់ខ្លួនជាដើម។ ត្រូវគៀងគរអ្នកស្ម័គ្រចិត្ត និងរៀបចំឱ្យមានកម្មវិធីអញ្ជើញវាគ្មិន មកធ្វើបទបង្ហាញក្នុងគ្រឹះស្ថានរបស់ខ្លួនយ៉ាងតិចមួយដងក្នុងមួយឆ្នាំសិក្សា។ ត្រូវកសាងបណ្តាញជាមួយគ្រូប្រឹក្សាអាជីពក្នុងគ្រឹះស្ថានដទៃទៀតដើម្បីជានាប្រសិទ្ធភាពក្នុងការអនុវត្តសេវាប្រឹក្សាអាជីពប្រកបដោយនិរន្តភាព (ក្រសួងអប់រំ ២០១៧)។ ការប្រឹក្សាអាជីពមិនត្រឹមតែជួយសិស្សឱ្យប្រឹងប្រែងរៀនសូត្រទេ វាថែមទាំងជួយដោះស្រាយរាល់បញ្ហាប្រឈមរបស់សិស្ស នៅក្នុងការរៀនសូត្ររួមគឺជួយសិស្សឱ្យអភិវឌ្ឍការរៀនសូត្រនិងចំណេះដឹងគ្រប់មុខវិជ្ជា។ ដោយឃើញពីសារៈប្រយោជន៍នៃការប្រឹក្សាអាជីពនេះទើបក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចូលមុខវិជ្ជាប្រឹក្សាអាជីពក្នុងកម្មវិធីសិក្សារដ្ឋក្នុងសាលាគម្រោងស៊ីបដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

## ១.៣-គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវស្តីពីប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពយោបល់លើសិស្ស នៅមធ្យមសិក្សាទុតិយភូមិមានគោលបំណងដូចខាងក្រោមៈ

(១) រកឱ្យឃើញពីកម្រិតអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពក្នុងការជួយសិស្សនៅមធ្យមសិក្សាទុតិយភូមិការសិក្សាធៀបនឹងស្តង់ដាប្រឹក្សាអាជីព។

(២) រកឱ្យឃើញពីបញ្ហាប្រឈមនានារបស់គ្រូប្រឹក្សាអាជីពក្នុងការអនុវត្តការងារជួយសិស្សនៅមធ្យមសិក្សាទុតិយភូមិធៀបនឹងស្តង់ដាការប្រឹក្សាអាជីព។

## ១.៤-សំណួរស្រាវជ្រាវ

ការសិក្សាបច្ចុប្បន្ននេះទាមទារឱ្យមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ និងមានវិធីសាស្ត្រជាច្រើនដើម្បីទទួលបានជោគជ័យ។ ការប្រឹក្សាអាជីពជាថាមពលសង្គមនិងផ្លូវចិត្តដែលប្រើវិធីសាស្ត្របែបស្ថាបនាក្នុងការណែនាំដើម្បីគាំទ្រនិងលើកទឹកចិត្តដល់អ្នកដែលទទួលបានការប្រឹក្សាយោបល់ក្នុងការយល់ និងដោះស្រាយបញ្ហាផ្សេងៗនៅក្នុងជីវិតផ្ទាល់ខ្លួន។ ប្រធានបទនេះមានទាក់ទងជាមួយសំណួរស្រាវជ្រាវចំនួនពីរដែលបានពិភាក្សាលម្អិតនៅកថាខណ្ឌដូចខាងក្រោម។

សំណួរស្រាវជ្រាវនៃការសិក្សានេះមានដូចជា៖

(១) តើការអនុវត្តការងាររបស់គ្រូតាមស្តង់ដាប្រឹក្សាអាជីពក្នុងការជួយសិស្សនៅមធ្យមសិក្សាទុតិយភូមិមានប្រសិទ្ធភាពកម្រិតណា?

(២) តើការអនុវត្តការងាររបស់គ្រូតាមស្តង់ដាប្រឹក្សាអាជីពក្នុងការជួយសិស្សនៅមធ្យមសិក្សាទុតិយភូមិជួបបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥-សារៈសំខាន់នៃការស្រាវជ្រាវ

មុខវិជ្ជាប្រឹក្សាអាជីព និងផ្តល់យោបល់ គឺជាមុខវិជ្ជាសំខាន់មួយក្នុងការចំណោមមុខវិជ្ជាដទៃៗទៀតដែលក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ និងបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សាដើម្បីជួយគាំទ្រការសិក្សារបស់សិស្ស។

ការសិក្សានេះនឹងធ្វើឱ្យយើងដឹងនូវ៖

-ខ្លឹមសារមួយចំនួនដែលក្រុមគ្រូប្រឹក្សាត្រូវបង្រៀនសិស្ស។

-ការរកឱ្យឃើញពីប្រសិទ្ធភាពឬវិធីសាស្ត្រនៃការអនុវត្តការងាររបស់ក្រុមគ្រូប្រឹក្សាអាជីព។

-រកឱ្យឃើញពីបញ្ហាប្រឈមនិងការប្រឹងប្រែងដោះស្រាយបញ្ហាក្នុងការងាររបស់គ្រូប្រឹក្សាអាជីព។

ការដឹងពីខ្លឹមសារមេរៀននិងវិធីសាស្ត្រ និងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ក្រុមគ្រូប្រឹក្សាយោបល់នឹងជួយដោះស្រាយបញ្ហាប្រឈមនានា ដែលគ្រូកំពុងជួបប្រទះនៅក្នុងការជួយសិស្សឱ្យចេះរិះរកវិធីជំនាញក្នុងការសិក្សាការរៀបចំផែនការអាជីពហើយនិងជំនាញក្នុងជីវិតការងារ ដើម្បីឱ្យការសិក្សាមានការប្រសើរឡើងនៅពេលគេទៅបន្តការសិក្សានៅឧត្តមសិក្សា។

## ១.៦-វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ

### ១.៦.១-វិសាលភាពនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាអំពី "ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពនិងយោបល់ទៅលើសិស្សនៅមធ្យមសិក្សាទុតិយភូមិនៅខេត្តបន្ទាយមានជ័យ"ដោយយកតែវិទ្យាល័យចំនួន៤ក្នុងស្រុកចំនួន៤ដែលយកបង្ហាញពីមេរៀនដែលត្រូវបង្រៀនទៅលើសិស្ស និងវិធីសាស្ត្រប្រើក្នុងការបង្រៀន រួមទាំងរបៀបបំពេញការងាររបស់គ្រូប្រឹក្សាអាជីព។

### ១.៦.២-ដែនកំណត់នៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើទៅលើវិទ្យាល័យចំនួន៤ក្នុងខេត្តបន្ទាយមានជ័យដែលជ្រើសរើសយកសិស្សថ្នាក់ទី១០ចំនួន២ថ្នាក់ ថ្នាក់ទី១១ចំនួន២ថ្នាក់ ថ្នាក់ទី១២ចំនួន៥ថ្នាក់ គ្រូចំនួន១២នាក់ នាយកនិងនាយករងចំនួន១២នាក់។

## ១.៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ជំពូកធំៗ៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ។

**ជំពូកទី២៖** ការរំលឹកទ្រឹស្តីនៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវមុនៗដែលពាក់ព័ន្ធនិងប្រធានបទនេះ ដើម្បីជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវនិងបង្កើតស្នាដៃថ្មី។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវ និងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូ និងប្រភេទគំរូ ព្រមទាំងវិធីសាស្ត្រនៅក្នុងការស្រាវជ្រាវសម្រាប់ការវិភាគទិន្នន័យជាដើម។

**ជំពូកទី៤៖** លទ្ធផល និងការពិភាក្សា នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគនិងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អនិងចំណុចត្រូវកែលម្អក្នុងការបង្រៀនជាក់ស្តែងរបស់សាលានីមួយៗ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ ជាផ្នែកមួយផ្សេងទៀតដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគព្រមទាំងផ្តល់ជាសំណូមពរមួយចំនួននៅក្នុងបំណងចូលរួមចំណែកលើកកម្ពស់ការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្សឱ្យកាន់តែល្អជាងមុន។

# ជំពូកទី២

# ការរំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ អ្នកសិក្សាផ្តោតការស្រាវជ្រាវទៅលើនិយមន័យពាក្យគន្លឹះដែលជាប់ទាក់ទងនិងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាអាជីព និងយោបល់លើសិស្សនៅមធ្យមសិក្សាទុតិយភូមិ ប្រវត្តិនៃការប្រឹក្សាអាជីព ប្រភេទនៃការប្រឹក្សា សារៈប្រយោជន៍នៃការប្រឹក្សាអាជីព របៀបនៃការធ្វើការប្រឹក្សា និងបញ្ហាប្រឈមរបស់គ្រូប្រឹក្សាអាជីព។ ប្រធានបទនេះមានពាក្យគន្លឹះមួយចំនួនក្នុងការយកមកបកស្រាយពន្យល់ពាក្យទាំងនោះរួមមាន ប្រឹក្សា អាជីព ប្រសិទ្ធភាព បញ្ហាប្រឈម និងការអនុវត្តការងារ ។

## ២.១-ប្រវត្តិនៃការប្រឹក្សាយោបល់

ការប្រឹក្សាអាជីពត្រូវបានចាប់ផ្តើមកើតមានឡើងនៅសហរដ្ឋអាមេរិច នៅចុងសតវត្សរ៍ទី១៩ ដោយសារសង្គមមានចលាចលនិងការផ្លាស់ប្តូរអាជីពនេះ ត្រូវបានគេបង្កើតឡើងហើយអាជីពនេះបានព័ណ៌នាដោយអ្នកប្រវត្តិវិទូថាបានជួយអភិវឌ្ឍសង្គម និងកែប្រែទម្រង់សង្គម ផ្លាស់ប្តូរពីភាពក្រីក្រទៅរកលក្ខណៈស្តង់ដារស់នៅតាំងពីទីជនបទរហូតដល់ទីក្រុងដែលបង្កើតឧស្សាហកម្ម។ ដោយសារសង្គមនៅសហរដ្ឋអាមេរិចមានបញ្ហាសេដ្ឋកិច្ចច្រើនទាំងផ្នែកកសិកម្មឧស្សាហកម្មដែលទាមទារឱ្យមានកម្មករធ្វើការក្នុងឧស្សាហកម្មធុនធ្ងន់។ចំណែកនៅប្រទេសឥណ្ឌាការប្រឹក្សាលើការអប់រំក្រោយឧត្តមសិក្សា ដើម្បីឱ្យការអប់រំប្រៃពៃឡើង Rao (1991)។ ចំណែកកម្ពុជាវិញការប្រឹក្សាអាជីពនៅខេត្តកំពង់ចាមដែលមានសេវាកម្មផ្តល់ឱ្យសិស្សនៅឆ្នាំ២០១២។

## ២.២-និយមន័យ

### ២.២.១-ប្រឹក្សា

ប្រឹក្សាមានន័យថាការពិចារណា ដំណើរស្ទង់ការ ការល្បងមើលឱ្យឃើញការពិត ការពិគ្រោះគ្នា( ជួន ណាត ១៩៣៨)។

ប្រឹក្សាគឺជាសកម្មភាពស្តាប់រឿងរបស់បុគ្គលពីទិសដៅការសម្រេចចិត្តហើយស្វែងយល់ពីទំនាក់ទំនងទាំងការផ្តល់ការគោរព (ក្រសួងអប់រំ ១៩៩៨)។

### ២.២.២-អាជីព

តាមវចនានុក្រមសម្តេចសង្ឃរាជជួន ណាត មានន័យថា ការចិញ្ចឹមជីវិត ដំណើរធ្វើការ របរចិញ្ចឹមជីវិត។

អាជីពគឺជាដំណើរការនៃការធ្វើការក្នុងជីវិត ទាំងការងារមានប្រាក់ខែ និងការងារមិនមានប្រាក់ខែក្នុងជីវិតបុគ្គល។ មនុស្សបង្កើតអាជីព ខណៈពេលដែលការសម្រេចចិត្តអំពីការអប់រំ ការងារ គ្រួសារ និងតួនាទីក្នុងជីវិតដទៃទៀត (នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ២០១៨)។

អាជីពគឺជាអន្តរកម្មនៃការធ្វើការងារដោយតួនាទីនៃជីវិតបុគ្គលក្នុងសង្គម (Radhika Kapur)។ ការប្រឹក្សាអាជីពនិងកម្មវិធីប្រឹក្សាយោបល់គឺជាការយោគយល់ក្នុងការអភិវឌ្ឍកម្មវិធី ដែលរៀបចំឡើងដើម្បីជួយសិស្សបុគ្គលក្នុងការបង្កើតនិងបំពេញនិងធ្វើឱ្យយល់ពីការអប់រំនិងជម្រើសអាជីព។ការប្រឹក្សាអាជីពនិងយោបល់អភិវឌ្ឍន៍សមត្ថភាពបុគ្គលក្នុងចំណេះដឹងផ្ទាល់ខ្លួនខាងការអប់រំទូទៅ និងចំណេះដឹង ស្វែងរកអាជីពនិងគម្រោងអាជីពបានជាត្រូវមានប្រឹក្សាអាជីព និងយោបល់ ដើម្បីជួយចែកចាយក្នុងការអប់រំវិជ្ជាជីវៈ។ លើសពីនេះ ដើម្បីឱ្យសិស្សទទួលចំណេះដឹងជំនាញ និងបទពិសោធន៍ដែលចាំបាច់ ដើម្បីកំណត់ផ្នែកជម្រើស និងភាពជោគជ័យក្នុងសង្គមត្រូវ U.S Department of Education ឆ្នាំ1988-1991 W.Bush's and Bill Clinton's (1992-2000)។

លោក Carl D.Perkins បានលើកឡើងថា ការប្រឹក្សាអាជីពនិងយោបល់ត្រូវបានគេយកទៅដាក់នៅក្នុងសកម្មភាពបច្ចេកវិទ្យារួមមាន៖ (១)ជានាគុណភាព ភាពជាអ្នកអប់រំនិងការផ្គត់ផ្គង់ (២)បន្តចំណាយគាំទ្រកម្មវិធី (៣)ជានាប្រសិទ្ធភាព (៤)ជានាគុណភាពនៃសកម្មភាព (៥)តម្រូវឱ្យអភិវឌ្ឍន៍អាជីពនិងសកម្មភាព (៦)ប្រជាភិវឌ្ឍន៍ និង(៧)ដំឡើងការហ្វឹកហាត់។

នៅឆ្នាំ១៩៩៧-១៩៩៨ ការប្រឹក្សាអាជីពត្រូវបានជ្រើសរើសនៅក្នុងគម្រូតាមកន្លែងដូចជា អនុវិទ្យាល័យ វិទ្យាល័យ សាលាភូមិភាគ មហាវិទ្យាល័យ។ល។ សមាសភាពចំបងរបស់ការប្រឹក្សាអាជីពដ៏ជោគជ័យ គឺសកម្មភាពបន្តគ្នាឥតដាច់នៃគម្រោង ដើម្បីសម្រេចបានភារកិច្ចជាក់លាក់ដូចជា ការវាយតម្លៃខ្លួនឯងការធ្វើការសម្រេចចិត្ត ការកំណត់ទិសដៅនិងគម្រោងអាជីព គុណភាពនៃធន្ទៈ រៀបចំលទ្ធផលនិងកម្មវិធីឱ្យប្រសើរឡើង សមត្ថភាពនៃភាពជាអ្នកដឹកនាំ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងតម្រូវការគាំទ្រ មានការសហប្រតិបត្តិការយោគយល់ក្នុងកម្មវិធីប្រឹក្សាអាជីព។ ក្រុមប្រឹក្សាអាជីពនេះត្រូវមានចំណេះដឹងពីវិធីសាស្ត្រគរុកោសល្យដែលមានវិញ្ញាបនបត្រទទួលស្គាល់ដោយមជ្ឈមណ្ឌលកម្មវិធីប្រឹក្សាជំនាញអាជីព។ ការយល់ពីស្ថានភាពតាមកាលៈទេសៈគ្រប់គ្រាន់ សម្ភារៈធនធានចុងក្រោយត្រូវមានការអភិវឌ្ឍពង្រឹងសមត្ថភាពខ្លួនឱ្យកាន់តែខ្លាំង។

ប្រឹក្សាអាជីពគឺជាដំណើរការដ៏ធំដែលប្រើការនិយាយរបស់អ្នកផ្តល់ប្រឹក្សា ដោយភាពស្វាហាប់សហការនិងទាក់ទងនឹងមុខរបរឬទិសដៅអាជីពទៅអនាគតក្នុងនោះអ្នកផ្តល់ប្រឹក្សាផ្តល់វិធីសាស្ត្រហើយដំណើការ ដើម្បីជួយឱ្យយល់ពីខ្លួនឯងយល់ពីអាកប្បកិរិយាខ្លួនឯង ចំណុចវិជ្ជមាន និងធ្វើឱ្យដឹងពីការសម្រេចចិត្តក្នុងការប្រឹក្សាដែលមានទំនួលខុសត្រូវសម្រាប់ទង្វើរបស់សកម្មភាពខ្លួន Herr&Cramer ( 1996 )។

នៅឆ្នាំ២០១២ការប្រឹក្សាអាជីពចាប់ផ្តើមមាននៅក្នុងប្រទេសប្រទេសកម្ពុជាដែលត្រូវបានអនុវត្តនៅក្នុងអនុវិទ្យាល័យហើយទទួលប្រឹក្សាលើសិស្សដែលមានបញ្ហាខ្ពស់ឬសិស្សដែលទទួលបានលទ្ធផលមិនល្អក្នុងការរៀនសូត្រដែលផ្តោតលើតម្រូវការរបស់ពួកគេ សកម្មភាពត្រូវបានបំពេញដោយនាយកសាលាមានតិចតួច គ្រូប្រឹក្សាអាជីពជាលក្ខណៈបុគ្គលឬផ្តល់របនាសម្ព័ន្ធពិភាក្សានិងបកស្រាយអំពីផ្លូវអាជីពក្នុងស្រុកដូចជា ការចូលហ្វឹកហាត់បន្ថែមពីនេះទៅទៀត ការជួយអន្តរាគមន៍ធ្វើឱ្យលៃលក ដើម្បីផ្តល់ការគាំទ្រយុវជននិងបញ្ហាទាំងនោះគម្រោងនេះមិនត្រឹមតែផ្តល់ទៅយុវជនក្មេងៗដែលគ្មានគំនិតក្នុងជម្រើសអាជីពល្អបំផុតក្នុងជីវិតរបស់ពួកគេទេតែពិភាក្សាពីសុបិនរបស់ពួកគេពីរបៀបការតភ្ជាប់ដើម្បីឆ្ពោះទៅជោគជ័យក្នុងជីវិត។

**២.២.៣-ប្រសិទ្ធភាព**

ប្រសិទ្ធភាពមានន័យថាភាពធ្វើឱ្យសម្រេចបាន ភាពធ្វើឱ្យមានសិរីសួស្តីជោគជ័យ ( ជួនណាត ១៩៣៨ )។ ប្រសិទ្ធភាពមានន័យថា ភាពអាចសម្រេចដូចជាការសម្រេចចិត្តជាដើម។

**២.២.៤-បញ្ហាប្រឈម**

បញ្ហាប្រឈមគឺរឿងរ៉ាវដែលត្រូវដោះស្រាយរឿងត្រូវប្រឈមមុខដាក់គ្នា ( ជួន ណាត ១៩៣៨ )។

**២.២.៥-ការអនុវត្តការងារ**

ការអនុវត្តការងារគឺការធ្វើការងារឬការបំពេញការងារតាមតួនាទី។

ការប្រឹក្សាយោបល់អំពីអាជីពសំដៅលើដំណើរការអនុវត្តរបស់ក្រុម ឬបុគ្គល ដែលសង្កត់ធ្ងន់ទៅលើការយល់ដឹងនិងការស្វែងយល់ដោយអនុវត្តរបស់ក្រុមឬបុគ្គល ដែលសង្កន់ធ្ងន់ទៅលើការយល់ដឹង និងការស្វែងយល់ដោយខ្លួនឯង ហើយជួយសម្របសម្រួលមនុស្សឱ្យចេះអភិវឌ្ឍន៍ជីវិតរបស់ខ្លួនឱ្យមានន័យជួយមនុស្ស ឱ្យមានលទ្ធភាពអាចតម្រង់ទិសការងារដែលត្រឹមត្រូវដើម្បីជាមូលដ្ឋានក្នុងការរៀនសូត្រ ការធ្វើការងារ និងការធ្វើការសម្រេចចិត្តនានាក៏ដូចជាការគ្រប់គ្រងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរបរិស្ថានការងារនិងបរិស្ថានរៀនសូត្រនៅក្នុងដំណើរជីវិតប្រចាំថ្ងៃ Vire kinkar ( 2019 )។

## ២.៣-ប្រភេទនៃការប្រឹក្សាយោបល់

មានការប្រឹក្សាយោបល់ដ៏ពេញនិយមដូចជា៖

- ការប្រឹក្សាគ្រួសារនិងអាពាហ៍ពិពាហ៍
- កាប្រឹក្សាជំងឺ
- ការប្រឹក្សាអាជីព
- ការប្រឹក្សាផ្លូវចិត្ត
- ការប្រឹក្សាការរំលោភបំពាន
- ការប្រឹក្សាការស្រឡាញ់និងស្នេហា
- ការប្រឹក្សាការអប់រំ
- ការប្រឹក្សាលើទំនាក់ទំនង
- ការប្រឹក្សាការបាក់ទឹកចិត្ត

( Job Placement Services 1809-1919 )

## ២.៤-ប្រឹក្សាអាជីពនិងយោបល់

ទោះបីជាការប្រឹក្សាគឺជាចិត្តវិទ្យាដែលប្រើសម្រាប់ជួយយុវជនដោយពិភាក្សាអំពីក្តីស្រមៃ និងការតស៊ូដើម្បីឆ្ពោះទៅអាជីពមួយដែលសក្តិសមនិងខ្លួនគេ។ ដោយសារយុវជនខ្លះមិនច្បាស់អំពីក្តីសុបិនរបស់គេ ដូច្នេះហើយទាមទារឱ្យអ្នកប្រឹក្សាអាជីពពិភាក្សាពីមុខវិជ្ជាដែលពេញចិត្ត ហើយបន្ទាប់មកផ្តល់អំពីទំនាក់ទំនងការងារដែលគេអាចជ្រើសសម្រាប់អនាគត។

គ្រូប្រឹក្សាអាជីពមានសមត្ថកិច្ចធៀបទៅនឹងស្តង់ដាជាក់លាក់មួយដែលបានកំណត់ទុកជាមុន។ សមត្ថភាពគឺភាពដែលអាចប្រើប្រាស់នូវចំណេះដឹង ជំនាញ និងលក្ខណៈផ្ទាល់ខ្លួនសង្គម និងសមត្ថភាពនៅក្នុងការងារ ឬការសិក្សាក៏ដូចជាការអភិវឌ្ឍអាជីពនិងការអភិវឌ្ឍខ្លួនឯង ឬលទ្ធភាពក្នុងបរិបទដែលបានកំណត់។ សមត្ថភាពត្រូវបានព័ណ៌នាថា ជាការទទួលខុសត្រូវនិងមានស្វ័យភាព Mariu Pold ( 2019 )។

ការផ្តល់ប្រឹក្សាអាជីពនិងយោបល់រួមមានការជួយបុគ្គលណាម្នាក់ឱ្យរកឃើញបញ្ហាក់ វាយតម្លៃនិងស្វែងយល់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេដើម្បីស្គាល់ពីភាពខ្លាំងនិងខ្សោយ។ការប្រឹក្សាអាជីពយោបល់ក៏ជាផ្នែកមួយនៃការជំរុញលើកទឹកចិត្តនិងទិសដៅការងាររបស់ខ្លួនគេដើម្បីស្វែងរកជម្រើសនិងការអនុវត្តដែលអាចទៅបានយ៉ាងប្រសើរ

(នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ២០១៨)។ គ្រូគឺជាដំណើការរួមមួយមានបំណងបង្កើនការយល់ដឹងដោយខ្លួនឯងកំណត់នូវតម្រូវការ និងទិសដៅ គោលបំណងព្រមទាំងបង្កើតនិងអនុវត្តផែនការសកម្មភាពដើម្បីសម្រេចគោលដៅដែលចង់បាននោះ។ ការផ្តល់ប្រឹក្សាយោបល់ គឺជាសកម្មភាពដែលកើតចេញពីបំណងរបស់អ្នកប្រឹក្សាយោបល់និងអ្នកទទួលការប្រឹក្សាយោបល់ដែលជាទូទៅពាក់ព័ន្ធគ្នាទៅនឹងទំនាក់ទំនង ជាមួយនឹងការប្រាស្រ័យទាក់ទងជាទៀងទាត់។ លើសពីនេះ អ្នកប្រឹក្សាយោបល់ត្រូវបានគេស្នើឱ្យធ្វើការជាមួយក្រុមប្រឹក្សាភិបាលសាលារៀនបឋមសិក្សាឬមធ្យមសិក្សា។ សកម្មភាពសំខាន់ៗរួមមាន ការផ្តល់ប្រឹក្សាដល់សិស្សអំពីបញ្ហាផ្ទាល់ខ្លួននិងបញ្ហាទាក់ទងនិងការសិក្សាដែលសង្កត់ធ្ងន់ចម្បងគឺការផ្តល់ជ្រើសរើសអប់រំ និងការបណ្តុះបណ្តាលក្រោយមធ្យមសិក្សាដោយមិនផ្តោតលើបញ្ហាដែលទាក់ទងទៅនឹងការងារពីសាលាទេ។ អ្នកប្រឹក្សាយោបល់ពីអាជីពរៀបចំសម្របសម្រួលសេវាកម្មប្រឹក្សាយោបល់សេវាកម្មស្តីពីអាជីព និងជួយបញ្ជូនទៅសេវាកម្មជំនាញខាងក្រៅ បើសិនជាត្រូវការ។ បន្ថែមពីនេះទៅទៀតគ្រូប្រឹក្សាអាជីពអាចគ្រប់គ្រង និងបកស្រាយឧបករណ៍វាយតម្លៃអាជីពដែលមានលក្ខណៈស្តង់ដារួមទាំងការធ្វើតេស្តសមត្ថភាពនិងចំណាប់អារម្មណ៍របស់សិស្ស (នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ២០១៨)។ មិនតែប៉ុណ្ណោះប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូគឺពួកគាត់មានសិក្ខាសាលា មានសន្និសីទគ្រូប្រឹក្សា ថែមទាំងរៀបចំឱ្យមានខិត្តបណ្ណនិងសរសេរសម្ភារៈឧបទ្ទេសសម្រាប់បង្រៀនសិស្សហើយខិត្តបណ្ណត្រូវបានមកពីការបណ្តុះបណ្តាលវិជ្ជាជីវៈការអប់រំនៅវិទ្យាសាស្រ្ត និងវប្បធម៌នៅសហរដ្ឋអាមេរិច (UNESCO) ដែលបញ្ជាក់ឱ្យច្បាស់ថាការប្រឹក្សាអាជីពនៃយុវជនមាន៣សមាសភាគគឺៈ

(១) ផ្តល់ជំនួយឱ្យទទួលបាននូវចំណេះដឹងដ៏ប្រសើរក្នុងតំបន់ដូចជា ចំណាប់អារម្មណ៍គេអាចក្លាយជាយល់ដឹងល្អខាងមុខរបរហើយនិងអាជីព។ (២)ទាក់ទងភាពជាមនុស្សក្នុងការបង្កើតជាដំណើរការសម្រេចចិត្ត។ ដូចនេះហើយពួកគេបានជ្រើសរើសផ្លូវអាជីព ដែលស័ក្តិសមនិងចំណង់ចំណូលចិត្តរបស់ពួកគេ រួមទាំងតម្លៃ សមត្ថភាពការតម្រូវការហើយនិងគុណសម្បត្តិរបស់ពួកគេ។ (៣)គាំទ្របុគ្គលឱ្យមានភាពស្វាហាប់ក្នុងការជ្រើសរើសអាជីពរួមផ្សំនិងការគ្រប់គ្រង ការផ្លាស់ប្តូរមុខរបរនិងគុណភាពផ្សេងៗនៃតួនាទីជីវិតឱ្យល្អក្លាយជាអ្នកសិក្សាពេញមួយជីវិតក្នុងការអភិវឌ្ឍអាជីពប្រកបដោយការត្រិះរិះពិចារណាវិនិច្ឆ័យពេញមួយជីវិត (ដកស្រង់ពីការអភិវឌ្ឍអាជីពn.d)។ នៅសហរដ្ឋអាមេរិចការហ្វឹកហាត់និងបង្រៀនពីអាជីពខុសគ្នាពីតំបន់មួយទៅតំបន់មួយ ធ្វើឡើងដើម្បីអង្គការសង្គមរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម។ សហរដ្ឋមិនត្រឹមតែផ្តល់ឱ្យចំនួនការងារជាច្រើនដល់និយោជកក្នុងសង្គមទេ គេមាន

ផ្តល់សេវាប្រឹក្សាអាជីពដល់បុគ្គលទាំងនោះដោយសារគ្រូបង្រៀនជាបុគ្គលមានឥទ្ធិពលខ្លាំងក្នុងជំនាញនេះ។ ដូច្នេះហើយបានជាគម្រោងនៃការប្រឹក្សាយោបល់ទៅលើក្រសួងអប់រំ គឺសិស្សត្រូវរៀនតាមរយៈបទពិសោធន៍ របស់គ្រូ និងស្វែងយល់ពីចំណង់ចំណូលចិត្ត ជំនាញរបស់ខ្លួននិងលក្ខណៈសម្បត្តិ ការប្រព្រឹត្ត ដើម្បីជ្រើសរើសអាជីពទៅអនាគតក្រោមការលើកទឹកចិត្តពីគ្រូបង្រៀន ឪពុកម្តាយ និងឥទ្ធិពលបរិស្ថាន កាលៈទេសៈ ចំណេះដឹងបុគ្គល និងការត្រួតពិនិត្យរបស់បុគ្គលជាសិស្សផ្ទាល់ខ្លួន ( JohnD. KRUM BoIT2 )។ វាមានសារៈសំខាន់ណាស់សម្រាប់បុគ្គលដែលរក្សាអាជីព របៀបគ្រប់គ្រងដឹកនាំអាជីព ជំនាញដឹកនាំអាជីព វាបញ្ជាក់ភាពជាមនុស្សក្នុងការធ្វើការមានវត្ថុបំណងវែងឆ្ងាយ។

## ២.៥-លក្ខណៈសម្បត្តិនៃអ្នកប្រឹក្សាអាជីព

គ្រូប្រឹក្សាអាជីពគាត់ត្រូវមានជំនាញនៃការគ្រប់គ្រងការបង្រៀនអាជីព ដើម្បីជំរុញជំនាញនេះបានល្អទាមទារឱ្យគ្រូមានចំណេះដឹងទូលំទូលាយប្រកបដោយប្រសិទ្ធភាពលើមុខវិជ្ជានោះដូចជា៖

- **ជំនាញទំនាក់ទំនងគ្រូត្រូវមានការប្រាស្រ័យទាក់ទង**ជាមួយសិស្សបានល្អ ជាមួយគ្រូមុខវិជ្ជាដទៃទៀតជាមួយនាយកសាលាជាពិសេសត្រូវមានទំនាក់ទងជាមួយមាតាបិតាសិស្ស ដោយសារត្រូវការអភិវឌ្ឍអាកប្បកិរិយាល្អរបស់សិស្ស និងដោះស្រាយបញ្ហាប្រឈមដែលកើតឡើងចំពោះសិស្សឱ្យទាន់ពេលវេលា ប្រាប់ព័ត៌មានត្រឡប់ពីតម្រូវការកូនរបស់គាត់ និងរឿងរ៉ាវដែលកើតឡើងរវាងមិត្តរួមថ្នាក់ ច្បាប់បទដ្ឋាន នយោបាយ ចំណាប់អារម្មណ៍ ផលប្រយោជន៍ វិន័យច្បាប់ផ្សេងៗទៀត Castells ( 2000 )។ លើសពីនេះ ត្រូវមានជំនាញទំនាក់ទំនងអំពីការងារ និងឱកាសសមស្រប ដោយយោងទៅតាមជំនាញសមត្ថភាពគ្រូត្រូវមានការទាក់ទងទីផ្សារការងារ ពីទិដ្ឋភាពសំខាន់ៗក្នុងការសម្រេចចិត្តត្រឹមត្រូវហើយទោះជាការងារស្ម័គ្រចិត្តគ្មានទទួលបានប្រាក់ខែក៏ដោយ នេះជាការងារដើម្បីទទួលបានបទពិសោធន៍ការងារពីព្រោះកន្លែងការងារឥឡូវតម្រូវឱ្យមានបទពិសោធន៍រយៈពេលខ្លី ឬវែង នេះជាតួនាទីគ្រូប្រឹក្សាអាជីពត្រូវការជួយសិស្ស។
- **គ្រូត្រូវមានអត្តចរិកល្អសមរម្យ**ដែលទាក់ទាញចំណាប់អារម្មណ៍សិស្ស ក្នុងការប្រឹក្សាយោបល់ជាមួយប្រកបដោយទំនុកចិត្តខ្ពស់ថា តើពួកគេគួរផ្លាស់ប្តូរគម្រោងអភិវឌ្ឍអាជីពដែលសិស្សយល់ស្របតាមថាល្អ ហើយការប្រឹក្សាទៀតសោតត្រូវមានចិត្តសាស្ត្រដ៏ទូលំទូលាយដែលត្រូវពង្រីកក្នុងរចនាសម្ព័ន្ធប្រឹក្សាអាជីពបង្ហាញផ្លូវពួកគេក្នុងការរកចាប់អាជីព យោងទៅតាមជំនាញនិងសមត្ថភាព និងការប្រឹងប្រែង

របស់ពួកគេក្នុងជីវិតអាជីព។

- **ការទទួលការហ្វឹកហាត់ពីវិធីសាស្ត្រល្អ**ៗទាន់សម័យ ហើយបន្តចែករំលែកពីចំណេះដឹងដែលទទួលបាន ជាពិសេសធ្វើឱ្យមានភាពជោគជ័យក្នុងការសន្ទនាពីអាជីព។ គ្រូត្រូវបង្រៀនពីរបៀបវិនិច្ឆ័យពិនិត្យពិច័យពីចំណុចខ្សោយ ហើយបន្ទាប់មកពុះពារពួកគេឱ្យបានជោគជ័យ រួមទាំងការផ្តល់សេវា ផ្តល់ជម្រើសអាទិភាព ក្នុងការពួកគេត្រូវការជំនួយ ដែលការសម្រេចចិត្តបំពេញចំណង់ចំណូលចិត្ត និងពង្រីកការអប់រំ Arthur,M,B Rosseau,D.M ( 1996 )។
- **ការបង្រៀនទៀងទាត់តាមកម្មវិធីនិងតាមបញ្ញត្តិម៉ោង**តាមកាលវិភាគ ត្រូវមានស្តង់ដាគ្រប់គ្រងអាជីពផ្ទាល់ខ្លួនគ្រូត្រូវផ្តល់ឱកាស ដើម្បីរៀបចំភ្ជាប់និងការផ្តល់គុណភាពអប់រំ និងការធ្វើការងារជំនញផ្ទាល់ខ្លួនដើម្បីរៀបចំក្នុងដំណើរអាជីពជាអ្នកប្រឹក្សានិងអ្នករៀនពេញមួយជីវិត ហើយក៏ដើម្បីឱ្យការងារមានប្រសិទ្ធផលបង្កើនល្បឿនក្នុងទីផ្សារការងារ The Council of the European Union ( 2015 )។
- **មានការរៀបចំការបង្រៀននិងវិធីសាស្ត្រ៖** គ្រូប្រឹក្សាត្រូវមានការរៀបចំមេរៀនមុននឹងបង្រៀនមេរៀនដល់សិស្ស ត្រូវមានការរៀបចំសម្ភារៈឧបទ្ទេសសម្រាប់គាំទ្រការបង្រៀន និងមានកិច្ចតែងការបង្រៀនប្រកបដោយប្រសិទ្ធភាព។ ចំណែកវិធីសាស្ត្រត្រូវមានវិជ្ជាជីវៈដូចគ្នា ហើយអនុវត្តតាមខ្នាតនៃអាជីពបុគ្គលង្វាស់បន្តដើម្បីធ្វើការងារជំនាញស្នុគស្មាញ ដែលជាប់ទាក់ទងនិងការប្រឹក្សាចិត្តសាស្ត្រវាស់ស្ទង់ការអប់រំធ្វើឱ្យមានការចូលរួមយ៉ាងសកម្មចំពោះសិស្ស ( Career Guidance and Student Counseling )។ យោងទៅលើការជ្រើសរើសអាជីពជំនាញមិនមែនជាសម្រេចចិត្តចុងក្រោយទេប៉ុន្តែវាជាលទ្ធផលនៃការអភិវឌ្ឍនៃជីវិតរបស់បុគ្គលគ្រប់ពេលវេលា រឿងនេះជារឿងសំខាន់ណាស់សម្រាប់ជីវិតរបស់ពួកគាត់។ ដើម្បីទទួលបានឱកាសការងារដែលអាចទៅរួចវាទាក់ទងនិងជំនាញសមត្ថភាព គុណសម្បត្តិហើយនិងបទពិសោធន៍ការងារពីពេលមុនៗ ដូច្នេះគ្រូប្រឹក្សាអាជីពអាចផ្តល់ប្រឹក្សាតម្រង់ឆ្ពោះទៅចំទិសដៅ។
- **ជំនាញដោះស្រាយបញ្ហា៖** ជំនាញនេះគឺស្នុគស្មាញបន្តិចតែវាមានសារៈសំខាន់ណាស់ក្នុងនាមជាគ្រូប្រឹក្សាអាជីព។ ដូច្នេះហើយគាត់ត្រូវមានកម្លាំងនិងបែបផែនចរិកលក្ខណៈបច្ចេកទេស ជាពិសេសគាត់ត្រូវដឹងរឿងផ្សេងៗជាច្រើនក្នុងសង្គម ហើយធ្វើការជាបណ្តាញដែលជួបពិភាក្សារវាងគ្នានិងគ្នា ព្រោះបញ្ហាមិនអាចដោះស្រាយតែម្នាក់ឯងបានទេ Mikes and Snow ( 1986 )។

- **ភាពជាអ្នកដឹកនាំ៖** គ្រូត្រូវចេះជំនាញនេះ ព្រោះត្រូវបង្រៀនសិស្សពីជំនាញនេះដែលមានសារៈប្រយោជន៍ក្នុងការធ្វើការងារ។ កាលណាគ្រូមានភាពជាអ្នកដឹកនាំ គ្រូមានសមត្ថភាពយល់ច្បាស់ពីប្រភេទអត្តចរិកផ្សេងៗរបស់សិស្ស ដែលអាចជួយជំរុញការចូលរួមក្នុងការរៀននិងលើកការធ្វើការប្រព្រឹត្តត្រឹមត្រូវរបស់សិស្ស។ លើសពីនេះ គាត់រួមចំណែកផ្តល់គ្រឹះនៃការយល់ពីការលើកទឹកចិត្តមនុស្សក្នុងការប្រព្រឹត្តនិងផ្លូវចិត្តជួយឱ្យគ្រូអភិវឌ្ឍការគិតវិជ្ជមាន និងមានជំហរគំនិតខ្លួនឯងនិងមានការតាំងចិត្តខ្ពស់ Combs& Avila ( 1985 )។

  តាមការស្រាវជ្រាវរបស់សាកលវិទ្យាល័យTallin ដែលសហការជាមួយ Foundation Innove បានបង្ហាញថា ស្តង់ដាក្នុងការគ្រប់គ្រងជំនាញអាជីពគឺមានសមត្ថភាព សមត្ថកិច្ច មធ្យោបាយនិងតម្លៃជាលទ្ធផលដែលអាចទាំងខ្លួនពួកគាត់ជាអ្នកប្រឹក្សា និងប្រយោជន៍ក្នុងការអភិវឌ្ឍសមត្ថភាពខ្លួនគេត្រូវមាន៤ចំណុចដែរដូចជា៖ (១)អភិវឌ្ឍន៍ទំនុកចិត្តលើខ្លួនឯង ពេលបង្រៀនគ្រូមានតួនាទីឱ្យសិស្សវិភាគពីតម្លៃ ចំណាប់អារម្មណ៍ចំណេះដឹង និងជំនាញ វិភាគលើអត្តចរិក រួមទាំងពង្រឹងបទពិសោធន៍ដើម្បីភ្ជាប់ការរៀនពីមេរៀនទៅនិងឱកាសការងារក្នុងនេះសិស្សត្រូវបានលើកទឹកចិត្ត ដើម្បីធ្វើឱ្យគេរីកចម្រើននិងអភិវឌ្ឍទំនួលខុសត្រូវរបស់ពួកគេ។ (២)ការវិភាគត្រូវឱ្យសិស្សអាចយល់ពីការភ្ជាប់រវាងការអប់រំនិងទីផ្សារការងារដោយស្វែងយល់វិភាគ និងពីប្រយោជន៍ប្រើការភ្ជាប់ព័ត៌មានទាក់ទងនិងការសិក្សា ការងារ និងជម្រើសជីវិតបុគ្គល។ (៣)គម្រោងធ្វើឱ្យសិស្សយល់ពីទិដ្ឋភាពផ្សេងៗដែលពួកគេត្រូវការដើម្បីពិចារណាក្នុងគម្រោងអាជីពកំណត់ពីឱកាសអាចទៅរួច ដោយយោងលើស្ថានភាពរបស់ពួកគេទាំងគ្មានគោលបំណងត្រៀមមុនក្នុងការសម្រេចចិត្ត។ (៤)សកម្មភាពគឺពិតជាមានផលជះទៅលើសិស្សព្រោះសិស្សចាប់ផ្តើមបន្តសកម្មភាព ដើម្បីសម្រេចបានទិសដៅទាក់ទងនិងទិសដៅផ្សេងៗក្នុងជីវិតហើយបន្សល់ទុកភាពវិជ្ជមាន ហើយតួនាទីទំនាក់ទំនងការផ្តល់យោបល់និងការអប់រំឬការងារ។

- មានការតាំងចិត្តឬត្រួតពិនិត្យខ្លួនឯង (commitment and self-control )

កាលណាមានការតាំងចិត្តហើយ និងត្រួតពិនិត្យខ្លួនឯងជាប្រចាំ ការងារដែលគ្រូនោះធ្វើប្រាកដជាបានល្អហើយគេច្រើនប្រើដើម្បីដោះស្រាយបញ្ហាបុគ្គល ឬត្រួតពិនិត្យសកម្មភាពផ្សេងៗ ដែលជះឥទ្ធិពលដល់អាកប្បកិរិយារបស់មនុស្ស Thoresen ( 1976 )។

- គំនិតម្ចាស់ការ (self –concept ) self esteen

មានតួនាទីសិក្សាពីឥរិយាបថរបស់អ្នករៀន មានការកសាងឡើងវិញនូវចំណេះដឹង មានការហ្វឹកហាត់ ជាក់លាក់ ហើយសារតែយើងជាអ្នកប្រឹក្សាអាជីពមិនអាចដោះស្រាយបញ្ហាសួរសំណួរតែមួយ ប្រើវិធីសាស្ត្រតែមួយ មិនបានជោគជ័យទេត្រូវផ្លាស់ប្តូរទៅតាមតម្រូវការត្រូវដឹងថានរណាយើងកំពុងព្យាយាម ជួយអ្នកប្រឹក្សាអាជីពភាគច្រើន ត្រូវធ្វើការរៀបចំជាមួយសិស្សជាគំរូឆ្លុះបញ្ចាំងពីតថភាពពិតងាយស្រួល ជួយទៅដល់សិស្សជ្រើសរើសអាជីពឆ្ពោះទៅរកការងារ រួមបញ្ចូលទាំងគោលគំនិតបន្តអភិវឌ្ឍអាជីព Thoresen(1969) Hebbar(1974)។ សេចក្តីណែនាំស្តីពីការអនុវត្តសេវាប្រឹក្សាអាជីពតាមគ្រឹះស្ថានមធ្យមសិក្សាលេខ៤០ អយក សណន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និង និង កីឡាបានលើកឡើងអំពីភារកិច្ចរបស់គ្រូប្រឹក្សាអាជីពក្នុងការងារមគ្គុទេសក៍ក្នុងថ្នាក់រៀននិងការងារផ្តល់ប្រឹក្សាណែនាំក្នុងនាមជាអ្នកប្រឹក្សាអាជីព។ ទាក់ទងការងារមគ្គុទេសក៍ក្នុងថ្នាក់រៀនវិញគឺគ្រូប្រឹក្សាអាជីពត្រូវរៀបចំកិច្ចតែងការបង្រៀនម៉ោងមគ្គុទេសក៍ក្នុងថ្នាក់រៀន ដោយផ្អែកលើសៀវភៅប្រឹក្សាអាជីព និងព័ត៌មានស្តីពីការសិក្សាជំនាញមួយថ្នាក់ ចំនួនមួយម៉ោងក្នុងមួយសប្តាហ៍ សម្រាប់មួយឆ្នាំសិក្សាទៅតាមកាលវិភាគដែលគណៈគ្រប់គ្រងរៀបចំជូន។ ត្រូវរៀបចំសម្ភារឧបទ្ទេសគាំទ្រដល់ការបង្រៀនម៉ោងមគ្គុទេសក៍ក្នុងថ្នាក់រៀន និងសកម្មភាពសិក្សាដែលគាំទ្រដល់ការសិក្សារបស់សិស្សទៅតាមកម្រិតភូមិសិក្សារបស់ខ្លួន។ ត្រូវស្វ័យសិក្សាស្រាវជ្រាវបន្ថែមអំពីគោលវិធីសិស្សមជ្ឈមណ្ឌល វិធីដោះស្រាយបញ្ហា វិធីសាស្ត្រផ្តល់ប្រឹក្សាណែនាំទល់មុខ ព័ត៌មានស្តីពីតម្រូវការមុខជំនាញ និងមុខរបរ និងព័ត៌មានស្តីពីទីផ្សារការងារក្នុងបរិបទកម្ពុជាបច្ចុប្បន្ននិងទៅអនាគត។ ចំណែកការងារផ្តល់ប្រឹក្សាណែនាំគឺគ្រូប្រឹក្សាអាជីពត្រូវរៀបចំបន្ទប់ប្រឹក្សាឱ្យមានរបៀបរៀបរយល្អ សមរម្យជាទីកន្លែងផ្តល់ប្រឹក្សាដល់សិស្ស។ ត្រូវផ្សព្វផ្សាយអំពីសេវាប្រឹក្សាអាជីពតាមគ្រប់រូបភាព ដែលអាចធ្វើបាននិងជំរុញឱ្យសិស្សមកទទួលសេវាប្រឹក្សាអាជីពទល់មុខជាលក្ខណៈក្រុម និងជាលក្ខណៈបុគ្គលទាក់ទងនឹងការសិក្សា ឬបញ្ហាផ្ទាល់ខ្លួនជាប្រចាំ។ ត្រូវរៀបចំឱ្យមានម៉ោងប្រឹក្សាទល់មុខជាក្រុម សម្រាប់គ្រប់កម្រិតថ្នាក់យ៉ាងតិចចំនួន០៦ម៉ោងក្នុងមួយសប្តាហ៍។ បន្ទាប់ពីម៉ោងមគ្គុទេសក៍ក្នុងថ្នាក់រៀន គ្រូប្រឹក្សាអាជីពត្រូវប្រចាំការនៅក្នុងបន្ទប់ប្រឹក្សាអាជីពចំនួន០៤ម៉ោងក្នុងមួយថ្ងៃនៃថ្ងៃធ្វើការសម្រាប់គ្រូប្រឹក្សាអាជីពដែលជាប់ពីមុខវិជ្ជាឯកទេសដើមនិងចំនួន០២ម៉ោងក្នុងមួយថ្ងៃនៃថ្ងៃធ្វើការ សម្រាប់គ្រូប្រឹក្សាអាជីពដែលមិនទាន់ជាប់ពីមុខវិជ្ជាឯកទេសដើម ដើម្បីរង់ចាំជួបសិស្សដែលត្រូវការសេវាប្រឹក្សាណែនាំទល់មុខ (ក្រសួងអប់រំ ២០១៧)។

## ២.៦-សារៈសំខាន់នៃការប្រឹក្សាអាជីពនិងយោបល់

ការប្រឹក្សាអាជីពនិងយោបល់មានឥទ្ធិពលខ្លាំងក្នុងការកែប្រែបុគ្គលិកលក្ខណៈរបស់សិស្សឬយុវជនឱ្យយល់ពីគោលដៅរបស់ពួកគេនិងឱ្យពួកគេមានទំនុកចិត្តនិងមានទំនាក់ទំនងល្អជាមួយមនុស្សជុំវិញខ្លួនគេ ជាពិសេសគេមានភាពកក់ក្តៅធ្វើឱ្យពួកគេមានអារម្មណ៍ស្វាគមន៍និងស្គាល់ពីតម្លៃផ្ទាល់ខ្លួន។ ការប្រឹក្សាអប់រំធ្វើឱ្យការអប់រំចំបង។

នៅប្រទេសកម្ពុជា ខេត្តកំពង់ចាមគឺគ្មានសាលាផ្ទាល់ខ្លួន ដើម្បីផ្តល់អាជីពគ្រប់គ្រាន់នៅក្នុងការគាំទ្រយុវជនហើយនាយកសាលារវល់មិនខ្វល់អំពីកម្មវិធីនេះ។ បញ្ហាយុវជនមិនផ្តោតលើសិស្សឬយុវជនឱ្យច្បាស់ គ្មានការប្រឹក្សាបុគ្គល ជាពិសេសគ្មានព័ត៌មាន ប្រាក់កំរៃហិរញ្ញវត្ថុ គ្មានព័ត៌មានថាកន្លែងត្រូវទៅសិក្សា។ នៅពេលអនាគតគ្រូប្រឹក្សាអាជីពប្រឈម និងស្ថានភាពអារម្មណ៍ មានការភ្ញាក់ផ្អើលចំពោះបញ្ហារបស់សិស្សឬអតិថិជន Hill,Sullivan,Knox and Schlosser(2007)មានការសម្រេចចិត្តលើសប្រមាណដើម្បីជួយតម្រូវការហួសហេតុ ក្នុងការភ្ជាប់និងអារម្មណ៍ផ្ទាល់ខ្លួនខុសគ្នារវាងធម្មតានិងមិនធម្មតា។ មួយវិញទៀតការមានទំនុកចិត្តមិនប្រាកដឡើយ។

### ២.៦.១-ការទទួលខុសត្រូវរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

ការអនុវត្តសេវាប្រឹក្សាអាជីពនៅតាមគ្រឹះស្ថានសិក្សាមធ្យមសិក្សា ក្រោមការមើលខុសត្រូវរបស់មន្ទីរអប់រំ។

-មន្ទីរអប់រំ យុវជននិងកីឡារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងប្រកបដោយភាពច្បាស់លាស់ដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្រោមឱវាទ ដែលមានរៀបចំសេវាប្រឹក្សាអាជីពអំពីភារកិច្ចរបស់គ្រឹះស្ថាន និងភារកិច្ចរបស់គ្រូប្រឹក្សាអាជីពក្នុងគ្រឹះស្ថាន។

-ជួយចង្អុលបង្ហាញគោលដៅបណ្តាញ និងជួយសម្របសម្រួលការងារបណ្តាញដល់គណៈគ្រប់គ្រងគ្រឹះស្ថាន និងគ្រូប្រឹក្សាអាជីពដោយស្មារតីជ្រោមជ្រែង និងសហការ។

-រៀបចំគ្រោងថវិកាប្រចាំឆ្នាំបន្ថែមជូនគ្រឹះស្ថានសិក្សាមធ្យមសិក្សាសាធារណៈ ដែលមានសេវាប្រឹក្សាអាជីពសម្រាប់គាំទ្រដំណើរការបច្ចេកទេសមូលដ្ឋាននៃការផ្តល់សេវាប្រឹក្សាអាជីពក្នុងគ្រឹះស្ថានសិក្សា។

-រៀបចំរបបប្រាក់ម៉ោងបន្ថែមជូនគ្រូប្រឹក្សាអាជីពក្នុងគ្រឹះស្ថានមធ្យមសិក្សាសាធារណៈដែលអនុវត្តកម្មវិធីប្រឹក្សាអាជីពដោយមានភាពទន់ភ្លន់ប្រកបដោយប្រសិទ្ធភាព និងស្របតាមគោលការណ៍ណែនាំក្នុងអនុក្រឹត្យលេខ១០ អនក្រ.បក ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ និងសេចក្តីណែនាំលេខ១៧ អយក.សណនស្តីពីការអនុវត្តអនុក្រឹត្យលេខ១០ អនក្រ.បក របស់ក្រសួងអប់រំ យុវជននិងកីឡាចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧(ក្រសួងអប់រំ ២០១៧)។

## ២.៦.២-ការទទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សា

ការអនុវត្តសេវាប្រឹក្សាអាជីពនៅតាមគ្រឹះស្ថានសិក្សាមធ្យមសិក្សា ស្ថិតក្រោមការមើលខុសត្រូវរបស់សាលា។

-គណៈគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ត្រូវរៀបចំបង្កើតគណៈកម្មការតម្រង់ទិសវិជ្ជាជីវៈ ប្រសិនបើគ្រឹះស្ថានមិនទាន់បានបង្កើតគណៈកម្មការតម្រង់ទិសវិជ្ជាជីវៈ ដោយបញ្ចូលគ្រូប្រឹក្សាអាជីពជាសមាជិកប្រចាំការក្នុងគណៈកម្មការឬត្រូវប្រជុំកែសម្រួលសមាសភាពគណៈកម្មការតម្រង់ទិសវិជ្ជាជីវៈប្រចាំគ្រឹះស្ថានរបស់ខ្លួន។ ប្រសិនគ្រឹះស្ថានមានគណៈកម្មការតម្រង់ទិសវិជ្ជាជីវៈរួចហើយ ដោយដាក់បញ្ចូលគ្រូប្រឹក្សាអាជីពជាសមាជិកប្រចាំការក្នុងគណៈកម្មការ។

-ចំពោះគ្រឹះស្ថានសិក្សាដែលមានគ្រូប្រឹក្សាអាជីពដាច់ចេញពីមុខវិជ្ជាឯកទេសដើម ត្រូវរៀបចំម៉ោងមគ្គទេសក៍ក្នុងថ្នាក់ចំនួន០១ម៉ោងក្នុងមួយសប្តាហ៍ក្នុងមួយថ្នាក់ និងម៉ោងប្រចាំការក្នុងសាលារៀនចំនួន០៤ម៉ោងក្នុងមួយថ្ងៃដើម្បីរៀបចំសេវាប្រឹក្សាយោបល់ទល់មុខជាមួយសិស្សជាលក្ខណៈបុគ្គលឬជាក្រុម។

-ចំពោះគ្រឹះស្ថានសិក្សាដែលមានគ្រូប្រឹក្សាអាជីពមិនទាន់ដាច់ចេញពីមុខវិជ្ជាឯកទេសដើម ត្រូវរៀបចំសេវាប្រឹក្សាអាជីពបត់បែនទៅតាមភាពជាក់ស្តែងនៅក្នុងគ្រឹះស្ថានសិក្សា ដោយតម្រូវឱ្យគ្រូប្រឹក្សាអាជីពបង្រៀនម៉ោងមគ្គទេសក៍ក្នុងថ្នាក់រៀនចំនួន០១ម៉ោង ក្នុងមួយសប្តាហ៍ក្នុងមួយថ្នាក់ និងម៉ោងប្រចាំការក្នុងសាលារៀនចំនួន០២ម៉ោង ក្នុងមួយថ្ងៃ ដើម្បីរៀបចំសេវាប្រឹក្សាយោបល់ទល់មុខទៅតាមស្ថានភាពជាក់ស្តែង និងបង្រៀនម៉ោងឯកទេសដើមរបស់ខ្លួនដដែលរហូតដល់គ្រឹះស្ថានទទួលបានគ្រូថ្មីជំនួសគ្រូប្រឹក្សាអាជីព។

-ជំរុញឱ្យគ្រូប្រឹក្សាអាជីពរៀបចំម៉ោងប្រឹក្សាទល់មុខជាមួយក្រុមគ្រប់កម្រិតថ្នាក់ យ៉ាងតិចចំនួន០៦ម៉ោងក្នុងមួយសប្តាហ៍។

-រៀបចំឱ្យមានបន្ទប់ប្រឹក្សាអាជីពដាច់ដោយឡែកពីបន្ទប់ទីចាត់ការ បណ្ណាល័យ បន្ទប់គេហកិច្ចនិងបន្ទប់រៀនប្រសិនបើគ្រឹះស្ថានសិក្សាមានលទ្ធភាព។

-ជួយចង្អុលបង្ហាញគោលដៅបណ្តាញ និងជួយសម្របសម្រួលការងារបណ្តាញរបស់គ្រូប្រឹក្សាអាជីពដូចជា អញ្ជើញវាគ្មិនធ្វើបទបង្ហាញក្នុងគ្រឹះស្ថានសិក្សា ការចុះជួបមាតាបិតាសិស្ស សហគមន៍ មជ្ឈមណ្ឌល និងអង្គការឬសហគមន៍នានា ការរចុះប្រមូលព័ត៌មានស្តីពីបណ្តាញប្រឹក្សាអាជីព។

-រៀបចំបញ្ជីវត្តមានប្រចាំថ្ងៃនិងប្រចាំម៉ោងរៀងរាល់សប្តាហ៍ដោយឡែកសម្រាប់គ្រូប្រឹក្សាអាជីពក្នុងគ្រឹះស្ថាន។

-កៀងគរធនធាន និងផ្តល់ការគាំទ្រគ្រប់លទ្ធភាពដល់គ្រូប្រឹក្សាអាជីពចំពោះដំណើរការរៀបចំវេទិកា អញ្ជើញវាគ្មិនធ្វើ

បទបង្ហាញក្នុងគ្រឹះស្ថានរបស់ខ្លួនដោយស្មារតីសហការនិងសម្របសម្រួលខ្ពស់។

-ពិនិត្យតាមដាន គាំទ្រនិងជំរុញការអនុវត្តសេវាប្រឹក្សាអាជីពក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនឱ្យមានមានប្រសិទ្ធភាព។

## ២.៧-របៀបធ្វើការប្រឹក្សាលើសិស្ស

យោងទៅលើTEVETA បានជ្រើសរើសដំណើការដោយប្រាប់ព័ត៌មានទៅសិស្សអំពីវិធីសាស្ត្រក្នុងការប្រាប់ពីគោលបំណងនិងផ្តល់ឱ្យសិស្សចូលជាសមាជិករបស់គេ។ ទោះបីជាវាមិនមែនជាការផ្តល់អនុសាសន៍ឬការផ្តល់ប្រឹក្សាក៏វាបានគាំទ្រ ដើម្បីឱ្យសិស្សដឹងពីជម្រើសរបស់ពួកគេលើកទឹកចិត្តពួកគេឱ្យចូលរួម និងគោរពតាមនិងអនុវត្តតាមគោលនយោបាយគេ បន្ទាប់មកពង្រឹងសេវាកម្មប្រាប់សិស្សពីសក្តានុពលរបស់គេ ដោយជួបផ្ទាល់ជាមួយសិស្សជាពិសេសសិស្សមានបញ្ហាTEVETA(2016)។ គេធ្វើការផ្តល់ប្រឹក្សាតាមរយៈកម្មវិធីវិទ្យុ ទូរស័ព្ទហៅចូល បង្ហាញផ្លូវប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតរួចគ្រូជួយពន្យល់ពីសារៈសំខាន់នៃការអប់រំ។

## ២.៨-បញ្ហាប្រឈមនៃអ្នកប្រឹក្សាអាជីព

នៅប្រទេសឥណ្ឌាការផ្តល់ប្រឹក្សាលើការរៀនសូត្រ (ការអប់រំ) ក្រោយកម្រិតឧត្តមសិក្សា អ្នកប្រឹក្សាធ្វើការរៀបចំផ្សេងៗក្នុងការស្ថានភាពដើមដឹងពីបញ្ហាពិបាក និងបញ្ហាប្រឈម ដែលអ្នកប្រឹក្សាជួបប្រទះការសិក្សាថ្មីបានបង្ហាញការគណនា(qualitativeframework) ជាមួយនឹងការរុករករៀបចំដូចមហាវិទ្យាល័យជំនួយការវិនិយោគកម្មវិធី(EAP)បានរកឃើញថាអ្នកប្រឹក្សាខ្វះចំណេះដឹងនៃការប្រឹក្សាយោបល់ប្រាក់ខែទាប គ្មានសន្តិសុខនិងសុវត្ថិភាពខ្វះបណ្តាញនៃការប្រឹក្សា Rao(1991) មានបញ្ហាក្នុងការអនុវត្តឆ្លុះបញ្ចាំងពីអតិថិជន។

សរុបមក ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពត្រូវមានចំណុចទាំង៧ខាងលើនេះ។ ចំណែកឯបញ្ហាប្រឈមដែលកើតមានឡើងនៅប្រទេសកម្ពុជាវិញគឺការចូលរួមក្នុងការប្រឹក្សាជួយសិស្សមានកម្រិតនិងសិស្សមិនមានភាពច្បាស់លាស់នៃការជ្រើសរើសអាជីពខ្លួនរួមជាមួយសិស្សខ្វះព័ត៌មានអប់រំ និងសេវាប្រឹក្សាអាជីពជាញឹកញាប់។ នាយកនិងគ្រូនៅមានកម្រិតស្វែងយល់ពីអារម្មណ៍របស់សិស្ស។ គ្រូមិនបានចូលរួមឱ្យបានគ្រប់គ្រាន់ក្នុងការបណ្តុះបណ្តាល (គម្រោងវិភាគបញ្ហារបស់អ្នកប្រឹក្សាអាជីពក្នុងសាលាឆ្នាំ២០១២)។

# ជំពូកទី៣

# វិធីសាស្រ្តស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើគឺអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្រ្ត នៅក្នុងការជ្រើសរើសសំណាកដោយមានគោលបំណងក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យដោយផ្តោតលើតែសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវទិន្នន័យបានជាក់ច្បាស់ និងត្រឹមត្រូវដែលអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីទីតាំងភូមិសាស្រ្តនិងភាគសំណាក ឧបករណ៍ស្រាវជ្រាវ ដំណើរការប្រមូលទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.១-ទិសាលភាពនិងដែនកំណត់

ខេត្តបន្ទាយមានជ័យស្ថិតនៅភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចំងាយផ្លូវ៣៥៩គមពីរាជធានីភ្នំពេញ ហើយមានព្រំប្រទល់ខាងកើតទល់ខេត្តសៀមរាប ខាងលិចទល់និងប្រទេសថៃ ខាងត្បូងទល់និងខេត្តបាត់ដំបង ខាងជើងទល់និងខេត្តឧត្តរមានជ័យ និងប្រទេសថៃផងដែរ។

ខេត្តបន្ទាយមានជ័យមានស្រុកចំនួន៧ និងក្រុងចំនួន២គឺក្រុងសិរីសោភ័ណ និងក្រុងប៉ោយប៉ែត ស្រុកមង្គលបូរី ស្រុកថ្មពួក ស្រុកស្វាយចេក ស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក ស្រុកអូរជ្រៅ និងស្រុកម៉ាឡៃ ដោយក្នុងនោះ ឃុំមានចំនួន៥៥ឃុំ មានសង្កាត់ចំនួន១០ និងភូមិមានចំនួន៦៥៦ភូមិ។ ទីរួមខេត្តបន្ទាយមានជ័យ ស្ថិតនៅលើទីតាំងក្រុងសិរីសោភ័ណ ត្រង់ចំណុចប្រសព្វ ផ្លូវជាតិលេខ ៥ ផ្លូវជាតិលេខ៦និងផ្លូវជាតិលេខ៥៦។ ផ្ទៃដីសរុបខេត្តបន្ទាយមានជ័យមានចំនួន៦.៦៧៩០០គម$^{២}$ ក្នុងនោះផ្ទៃដីសម្រាប់បង្កបង្កើនផលមានចំនួន៣៦៣.៦៥៧ហ.តក្នុងនោះដីស្រែ៣០៨.៩០៧ហត។ ប្រជាពលរដ្ឋមានចំនួន១៨៨.៥៥៥គ្រួសារ។ ចំនួនមនុស្សសរុបមាន៧៨៩.៩៥៣នាក់ក្នុងនោះស្រីមានចំនួន៣៩៣.៦៦១នាក់។ ប្រជាពលរដ្ឋចាប់ពីអាយុ១៨ឆ្នាំឡើងទៅមាន៤៥០.៣៨៧នាក់ក្នុងនោះស្រីមានចំនួន២៥៤.៣០៥នាក់ ។ ដង់ស៊ីតេប្រជាពលរដ្ឋគឺ១០៨នាក់ក្នុង១គីឡូម៉ែត្រការ៉េហើយ៨០%ជាប្រជាកសិករ (របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩របស់មន្ទីរព័ត៌មាន)។

## ៣.២-ការជ្រើសរើសភាគសំណាក

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ គឺអ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកសិស្សនៅកម្រិត

មធ្យមសិក្សាទុតិយភូមិចំនួន៤០០នាក់មកពីវិទ្យាល័យចំនួន៤ ដែលនៅក្នុងខេត្តបន្ទាយមានជ័យក្នុងចំណោមសិស្សសរុបចំនួន៤០០នាក់ និងគ្រូប្រឹក្សាអាជីពដែលបានបង្រៀននៅក្នុងសាលាគោលដៅចំនួន៤សាលា ចំនួន១២នាក់ និងនាយកសាលាចំនួន១២នាក់នៅក្នុងក្រុង ស្រុកខុសៗគ្នា។ មូលហេតុដែលអ្នកស្រាវជ្រាវសម្រេចចិត្តជ្រើសរើសវិទ្យាល័យទាំងនោះសម្រាប់ធ្វើការស្រាវជ្រាវដោយសារសាលាទាំងនោះស្ថិតនៅតំបន់ផ្សេងៗគ្នា និងវិទ្យាល័យ២នៅតាមជនបទ។

### ៣.៣-ឧបករណ៍ស្រាវជ្រាវ

ឧបករណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើ គឺអ្នកស្រាវជ្រាវបានដកស្រង់កម្រងសំណួរជ្រើសរើសចំនួន៦ផ្នែកដែលមានសរុប៥៤សំណួរ។ នៅក្នុងការបង្កើតកម្រងសំណួរនេះ គឺអ្នកស្រាវជ្រាវធ្វើការរៀបចំដោយផ្អែកលើសំណួរស្រាវជ្រាវ និងវត្ថុបំណងក្រោមការត្រួតពិនិត្យផ្ទាល់ពីសាស្ត្រាចារ្យដឹកនាំបង្គោល និងសាស្ត្រាចារ្យដឹកនាំរង។ ដើម្បីមានភាពងាយស្រួលនៅក្នុងការប្រមូលទិន្នន័យ និងបានលទ្ធផលជាក់លាក់។ អ្នកសិក្សាស្រាវជ្រាវបានបង្កើតទម្រង់កម្រងសំណួរស្រាវជ្រាវសម្រាប់នាយកសាលា លោកគ្រូ អ្នកគ្រូ សិស្សមធ្យមសិក្សាទុតិយភូមិចែកចេញជាពីរផ្នែកគឺៈ ព័ត៌មានទូទៅ និងកម្រងសំណួរជ្រើសរើស។

ផ្នែកទី១ៈអំពីព័ត៌មានទូទៅចែកចេញជា៥ចំណុចគឺ (១)ឈ្មោះខេត្ត (២)ឈ្មោះស្រុក (៣)ឈ្មោះសាលា (៤)ថ្នាក់ទីនិង(៥)ភេទ។

ផ្នែកទី២ៈជាកម្រងសំណួរជ្រើសរើសដែលមានចំនួន៥៤ និងតម្រូវឱ្យនាយក គ្រូ សិស្សជ្រើសរើសតាមការណែនាំអំពីអ្វីដែលត្រូវតាមចំណេះដឹងនិងព័ត៌មានដែលពួកគាត់ដឹងដោយគូសសញ្ញា(✓) លើចំណុចដែលជាចម្លើយតាមកម្រិតនៃសកម្មភាពនីមួយៗ ពី(១)ដល់(៥)មិនយល់ស្របទាល់តែសោះ មិនយល់ស្រប ពុំមានយោបល់ យល់ស្រប យល់ស្របខ្លាំង។ ទន្ទឹមនឹងនេះផងដែរ ដើម្បីបង្ហាញពីភាពជឿជាក់និងអាចយកជាការបានអ្នកស្រាវជ្រាវក៏បានបង្កើតតេស្តជ្រើសរើសដែលមាន១១ចំណុច សម្រាប់ឱ្យសិស្សធ្វើការជ្រើសរើសយកចម្លើយត្រឹមត្រូវតែមួយគត់នៅក្នុងមួយចំណុចៗ។

### ៣.៤-ដំណើរការប្រមូលទិន្នន័យ

បន្ទាប់ពីកម្រងសំណួរមានការឯកភាពពីគ្រូដឹកនាំ និងទទួលបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំលេខៈ១៧២ វជអ.ផក ចុះថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ

ឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅតាមរាជធានី ខេត្តនានា និងលិខិតជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខៈ៦៥៥ អយក វដអ ចុះថ្ងៃសុក្រ ១២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការស្នើទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តនានា សុំជួយសម្រួលដល់ការចុះស្រាវជ្រាវប្រមូលទិន្នន័យ នៅតាមរាជធានី ខេត្តនានា។ មូលហេតុនៃការស្នើសុំទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ ដោយសារសាលាគោលដៅទាំង៤ ដែលត្រូវមកធ្វើការស្រាវជ្រាវទាំងនេះ ស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ។ បន្ទាប់ពីទទួលបានការឆ្លើយតបពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ តាមរយៈលិខិតឧទ្ទេសនាមលេខៈ ៦៥៥ ចុះថ្ងៃសុក្រ ១២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការសម្រួលដល់ការចុះប្រមូលទិន្នន័យនៅតាមក្រុង ស្រុកគោលដៅ នានា ក្នុងខេត្តបន្ទាយមានជ័យមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំផែនការ ដោយធ្វើការទំនាក់ទំនងទៅសាលាគោលដៅដោយផ្ទាល់ ដើម្បីជួបពិភាក្សាជាមួយនាយកសាលា ក្នុងគោលបំណងកំណត់កាលបរិច្ឆេទជួបសិស្ស ដើម្បីបំពេញកម្រងសំណួរដែលបានត្រៀមទុកជាមុន ធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ដល់ការបង្រៀន និងការរៀនរបស់សិស្ស។ ដំណើរការទាំងមូលបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលាអំពី គោលបំណង និងផែនការទាំងមូលនៃការស្រាវជ្រាវ។ នាយកបានពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាក្នុងកិច្ចការស្រាវជ្រាវ រួចគាត់ក៏បានអនុញ្ញាតឱ្យរៀបចំការប្រមូលទិន្នន័យទៅតាមផែនការដែលបានឯកភាពគ្នា។

ការចុះប្រមូលទិន្នន័យជាផ្លូវការ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសាកល្បងកម្រងសំណួរទាំងអស់នៅសាលាមួយក្នុងខេត្តបន្ទាយមានជ័យ។គោលបំណងនៃការសាកល្បងកម្រងសំណួរនេះគឺដើម្បីធានាអំពីប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរដើម្បីឱ្យដឹងថាអាចយកមកប្រមូលទិន្នន័យជាផ្លូវការបាន ឬមិនបាន។ ក្រោយពីបានសាកល្បងលើកម្រងសំណួរទាំងនេះ អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ការសាកល្បងនេះពិតជាទទួលបានលទ្ធផលល្អមែនព្រោះពេលយើងរកឃើញចំណុចខ្វះខាតមួយចំនួនរបស់កម្រងសំណួរ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវក៏យកបញ្ហាទាំងនោះទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំ ដើម្បីទទួលបានយោបល់ត្រឹមត្រូវក្នុងការកែលម្អ កម្រងសំណួរឡើងវិញ។ ក្រោយពីការណែនាំកែលម្អ និងឯកភាពពីសាស្ត្រាចារ្យដឹកនាំរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្តើមចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅទាំង៤ក្នុងក្រុងសិរីសោភ័ណ ស្រុកមង្គលបូរី និងស្រុកអូរជ្រៅ។ មុននឹងដាក់ឱ្យជ្រើសរើសនូវចំណុចនីមួយៗ អ្នកស្រាវជ្រាវបានធ្វើការណែនាំពីរបៀបគូសសញ្ញាជ្រើសរើសក្នុងប្រអប់ដែលត្រូវនឹង

សកម្មភាពសិក្សារបស់សិស្ស ហើយការធ្វើកម្រងសំណួរនេះមានរយៈពេលចន្លោះពី៣០ទៅ៤៥នាទី។

## ៣.៥-ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាដំបូងត្រូវវិភាគដាច់។ ដោយឡែកទៅតាមប្រភេទសំណាកនីមួយៗ (នាយក គ្រូនិងសិស្ស) ។ អ្នកសិក្សាស្រាវជ្រាវបានប្រើកម្មវិធីកុំព្យូទ័រសម្រាប់ការស្រាវជ្រាវ សម្រាប់ការវិភាគទិន្នន័យដោយប្រើស្ថិតិដូចខាងក្រោម៖

១.ស្ថិតិមូលដ្ឋានដែលប្រើរកស្ថានភាពរបស់អ្នកឆ្លើយក្នុងកម្រងសំណួរ វិភាគដោយប្រើ Descriptives ។

២.ស្ថិតិដែលប្រើវិភាគកម្រងសំណួរអំពីលក្ខណៈសម្បត្តិរបស់គ្រូប្រឹក្សាអាជីពវិភាគ ដោយប្រើMean និង Standard Deviation ។

## ៣.៦-ក្រមសីលធម៌នៃការស្រាវជ្រាវ

ការប្រកាន់ខ្ជាប់នូវសីលធម៌មានសារៈសំខាន់ណាស់ សម្រាប់អ្នកស្រាវជ្រាវក្នុងការធានាប្រសិទ្ធភាពនៃការស្រាវជ្រាវក៏ដូចការបង្កើនទំនុកចិត្ត និងជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយក៏ដូចជាទិន្នន័យផ្សេងៗ សម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ។ ការព្រមព្រៀងគ្នារវាងអ្នកផ្តល់ចូលរួមធ្វើកម្រងសំណួរនិងអ្នកដែលស្វែងរកប្រភពព័ត៌មានច្បាស់លាស់និងមានប្រសិទ្ធភាព ហើយអាចយកមកប្រើការបានសម្រាប់ធ្វើការវិភាគឱ្យស៊ីជម្រៅ។ អត្តសញ្ញាណអ្នកផ្តល់ចម្លើយត្រូវបានរក្សាជាការសម្ងាត់លើកលែងតែឈ្មោះសាលារៀន ដែលត្រូវបង្ហាញក៏មានការឯកភាពពីនាយកសាលាគោលដៅនីមួយៗ ដែលអ្នកសិក្សាស្រាវជ្រាវបាននាំយកនូវលិខិតអនុញ្ញាតទៅជាមួយហើយសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធដោយចាប់ផ្តើមមុនពេលបំពេញកម្រងសំណួរ។ ការចូលរួមសហការរបស់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូក្នុងការផ្តល់ឱកាសឱ្យអ្នកស្រាវជ្រាវចុះធ្វើកម្រងសំណួរតាមថ្នាក់មានន័យថា អ្នកពាក់ព័ន្ធទាំងនោះត្រូវយល់ដឹងពីគោលបំណងនៃការស្រាវជ្រាវជាមុន ហើយអ្នកស្រាវជ្រាវក៏រំពឹងទុកផងដែរនឹងទទួលបានចម្លើយឬព័ត៌មានដែលពិត។ ការធ្វើដូច្នេះនាំឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងបញ្ជាក់ពីការចុះទៅប្រមូលព័ត៌មានឬទិន្នន័យរបស់ខ្លួនដោយស្របច្បាប់។

# ជំពូកទី៤

# លទ្ធផលនៃការស្រាវជ្រាវនិងការពិភាក្សា

## ៤.១-របៀបនៃការបង្ហាញព័ត៌មាន

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការបកស្រាយបង្ហាញ និងវិភាគទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ និងការធ្វើតេស្តលើចំណេះដឹងលើខ្លឹមសារប្រឹក្សាដើម្បីឱ្យដឹងថា តើគ្រូប្រឹក្សាបានអនុវត្តការងាររបស់គាត់បានត្រឹមត្រូវកម្រិតណា និងបញ្ហាប្រឈមក្នុងការបង្រៀនមុខវិជ្ជាប្រឹក្សាអាជីពនេះ។

នៅក្នុងផ្នែកទី១នេះ អ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការអនុវត្តការបង្រៀនរបស់គ្រូចំពោះសិស្សនៅមធ្យមសិក្សាទុតិយភូមិនៅខេត្តបន្ទាយមានជ័យ។ ដោយឡែក ចំនួនគ្រូដែលត្រូវសម្ភាសន៍មាន១២នាក់ ស្រី៨នាក់ នាយកចំនួន១២នាក់ ស្រី៤នាក់ និងសិស្សចំនួន១២០នាក់ ស្រី៧៦នាក់មកពីវិទ្យាល័យចំនួន៤ នៅក្នុងស្រុកនិងក្រុងខេត្តបន្ទាយមានជ័យ។

តាមរយៈកម្រងសំណួរជ្រើសរើសដែលមាន៥៤ចំណុច បែងចែកជា២ផ្នែក ដែលផ្នែកទី១ (មាន៦ចំណុចចាប់ពី«ក»ការបែងចែកនិងការអនុវត្តការងារបង្រៀនមាន១០ចំណុច«ខ»។ ការកសាងសមត្ថភាពគ្រូមាន៩ចំណុច«គ» ការកសាងសមត្ថភាពសិស្សមាន៦ចំណុច «ឃ»បញ្ហាប្រឈមមាន៥ចំណុច«ង»ដំណោះស្រាយមាន៦ចំណុចនិង«ច»ការពង្រឹងការអនុវត្តការងារ និងផ្នែកទី២ការស៊ើជំរៅលើខ្លឹមសារប្រឹក្សាអាជីព (មាន១១សំណួរ)។

ស្ថិតិដែលប្រើវិភាគមានមធ្យម(Mean) គម្លាតស្តង់ដា(Standard deviation) ដើម្បីបង្ហាញឱ្យឃើញនូវកម្រិតនៃការអនុវត្តការងាររបស់នាយក គ្រូ សិស្ស។ យោងតាមការបែងចែកកម្រិតដែលចងក្រងដោយ oxford និង Burry-Stock(1995)។ កម្រិតមធ្យមត្រូវបានគេបែងចែកជាបីក្រុម គឺកម្រិតខ្ពស់(M=3.50ឡើង) កម្រិតមធ្យម(M=2.50 -3.49)កម្រិតទាប(M=2.49ចុះ) ។ គម្លាតស្តង់ដាគេប្រើវាដើម្បីចង់ដឹងពីចន្លោះឬការឃ្លាតគ្នាពីមួយទៅមួយហើយវាជាក្បួនខ្នាតគម្រូមានលក្ខណៈសមស្របជាក់ស្តែង បើយើងរកឃើញតម្លៃមធ្យមដូចគ្នាហើយយើងចង់ដឹងថាមួយណាមានកម្រិតល្អជាងយើងមើលទៅលើគម្លាតស្តង់ដា កាលណាគម្លាតស្តង់ដាកាន់តែតូចលទ្ធផលវាកាន់តែល្អ។

ផ្នែកទី២៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិតនៃការអនុវត្តការងារនិងចំណេះដឹងលើខ្លឹមសារស៊ីជម្រៅលើមេរៀនប្រឹក្សាអាជីព។

## ៤.២-លទ្ធផលនៃការស្រាវជ្រាវ

**ផ្នែកទីI**

នៅក្នុងផ្នែកនេះមានបង្ហាញព័ត៌មានទូទៅរបស់គ្រូ នាយក សិស្សដែលជាសំណាកស្រាវជ្រាវទាំងអស់ជាព័ត៌មានលម្អិតអំពីភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍ជាគណៈគ្រប់គ្រង ជាគ្រូ មានដូចខាងក្រោមៈ

**តារាងទីIៈ ព័ត៌មានទូទៅរបស់នាយក**

**តារាងទី១ៈ សាលា**

| ឈ្មោះសាលា | ភាពញឹកញាប់គិតជាភាគរយ |
|---|---|
| វិទ្យាល័យអូរអំបិល | 3 |
| វិទ្យាល័យសម្តេចឪ | 3 |
| វិទ្យាល័យកូប | 3 |
| វិទ្យាល័យរោងគោ | 3 |
| សរុប | 12 |

តារាងទី១បានបង្ហាញថា គណៈគ្រប់គ្រងមកពីវិទ្យាល័យទាំង៤ រួមមាន (វិទ្យាល័យអូរអំបិល វិទ្យាល័យសម្តេចឪ វិទ្យាល័យកូប និងវិទ្យាល័យរោងគោ) មានចំនួន៣នាក់ដូចគ្នាស្មើនឹង២៥%។

**តារាងទី២ៈ ភេទ**

| ភេទ | ភាពញឹកញាប់គិតជាភាគរយ |
|---|---|
| ប្រុស | 9 |
| ស្រី | 3 |
| សរុប | 12 |

តារាងទី២បានបង្ហាញថា គណៈគ្រប់គ្រងប្រុសមានចំនួន៩នាក់ស្មើនឹង៧៥% ច្រើនជាងគណៈគ្រប់គ្រងស្រីមានចំនួន៣នាក់ស្មើនឹង២៥%ប៉ុណ្ណោះ។

**តារាងទី៣៖ អាយុ**

| **អាយុ** | ភាពញឹកញាប់គិតជាភាគរយ |
|---|---|
| 25-30ឆ្នាំ | 1 |
| 36-40ឆ្នាំ | 2 |
| លើសពី40ឆ្នាំ | 9 |
| សរុប | 12 |

តារាងទី៣បានបង្ហាញថា គណៈគ្រប់គ្រងអាយុ២៥ទៅ៣០ឆ្នាំចំនួន១នាក់ស្មើ៨%តិចជាងគេ។គណៈគ្រប់គ្រងអាយុ៣៦ទៅ៤០ឆ្នាំចំនួន២នាក់ស្មើ១៧% តិចជាងគណៈគ្រប់គ្រងអាយុលើសពី៤០ឆ្នាំគឺ៩នាក់ស្មើ៧៥%។

**តារាងទី៤៖ កម្រិតវប្បធម៌**

| **សញ្ញាបត្រ** | ភាពញឹកញាប់គិតជាភាគរយ |
|---|---|
| សញ្ញាបត្រទុតិយភូមិ | 2 |
| បរិញ្ញាបត្រ | 10 |
| សរុប | 12 |

តារាងទី៤បានបង្ហាញថា គណៈគ្រប់គ្រងមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួន២នាក់ស្មើនឹង ១៧% តិចជាងគណៈគ្រប់គ្រងដែលមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន១០នាក់ស្មើនឹង៨៣%។

**តារាងទី៥៖ ជំនាញឯកទេស**

| **មុខវិជ្ជា** | ភាពញឹកញាប់គិតជាភាគរយ |
|---|---|
| គណិតវិទ្យា | 2 |
| ភាសាខ្មែរ | 5 |
| គីមីវិទ្យា | 2 |
| ភូមិវិទ្យា | 1 |
| សីលធម៌ | 1 |
| ជីវវិទ្យា | 1 |
| សរុប | 12 |

តារាងទី៥បានបង្ហាញថា ក្នុងចំណោមគណៈគ្រប់គ្រងទាំង១២ ឯកទេសដើមដែលមានភាគរយច្រើនជាងគេគឺឯកទេសភាសាខ្មែរ មានចំនួន៥នាក់ស្មើនឹង៤២%។ ចំណែកឯកទេសភូមិវិទ្យា សីលធម៌ និង ជីវវិទ្យាមានចំនួន១នាក់ស្មើៗគ្នាមាន៨%។ ឯកទេសគីមីវិទ្យាវិញ មានចំនួន២នាក់ ស្មើនឹងឯកទេសគណិតវិទ្យាចំនួន១៧%។

**តារាងទី៦៖បទពិសោ ធន៍បង្រៀនរបស់គ្រូ**

| **ចំនួនឆ្នាំ** | ភាពញឹកញាប់គិតជាភាគរយ |
|---|---|
| លើសពី១៥ឆ្នាំ | 12 |

តារាងទី៦បានបង្ហាញថា គណៈគ្រប់គ្រងមានបទពិសោធន៍បង្រៀនលើស១៥ឆ្នាំ១២នាក់ស្មើ១០០%។

**តារាងទី៧៖ ភាសា**

| ភាសា | ភាពញឹកញាប់គិតជាភាគរយ |
|---|---|
| អង់គ្លេស | 12 |

តារាងទី៧បានបង្ហាញថា គណៈគ្រប់គ្រងចំនួន១២នាក់ប្រើប្រាស់ភាសាអង់គ្លេសស្មើនឹង១០០%។

**តារាងទីII៖ ព័ត៌មានទូទៅរបស់សិស្ស**

**តារាងទី៨៖ ទីកន្លែង**

| ឈ្មោះសាលា | ញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| វិទ្យាល័យអូរអំបិល | 30 | 25 |
| វិទ្យាល័យសម្តេចឪ | 30 | 25 |
| វិទ្យាល័យកូប | 30 | 25 |
| វិទ្យាល័យពោងគោ | 30 | 25 |
| សរុប | 120 | 100 |

តារាងទី៨បានបង្ហាញថា សិស្សសរុបចំនួន១២០នាក់ដែលចែកជា៤វិទ្យាល័យរួមមាន វិទ្យាល័យអូរអំបិល វិទ្យាល័យសម្តេចឪ វិទ្យាល័យកូប និងវិទ្យាល័យពោងគោមានភាគរយស្មើគ្នាគឺ២៥%ដូចគ្នា។

**តារាងទី៩៖ ភេទ**

| ភេទ | ភាពញឹកញាប់នៃភាគរយ | ភាគរយ |
|---|---|---|
| ប្រុស | 44 | 36.7 |
| ស្រី | 76 | 63.3 |
| សរុប | 120 | 100 |

តារាងទី៩បានបង្ហាញថា សិស្សប្រុស៤៤នាក់ស្មើ៣៦.៧% តិចជាងសិស្សស្រី៧៦នាក់ស្មើ៦៣.៣%។

**តារាងទី១០៖ អាយុ**

| **អាយុ** | ភាគរយនៃភាពញឹកញាប់ | **ភាគរយ** |
|---|---|---|
| 12-14ឆ្នាំ | 8 | 6.7 |
| 15-16ឆ្នាំ | 32 | 26.7 |
| 17-18ឆ្នាំ | 66 | 55 |
| លើសពី18ឆ្នាំ | 14 | 11.7 |
| សរុប | 120 | 100 |

តារាងទី១០បានបង្ហាញថា សិស្សមានអាយុ១២ឆ្នាំទៅ១៤ឆ្នាំមានចំនួន៨នាក់ស្មើនឹង៦.៧% តិចជាងសិស្សអាយុ១៥ឆ្នាំទៅ១៦ឆ្នាំចំនួន៣២នាក់ស្មើនឹង២៦.៧% ហើយសិស្សអាយុ១៧ឆ្នាំទៅ១៨ឆ្នាំចំនួន៦៦នាក់ស្មើនឹង៥៥% ច្រើនជាងសិស្សដែលមានអាយុលើសពី១៨ឆ្នាំចំនួន១៤នាក់ស្មើនឹង១១.៧%។

**តារាងទី១១៖ បណ្តុំមុខវិជ្ជា សិស្ស**

| មុខវិជ្ជា | ភាគរយនៃភាពញឹកញាប់ | ភាគរយ |
|---|---|---|
| វិទ្យាសាស្ត្រ | 89 | 74.2 |
| សង្គម | 31 | 25.8 |
| សរុប | 120 | 100 |

តារាងទី១១បានបង្ហាញថា សិស្សដែលជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រមានចំនួន៨៩នាក់ស្មើនឹង៧៤.២% ច្រើនជាងសិស្សជ្រើសរើសមុខវិជ្ជាសង្គមមានចំនួន៣១នាក់ស្មើនឹង២៥.៨%។

**តារាងទី១២៖ ភាសា**

| | Frequency | ភាគរយ |
|---|---|---|
| អង់គ្លេស | 120 | 100 |

តារាងទី១២បានបង្ហាញថា សិស្សជ្រើសរើសមុខវិជ្ជាភាសាអង់គ្លេសចំនួន១២០នាក់ ស្មើនឹង១០០%។

**តារាងទីIII៖ ព័ត៌មានទូទៅរបស់គ្រូប្រឹក្សា**

**តារាងទី១៣៖ តួនាទី**

| នាទី | ភាពញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| គ្រូបន្ទប់ | 7 | 58.3 |
| គ្រូមិនកាន់បន្ទប់ | 5 | 41.7 |
| សរុប | 12 | 100 |

តារាងទី១៣បានបង្ហាញថា គ្រូបន្ទប់មានចំនួន៧នាក់ស្មើ៥៨.៣% ច្រើនជាងគ្រូមិនកាន់បន្ទប់៥នាក់ស្មើ៤១.៧%។

**តារាងទី១៤៖ ភេទ**

| **ភេទ** | ញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| ប្រុស | 4 | 33.3 |
| ស្រី | 8 | 66.7 |
| សរុប | 12 | 100 |

តារាងទី១៤បានបង្ហាញថា គ្រូប្រុសមាន៤នាក់ស្មើនឹង៣៣.៣% តិចជាងគ្រូស្រី៨នាក់ស្មើនឹង៦៦.៧%។

**តារាងទី១៥៖ ឈ្មោះសាលា/តំបន់**

| | ញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| សាលាទីប្រជុំជន(អូរអំបិល) | 3 | 25 |
| សាលាទីប្រជុំជន (សម្តេចឪ) | 3 | 25 |
| សាលានៅតំបន់ជនបទ (កូប) | 3 | 25 |
| សាលាជនបទ(រោងគោ) | 3 | 25 |
| សរុប | 12 | 100 |

តារាងទី១៥បានបង្ហាញថា ភាគរយវិទ្យាល័យទាំង៤មានចំនួនស្មើគ្នាគឺសាលាក្នុងទីប្រជុំជននិងសាលានៅតំបន់ជនបទគឺ២៥%ដូចគ្នា។

**តារាងទី១៦៖ អាយុ**

| **អាយុ** | ញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| 25-30ឆ្នាំ | 2 | 16.7 |
| 31-35ឆ្នាំ | 1 | 8.3 |
| 36-40ឆ្នាំ | 6 | 50 |
| លើសពី40ឆ្នាំ | 3 | 25 |
| សរុប | 12 | 100 |

តារាងទី១៦បានបង្ហាញថា គ្រូមានអាយុចន្លោះ២៥ឆ្នាំទៅ៣០ឆ្នាំមានចំនួន២នាក់ស្មើនឹង១៦.៧% ច្រើនជាងគ្រូមានអាយុ៣១ឆ្នាំទៅ៣៥ឆ្នាំចំនួន១នាក់ស្មើនឹង៨.៣% ហើយគ្រូមានអាយុ៣៦ឆ្នាំទៅ៤០ឆ្នាំចំនួន៦នាក់ស្មើនឹង៥០% ច្រើនជាងគ្រូមានអាយុលើសពី៤០ឆ្នាំចំនួន៣នាក់ស្មើនឹង២៥%។

**តារាងទី១៧៖ កម្រិតវប្បធម៌ គ្រូ**

| **សញ្ញាបត្រ** | ញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| បាក់ឌុប | 1 | 8.3 |
| បរិញ្ញាបត្រ | 5 | 41.7 |
| បរិញ្ញាបត្រជាន់ខ្ពស់ | 6 | 50 |
| បណ្ឌិត | 0 | 0 |
| សរុប | 12 | 100 |

តារាងទី១៧បានបង្ហាញថា គ្រូដែលមានសញ្ញាបត្របាក់ឌុបចំនួន១នាក់ស្មើនឹង៨.៣% តិចជាងគ្រូមានបរិញ្ញាបត្រមានចំនួន៥នាក់ស្មើនឹង៤១.៧% ហើយតិចជាងគ្រូមានបរិញ្ញាបត្រជាន់ខ្ពស់ចំនួន៦នាក់ស្មើនឹង៥០%។ ចំណែកគ្រូដែលមានសញ្ញាបត្របណ្ឌិតមិនមានទេ។

**តារាងទី១៨៖ ជំនាញឯកទេស ដើមរបស់គ្រូ**

| **មុខវិជ្ជា** | ញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| ខ្មែរ | 4 | 33.3 |
| គីមីវិទ្យា | 1 | 8.3 |
| ភូមិវិទ្យា | 4 | 33.3 |
| ជីវវិទ្យា | 3 | 25 |
| សរុប | 12 | 100 |

តារាងទី១៨បានបង្ហាញថា នៅក្នុងចំណោមគ្រូ៤នាក់ស្មើនឹង៣៣.៣% មានឯកទេសដើមភាសាខ្មែរច្រើនជាងគ្រូឯកទេសដើមគីមីវិទ្យាចំនួន១នាក់ស្មើនឹង៨.៣%។ ចំណែកគ្រូឯកទេសដើមភូមិវិទ្យាមានចំនួន៤នាក់ស្មើនឹង៣៣.៣% ច្រើនជាងគ្រូឯកទេសដើមជីវវិទ្យាមានចំនួន៣នាក់ស្មើនឹង២៥%ប៉ុណ្ណោះ។

**តារាងទី១៩៖ ភាសា**

| **ភាសាបរទេស** | ញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| អង់គ្លេស | 12 | 100 |

តារាងទី១៩បានបង្ហាញថា គ្រូដែលជ្រើសរើសមុខវិជ្ជាភាសាអង់គ្លេសមានចំនួន១២នាក់ស្មើនឹង១០០%។

**តារាងទី២០៖បទពិសោធន៍ បង្រៀនរបស់គ្រូ**

| **ចំនួនឆ្នាំបម្រើការងារ** | ញឹកញាប់គិតជាភាគរយ | ភាគរយ |
|---|---|---|
| 6-10ឆ្នាំ | 3 | 25 |
| 11-15ឆ្នាំ | 4 | 33.3 |
| លើសពី15ឆ្នាំ | 5 | 41.7 |
| សរុប | 12 | 100 |

តារាងទី២០បានបង្ហាញថា គ្រូដែលបង្រៀនចាប់ពី៦ទៅ១០ឆ្នាំមានចំនួន៣នាក់ស្មើនឹង២៥% តិចជាងគ្រូដែលបង្រៀនបាន១១ឆ្នាំទៅ១៥ឆ្នាំចំនួន៤នាក់ស្មើនឹង៣៣.៣% ហើយតិចជាងគ្រូដែលបង្រៀនលើស១៥ឆ្នាំមានចំនួន៥នាក់ស្មើនឹង៤១.៧%។

ផ្នែកទីII

តារាងទី១៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យនៃប្រសិទ្ធភាពសម្រាប់ការអនុវត្តការងារប្រឹក្សាអាជីពលើសិស្សរបស់គ្រូនៅមធ្យមសិក្សាទុតិយភូមិ(N =12) ព័ត៌មានពីគ្រូប្រឹក្សាអាជីព

| ល.រ | ខ្លឹមសារ | កម្រិត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ក.ការបែងចែកនិងអនុវត្តការងារបង្រៀន | | | | |
| ១ | ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូមានរៀបចំកិច្ចតែងការបានល្អ។ | 3.83 | 0.72 | ខ្ពស់បង្គួរ |
| ២ | គ្រូបង្រៀនមេរៀនបានទាន់កម្មវិធីសិក្សា។ | 3.50 | 1.00 | ខ្ពស់បង្គួរ |
| ៣ | បានអនុវត្តការងារឆ្លើយតបទៅតាមតម្រូវការសិស្ស។ | 3.83 | 0.72 | ខ្ពស់បង្គួរ |
| ៤ | មានផ្តល់ប្រឹក្សាឱ្យសិស្សជាបុគ្គល និងជាក្រុម។ | 4.17 | 0.58 | ខ្ពស់ |
| ៥ | រៀបចំល្បែងសិក្សា ដើម្បីទាញចំណាប់អារម្មណ៍សិស្ស។ | 3.67 | 0.65 | ខ្ពស់បង្គួរ |
| ៦ | គ្រូបានរៀបចំសម្ភារឧបទ្ទេសសម្រាប់បង្រៀនប្រឹក្សាអាជីពបានត្រឹមត្រូវ | 3.75 | 0.87 | ខ្ពស់បង្គួរ |
| ៧ | យល់ដឹងពីខ្លឹមសារ និងសកម្មភាពក្នុងមេរៀនប្រឹក្សាអាជីពបានច្បាស់។ | 3.67 | 0.89 | ខ្ពស់បង្គួរ |
| ៨ | មានផែនការក្នុងការដោះស្រាយបញ្ហាប្រឈមរបស់សិស្ស។ | 3.92 | 0.51 | ខ្ពស់បង្គួរ |
| ៩ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ក្នុងការប្រឹក្សាអាជីព។ | 4.08 | 0.90 | ខ្ពស់ |
| ១០ | មុខវិជ្ជាប្រឹក្សាអាជីពជួយអភិវឌ្ឍការសិក្សារបស់សិស្ស។ | 4.25 | 0.62 | ខ្ពស់ |
| សរុប | | 3.42 | 0.74 | មធ្យម |

តារាងទី១បានបង្ហាញថា គ្រូអនុវត្តការងារបង្រៀនរបស់ខ្លួនផ្នែកកម្រិតខ្ពស់ ចាប់ពី3.67រហូតដល់4.25 មានន័យថាគ្រូបានរៀបចំកិច្ចតែងការ និងបង្រៀនតាមតម្រូវការរបស់សិស្សមានកម្រិត(M=3.83) ចំណុចខ្ពស់ជាងគេគឺមានការផ្តល់ប្រឹក្សាឱ្យសិស្សជាបុគ្គលនិងជាក្រុមនិងការឯកភាពថាប្រឹក្សាអាជីពជួយអភិវឌ្ឍន៍ការសិក្សារបស់សិស្ស។ នៅក្នុងចំណោមទាំង១០ចំណុចដែលបានទទួលលទ្ធផលទាបជាងគេ(M=3.5) គឺការបង្រៀនមេរៀនទាន់កម្មវិធី។

**តារាងទី២៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យនៃការកសាងសមត្ថភាព**

| | | | | |
|---|---|---|---|---|
| | **ខ.ការកសាងសមត្ថភាព** | | | |
| ១ | បានទៅទទួលការបណ្តុះបណ្តាលដើម្បីអភិវឌ្ឍគុណភាព និងសមត្ថភាពជំនាញប្រឹក្សាអាជីព។ | 4.33 | 0.49 | ខ្ពស់ |
| ២ | មានការពិភាក្សាគ្នាជាមួយគ្រូដទៃ ដើម្បីដោះស្រាយបញ្ហាប្រឈម។ | 3.83 | 0.83 | ខ្ពស់បង្គួរ |
| ៣ | មានការលើកទឹកចិត្តពីនាយកសាលាបានច្រើន។ | 3.67 | 0.98 | ខ្ពស់បង្គួរ |
| ៤ | បានរៀបចំការប្រជុំបច្ចេកទេសលើមុខវិជ្ជាប្រឹក្សារៀងរាល់ខែ។ | 3.17 | 0.72 | មធ្យម |
| ៥ | មានការលើកទឹកចិត្តសិស្សជាប្រចាំ។ | 4.00 | 0.85 | ខ្ពស់ |
| ៦ | គ្រូបានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា។ | 3.83 | 1.03 | ខ្ពស់បង្គួរ |
| ៧ | បានរៀបចំកិច្ចតែងការបង្រៀនជាប្រចាំ។ | 3.58 | 0.79 | ខ្ពស់បង្គួរ |
| ៨ | សិស្សអាចកសាងផែនការអាជីព និងសហគ្រិនភាពបាន។ | 3.17 | 0.83 | មធ្យម |
| ៩ | បានប្រើវិធីសាស្ត្រទំនើបៗ និងបង្រៀនដោយច្នៃប្រឌិត។ | 3.42 | 0.79 | មធ្យម |
| សរុប | | 3.66 | 0.73 | ខ្ពស់បង្គួរ |

តារាងទី២បានបង្ហាញថា ការកសាងសមត្ថភាពរបស់ខ្លួននៅកម្រិតមធ្យមរហូតដល់កម្រិតខ្ពស់ ចាប់ពី3.66ដល់4.33 នេះមានន័យថា គ្រូបង្រៀនបានរៀបចំកិច្ចតែងការបង្រៀន(M=៣.៥៨)។ បន្ទាប់ទៀតការលើកទឹកចិត្តពីនាយកនិងការបង្រៀនតាមការបែងចែកកាលវិភាគ។ តារាងបានបង្ហាញពីចំណុចទាបបំផុត3.17 ត្រង់ចំណុចសិស្សអាចកសាងផែនការអាជីព និងសហគ្រិនភាពបាន និងការប្រជុំបច្ចេកទេសរៀងរាល់ខែ។ ចំណុចដែលខ្ពស់នៅក្នុងការកសាងសមត្ថភាពគឺបានទទួលការបណ្តុះបណ្តាល ពីការអភិវឌ្ឍសមត្ថភាពនៃការប្រឹក្សាអាជីព និងជំនាញស្របគ្នានិងការលើកទឹកចិត្តសិស្សជាប្រចាំ។

**តារាងទី៣៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យនៃការកសាងសមត្ថភាពគ្រូ**

| | **គ.ការកសាងសមត្ថភាពគ្រូ** | | | |
|---|---|---|---|---|
| ១ | បានផ្តល់ឱកាសដល់សិស្សអភិវឌ្ឍចំណុចខ្សោយរបស់គេ។ | 3.67 | 0.49 | ខ្ពស់ |
| ២ | សិស្សមានទំនាក់ទំនងជាមួយខ្លួនយ៉ាងជិតស្និទ្ធ។ | 4.08 | 0.67 | ខ្ពស់ |
| ៣ | បានផ្តល់សេវាប្រឹក្សាអាជីពដល់សិស្ស។ | 4.00 | 0.74 | ខ្ពស់ |
| ៤ | រក្សាការសម្ងាត់របស់សិស្ស។ | 4.17 | 0.72 | ខ្ពស់ |
| ៥ | សិស្សមានការអភិវឌ្ឍចំណុចខ្លាំង និងជំនាញទំនាក់ទំនង។ | 3.67 | 0.49 | ខ្ពស់ |
| ៦ | មានការពេញចិត្តចែករំលែកពីបទពិសោធន៍នៃរបៀបជោគជ័យ។ | 4.00 | 0.60 | ខ្ពស់ |
| | សរុប | 3.80 | 0.78 | ខ្ពស់ |

តារាងទី៣បានបង្ហាញថា ការកសាងសមត្ថភាពគ្រូគឺចំណុចដែលបានខ្ពស់ប្រហាក់ប្រហែលគ្នា គឺធ្វើឱ្យសិស្សមានទំនាក់ទំនងល្អជាមួយគ្នា។ គ្រូនិងការផ្តល់សេវាប្រឹក្សាដល់សិស្ស និងការចែករំលែកបទពិសោធន៍ជោគជ័យ(M=4)។ បន្ទាប់មកទៀតចំណុចទី១និងចំណុចទី៥(M=3.67)ស្មើគ្នា។ សរុបមក ការកសាងសមត្ថភាពគ្រូមានកម្រិតល្អ។

**តារាងទី៤៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យនៃបញ្ហាប្រឈមរបស់គ្រូ**

| | **ឃ.បញ្ហាប្រឈមរបស់គ្រូ** | | | |
|---|---|---|---|---|
| ១ | សិស្សមិនមានភាពច្បាស់លាស់នៅជម្រើសអាជីព។ | 3.75 | 1.05 | ខ្ពស់ |
| ២ | ខ្វះការជំរុញពីភាគីពាក់ព័ន្ធដែលមានឥទ្ធិពលលើអាជីពរបស់សិស្ស។ | 3.58 | 1.00 | ខ្ពស់ |
| ៣ | ខ្វះព័ត៌មានអប់រំ និងសេវាប្រឹក្សាអាជីពញឹកញាប់។ | 3.67 | 0.65 | ខ្ពស់ |
| ៤ | គ្រូនៅមានកម្រិតពីការស្វែងយល់ពីចំណាប់អារម្មណ៍ និងវិធីកាត់បន្ថយសម្ពាធ។ | 3.92 | 0.51 | ខ្ពស់ |
| ៥ | ផ្តល់វគ្គបណ្តុះបណ្តាលជំនាញប្រឹក្សាបានតិចតួច។ | 4.08 | 0.67 | ខ្ពស់ |
| | សរុប | 3.80 | 0.78 | ខ្ពស់ |

តារាងទី៤បានបង្ហាញថា បញ្ហាប្រឈមរបស់គ្រូដែលជួបប្រទះពេលអនុវត្តការងារសិស្សមិនមានភាពច្បាស់លាស់នៅជម្រើសអាជីពបានកម្រិតខ្ពស់(M=3.37) ខ្វះព័ត៌មានអប់រំគឺ(M=3.58)។ចំណែកចំណុចគ្រូស្វែងពីចំណាប់អារម្មណ៍

និងវិធីកាត់បន្ថយសម្ពាធបានកម្រិតខ្ពស់ (M=4.08)។ ចំណុចដែលខ្ពស់លើសគេគឺផ្តល់វគ្គបណ្តុះបណ្តាលបានតិចតួចទទួលបានកម្រិតខ្ពស់(M=4.8)។ សរុបមក ការបញ្ហាប្រឈមរបស់គ្រូគឺមានកម្រិតខ្ពស់(M=3.8)។

**តារាងទី៥៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យដំណោះស្រាយ**

| | **ង.ដំណោះស្រាយ** | | | |
|---|---|---|---|---|
| ១ | អញ្ជើញអតីតនិស្សិតដែលបានជ្រើសរើសអាជីពបានត្រឹមត្រូវមកប្រឹក្សាបន្ថែម។ | 3.17 | 0.94 | មធ្យម |
| ២ | បង្កើនទំនាក់ទំនងជាមួយគ្រូប្រឹក្សាដូចគ្នា និងសិស្សដែលមានបញ្ហា។ | 3.83 | 0.72 | ខ្ពស់ |
| ៣ | តាមដានប្រអប់សំបុត្រចំពោះសិស្សដែលត្រូវការជំនួយ។ | 3.83 | 0.58 | ខ្ពស់ |
| ៤ | ជំរុញឱ្យមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ ដើម្បីជួយសិស្សទាន់ពេលវេលា។ | 3.58 | 0.90 | ខ្ពស់ |
| ៥ | ទទួលកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការប្រឹក្សាអាជីព។ | 3.67 | 0.78 | ខ្ពស់ |
| ៦ | ស្វែងយល់ពីអ្វីដែលជះឥទ្ធិពលលើជម្រើសអាជីពសិស្សបានច្បាស់។ | 3.50 | 0.67 | ខ្ពស់ |
| | សរុប | 3.59 | 0.76 | ខ្ពស់ |

តារាងទី៥បានបង្ហាញថា លទ្ធផលនៃដំណោះស្រាយស្ថិតនៅកម្រិតល្អ(M=3.59) ចំណុចដែលអញ្ជើញអតីតនិស្សិតមកប្រឹក្សាបន្ថែមបានកម្រិតមធ្យម(M=3.17) ហើយការបង្កើនទំនាក់ទំនងជាមួយគ្រូប្រឹក្សាអាជីពនិងសិស្សដែលមានបញ្ហាបានកម្រិតខ្ពស់(M=3.83) ស្មើនឹងការតាមដានប្រអប់សំបុត្រចំពោះសិស្សត្រូវការជំនួយ។ ចំណែកការទទួលកញ្ចប់ថវិកាសម្រាប់ដំណើរការប្រឹក្សាអាជីពគឺបានកម្រិតខ្ពស់(M=3.67)និងចុងក្រោយការស្វែងយល់ចំពោះអ្នកដែលពាក់ព័ន្ធបានជះឥទ្ធិពលលើជម្រើសអាជីពបានកម្រិតខ្ពស់(M=3.5)។

**តារាងទី៦៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យ ការពង្រឹងលើការអនុវត្តការងារ**

| | **ច.ការពង្រឹងលើការអនុវត្តការងារ** | | | |
|---|---|---|---|---|
| ១ | មានការប្រឡងយកពិន្ទុជាប្រចាំលើមុខវិជ្ជាប្រឹក្សា។ | 3.75 | 0.75 | ខ្ពស់បង្គួរ |
| ២ | បានវាយតម្លៃជាប្រចាំលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់សិស្ស។ | 3.50 | 0.67 | ខ្ពស់បង្គួរ |
| ៣ | មានការវាយតម្លៃ និងត្រួតពិនិត្យដំណើរការបង្រៀនរបស់ខ្លួន។ | 3.50 | 0.67 | ខ្ពស់បង្គួរ |
| ៤ | បានរៀបចំវគ្គតម្រង់ទិសអាជីព២ឬ៣ដងក្នុង១ឆ្នាំ។ | 3.92 | 0.79 | ខ្ពស់ |
| ៥ | មានការផ្តល់ព័ត៌មានអប់រំបានទូលំទូលាយ។ | 4.00 | 0.60 | ខ្ពស់ |
| ៦ | ពង្រឹងការស្គាល់ខ្លួនឯង។ | 3.92 | 0.67 | ខ្ពស់ |
| ៧ | បានបង្កើតការស្រាវជ្រាវផ្នែកចិត្តសាស្ត្របន្ថែមទៀត។ | 4.00 | 0.60 | ខ្ពស់ |
| សរុប | | 3.79 | 0.68 | ខ្ពស់បង្គួរ |

តារាងទី៦បានបង្ហាញថា ការពង្រឹងការអនុវត្តលើការការងារទទួលបានលទ្ធផលខ្ពស់(M=3.79)។ ចំពោះផ្នែកប្រឡងយកពិន្ទុជាប្រចាំទទួលបានលទ្ធផលខ្ពស់(M=3.75)។ ចំណុចដែលទទួលបានកម្រិតស្មើគ្នាគឺការវាយតម្លៃបុគ្គលិកលក្ខណៈរបស់សិស្សនិងការវាយតម្លៃ និងត្រួតពិនិត្យដំណើរការបង្រៀនរបស់ខ្លួនបានកម្រិតខ្ពស់បង្គួរគឺ(M=3.50)។ ចំណុចដែលទទួលបានលទ្ធផលខ្ពស់ស្មើគ្នាដែរ គឺការផ្តល់ព័ត៌មានអប់រំបានទូលំទូលាយ និងចំណុចការបង្កើតការស្រាវជ្រាវផ្នែកចិត្តសាស្ត្រមានកម្រិតខ្ពស់(M=4.00)។ ចំពោះចំណុចពង្រឹងការស្គាល់ខ្លួនឯងទទួលបានកម្រិតខ្ពស់(M=3.92)។

| តារាងទី៧៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យការស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីព | | | | |
|---|---|---|---|---|
| ផ្នែកស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីព | | | | |
| ១ | ការសិក្សាត្រូវការធ្វើផែនការពេលវេលាច្បាស់លាស់ ដើម្បីឱ្យដឹងថាពេលណាត្រូវធ្វើលំហាត់នៅផ្ទះ ចាត់ចែងមេរៀនប្រឡង។ | 4.08 | 0.51 | ខ្ពស់ |
| ២ | បំណងប្រាថ្នាមិនមែនសុទ្ធតែគោលដៅនោះទេ។ គោលដៅមានភាពពិតប្រាកដជាង។ | 4.00 | 0.95 | ខ្ពស់ |
| ៣ | វិធីសាស្ត្ររៀនគឺជាធម្មជាតិនៃការចូលចិត្តពីរបៀបដែលយើងរៀនសូត្រ និងសិក្សា។ | 3.67 | 0.65 | ខ្ពស់បង្គួរ |
| ៤ | តួនាទីអ្នកប្រឹក្សាជួយផ្តល់ព័ត៌មានអំពីជីវិតសេដ្ឋកិច្ច ការងារព្រមទាំងសហគ្រិន | 4.00 | 0.60 | ខ្ពស់ |
| ៥ | ការវាយតម្លៃបុគ្គលិកលក្ខណៈ ដើម្បីតម្រង់ទិសជំនាញ។ | 4.25 | 0.45 | ខ្ពស់ |
| ៦ | មានគម្រោងច្បាស់លាស់ជួយបង្កើនឱកាសជោគជ័យ និងឈានមួយជំហានមុនអ្នកដទៃ។ | 4.17 | 0.71 | ខ្ពស់ |
| ៧ | ការកំណត់គោលដៅគឺជាការដាក់នូវផែនការ ដើម្បីសម្រេចបានក្នុងពេលកំណត់មួយ។ | 4.33 | 0.49 | ខ្ពស់ |
| ៨ | គោលដៅអាចលេចជារូបភាពផ្សេងៗគោលដៅហិរញ្ញវត្ថុ គោលដៅផ្លាស់ប្តូរឥរិយាបថ គោលដៅអប់រំ គោលដៅសម្រាប់អាជីព។ | 4.08 | 0.51 | ខ្ពស់ |
| ៩ | អ្វីដែលជាបញ្ហាមិនមែនទំហំសម្ពាធទេគឺត្រង់សិស្សមើលវាក្នុងទស្សនៈបែបណាហើយដោះស្រាយវាយ៉ាងដូចម្តេច ព្រោះសម្ពាធគឺជាផ្នែកមួយនៃជីវិត។ | 3.75 | 0.62 | ខ្ពស់បង្គួរ |
| ១០ | ស្ត្រេសក៏អាចជារឿងល្អដែរនៅពេលដែលវាមិនមានច្រើនពេក។ បរិមាណសមស្របនៃស្ត្រេសផ្តល់ឱ្យអ្នកនូវថាមពល និងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាព។ | 3.25 | 1.06 | មធ្យម |
| ១១ | ការសិក្សាទទួលបានជោគជ័យអ្នកសិក្សាត្រូវស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយ ហើយយកបទពិសោធន៍នៃការសិក្សារបស់អ្នកដទៃ និងបទពិសោធន៍ខ្លួនឯង ជាពិសេសត្រូវយល់ពីរបៀបសិក្សា។ | 4.33 | 0.78 | ខ្ពស់ |
| សរុប | | 3.99 | 0.66 | ខ្ពស់បង្គួរ |

តារាងទី៧បានបង្ហាញថា  ផ្នែកស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីពបានទទួលលទ្ធផលកម្រិតល្អគឺនៅក្នុងផ្នែកដែលទទួលបានចំណុចល្អគឺខ្លាំងមានចំណុចទី១ ២ ៤ ៥ ៧ ៨ ១១   កម្រិតស្មើរប្រហាក់ប្រហែលគ្នាគឺកម្រិតខ្ពស់គឺ(M >4)ឬ (M=4) ។ ចំណុចដែលលទ្ធផលតិចជាងគេគឺស្ត្រេសក៏ជារឿងល្អដែរនៅពេលដែលវាមិនមានច្រើនពេកបរិមាណសមស្របនៃស្ត្រេសផ្តល់ឱ្យអ្នកនូវថាមពលនិងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាពកម្រិតមធ្យមគឺ(M=3.25)។ ចំពោះចំណុចអ្វីដែលជាបញ្ហាមិនមែនទំហំសម្ពាធទេ  គឺត្រង់សិស្សមើលវាក្នុងទស្សនៈបែបណាហើយដោះស្រាយវាយ៉ាងដូចម្តេចព្រោះសម្ពាធគឺជាផ្នែកមួយនៃជីវិត។

**តារាងទី៨៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យតារាងសរុប**

| **តារាងសរុប** | | | | |
|---|---|---|---|---|
| ក | ការបែងចែកនិងអនុវត្តការងារបង្រៀន | 3.86 | 0.74 | ខ្ពស់បង្គួរ |
| ខ | ការកសាងសមត្ថភាពគ្រូ | 3.66 | 0.73 | ខ្ពស់បង្គួរ |
| គ | ការកសាងសមត្ថភាពសិស្ស | 3.93 | 0.62 | ខ្ពស់បង្គួរ |
| ឃ | បញ្ហាប្រឈមរបស់គ្រូ | 3.80 | 0.78 | ខ្ពស់បង្គួរ |
| ង | ដំណោះស្រាយ | 3.59 | 0.76 | ខ្ពស់បង្គួរ |
| ច | ការពង្រឹងលើការអនុវត្តការងារ | 3.79 | 0.68 | ខ្ពស់បង្គួរ |
| សរុប | | 3.77 | 0.72 | ខ្ពស់បង្គួរ |

តារាងទី៨បានបង្ហាញថា   លទ្ធផលគ្រូប្រឹក្សាអាជីពបានអនុវត្តការងារបង្រៀនរបស់គាត់បានកម្រិតខ្ពស់ពី 3.66 ដល់ 3.93។ នេះមានន័យថាទាំងការអនុវត្ត ទាំងសមត្ថភាពខ្លួន និងការកសាងសមត្ថភាពសិស្សបានល្អកម្រិតខ្ពស់   ស្របពេលដែលបញ្ហាប្រឈមមានកម្រិតខ្ពស់បង្គួរ   តែទោះជាយ៉ាងណា  ការរកដំណោះស្រាយ និងការពង្រឹងការអនុវត្តការងារមានកម្រិតខ្ពស់បង្គួរ។   នេះបញ្ជាក់ថា ផ្នែកការអនុវត្តនេះមិនទាន់ឆ្លើយតបទៅនឹងតម្រូវការនិងស្តង់ដាប្រឹក្សាអាជីពបានល្អទេដោយសារការងាររបស់គ្រូប្រឹក្សាអាជីពនៅមានបញ្ហាប្រឈមខ្ពស់ ។

តារាងទី៩៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យនៃនាយកលើការអនុវត្តការងារគ្រូប្រឹក្សាអាជីព

| ល.រ | ខ្លឹមសារ | កម្រិត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាត ស្តង់ដា | |
| ក.ការបែងចែកនិងអនុវត្តការងារបង្រៀន | | | | |
| ១ | មានការស្ម័គ្រចិត្តចូលរួមការបង្រៀនប្រឹក្សាអាជីព។ | 3.42 | 1.00 | មធ្យម |
| ២ | ការសម្រេចចិត្តបានច្បាស់លាស់ និងតម្លាភាពក្នុងការបំពេញការងារ។ | 3.83 | 1.20 | ខ្ពស់បង្គួរ |
| ៣ | បានអនុវត្តការងារឆ្លើយតបទៅតាមកម្មវិធីសិក្សា។ | 3.83 | 1.00 | ខ្ពស់បង្គួរ |
| ៤ | ប្រឹក្សាផ្តល់ការប្រឹក្សាឱ្យសិស្សជាបុគ្គល និងជាក្រុម។ | 3.67 | 0.65 | ខ្ពស់បង្គួរ |
| ៥ | រៀបចំកម្មវិធីសិក្សាប្រឹក្សាអាជីពទៅតាមតម្រូវការរបស់សិស្ស។ | 3.17 | 0.83 | មធ្យម |
| ៦ | គ្រូបានរៀបចំសម្ភារឧបទេសសម្រាប់បង្រៀនប្រឹក្សាអាជីពបានត្រឹមត្រូវ។ | 3.42 | 0.79 | មធ្យម |
| ៧ | យល់ដឹងពីខ្លឹមសារ និងសកម្មភាពក្នុងមេរៀនប្រឹក្សាអាជីពបានច្បាស់។ | 3.25 | 1.10 | មធ្យម |
| ៨ | មានផែនការក្នុងការដោះស្រាយបញ្ហាប្រឈមរបស់សិស្ស។ | 3.42 | 1.10 | មធ្យម |
| ៩ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ប្រឹក្សាអាជីព។ | 3.67 | 1.10 | ខ្ពស់បង្គួរ |
| ១០ | មុខវិជ្ជាប្រឹក្សាអាជីពជួយអភិវឌ្ឍន៍ការសិក្សារបស់សិស្ស។ | 4.08 | 1.10 | ខ្ពស់ |
| សរុប | | 3.93 | 0.98 | ខ្ពស់បង្គួរ |

តារាងទី៩បានបង្ហាញថា ចំណុចទី១មានការស្ម័គ្រចិត្តចូលរួមការបង្រៀនប្រឹក្សាអាជីព និងចំណុចទី៦គ្រូបានរៀបចំសម្ភារឧបទ្ទេសសម្រាប់បង្រៀនប្រឹក្សាអាជីពបានត្រឹមត្រូវ និងមានផែនការនៅក្នុងការដោះស្រាយបញ្ហាប្រឈមរបស់សិស្សដែលលទ្ធផលបានស្មើគ្នាកម្រិតមធ្យម(M=3.42)។ ចំណែកចំណុចទី២ការសម្រេចចិត្តបានច្បាស់លាស់និងតម្លាភាពក្នុងការបំពេញការងារនិងចំណុចបានអនុវត្តការងារឆ្លើយតបទៅតាមកម្មវិធីសិក្សា ដែលលទ្ធផលបានកម្រិតល្អ(M=3.83) ហើយចំណុចទី៤ និងចំណុចទី៩លទ្ធផលកម្រិតល្អបង្គួរស្មើគ្នា(M=3.67)។ ចំពោះចំណុចដែលបានលទ្ធផលទាបជាងគេគឺចំណុចទី៧ដែលបានកម្រិតមធ្យម(M=3.25)។ ចំណុចដែលបានលទ្ធផលខ្ពស់ជាងគេគឺចំណុចទី១០ មុខវិជ្ជាប្រឹក្សាអាជីពជួយអភិវឌ្ឍន៍ការសិក្សារបស់សិស្ស(M=4.08)។ ចំណែកលទ្ធផលសរុបក្នុងចំណុច

«ក» ការបែងចែកនិងអនុវត្តការងារបង្រៀនបានលទ្ធផលកម្រិតខ្ពង់បង្គួរ(M=៣.៩៣)។

**តារាងទី១០៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យនៃការកសាងសមត្ថភាពគ្រូ**

| | | | | |
|---|---|---|---|---|
| **ខ.ការកសាងសមត្ថភាពគ្រូ** | | | | |
| ១ | បានអភិវឌ្ឍគុណភាព និងសមត្ថភាពជំនាញប្រឹក្សាអាជីព។ | 3.50 | 1.10 | ខ្ពស់បង្គួរ |
| ២ | បញ្ជូនគ្រូទៅទទួលវគ្គបណ្តុះបណ្តាលមុខវិជ្ជាប្រឹក្សាអាជីព ដើម្បីមានសមត្ថភាពច្បាស់លាស់។ | 3.92 | 1.00 | ខ្ពស់បង្គួរ |
| ៣ | បានចុះអធិការកិច្ចដល់គ្រូបង្រៀនប្រឹក្សាអាជីព។ | 3.75 | 0.75 | ខ្ពស់បង្គួរ |
| ៤ | បានរៀបចំការប្រជុំបច្ចេកទេសលើមុខវិជ្ជាប្រឹក្សាអាជីពរៀងរាល់ខែ។ | 3.50 | 1.24 | ខ្ពស់បង្គួរ |
| ៥ | មានការលើកទឹកចិត្តគ្រូប្រឹក្សាអាជីពជាប្រចាំ។ | 4.00 | 0.85 | ខ្ពស់ |
| ៦ | បានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា។ | 3.67 | 1.07 | ខ្ពស់បង្គួរ |
| ៧ | បង្រៀនបានរៀបចំកិច្ចតែងការបង្រៀនជាប្រចាំ។ | 3.25 | 0.87 | មធ្យម |
| ៨ | បង្រៀនមានគុណវុឌ្ឍិសមស្របតាមនិយាម និងគោលការណ៍។ | 3.75 | 0.75 | ខ្ពស់បង្គួរ |
| ៩ | បង្រៀនបានប្រើវិធីសាស្ត្រទំនើបៗ និងការបង្រៀនដោយច្នៃប្រឌិត។ | 3.58 | 0.79 | ខ្ពស់បង្គួរ |
| សរុប | | 3.65 | 0.93 | ខ្ពស់បង្គួរ |

តារាងទី១០បានបង្ហាញថា ការកសាងសមត្ថភាពទទួលបានលទ្ធផលកម្រិតខ្ពស់(M=3.65) ដែលចំណុចទី១និងចំណុចទី៤ទទួលបានកម្រិតខ្ពស់ស្មើគ្នា(M=3.50)។ ចំណុចទី៣បានចុះអធិការកិច្ចដល់គ្រូបង្រៀនប្រឹក្សាអាជីពនិងចំណុចទី៨បង្រៀនមានគុណវុឌ្ឍិសមស្របតាមនិយាម និងគោលការណ៍បានលទ្ធផលកម្រិតខ្ពស់(M=3.75)។ ចំណែកចំណុចលេខ២បញ្ជូនគ្រូទៅទទួលវគ្គបណ្តុះបណ្តាលមុខវិជ្ជាប្រឹក្សាអាជីព ដើម្បីមានសមត្ថភាពច្បាស់លាស់ទទួលបានកម្រិតខ្ពស់(M=3.92)។ ចំណុចទី៥មានការលើកទឹកចិត្តគ្រូប្រឹក្សាអាជីពជាប្រចាំ ទទួលបានលទ្ធផលខ្ពស់ជាងគេ (M=4.00)។ ចំណែកចំណុចទី៧ លទ្ធផលទទួលបានទាបត្រឹមកម្រិតមធ្យម(M=3.25)។ ចំពោះចំណុចទី៩បង្រៀនបានប្រើវិធីសាស្ត្រទំនើបៗ និងការបង្រៀនដោយច្នៃប្រឌិតបានទទួលលទ្ធផលកម្រិតខ្ពស់(M=3.58)។

| តារាងទី១១៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យនៃការកសាងសមត្ថភាពសិស្ស | | | | |
|---|---|---|---|---|
| | គ.ការកសាងសមត្ថភាពសិស្ស | | | |
| ១ | បានផ្តល់ឱកាសដល់សិស្សអភិវឌ្ឍចំណុចខ្សោយរបស់គេ។ | 3.92 | 0.79 | ខ្ពស់ |
| ២ | សិស្សមានទំនាក់ទំនងជាមួយគ្រូយ៉ាងជិតស្និទ្ធ។ | 3.83 | 0.83 | ខ្ពស់ |
| ៣ | បានផ្តល់សេវាប្រឹក្សអាជីពដល់សិស្ស។ | 3.92 | 1.08 | ខ្ពស់ |
| ៤ | រក្សាការសម្ងាត់របស់សិស្ស។ | 3.83 | 0.83 | ខ្ពស់ |
| ៥ | សិស្សមានការអភិវឌ្ឍចំណុចខ្លាំង និងជំនាញទំនាក់ទំនង។ | 3.50 | 1.00 | ខ្ពស់ |
| ៦ | មានការចែករំលែកពីបទពិសោធន៍នៃរបៀបជោគជ័យ។ | 3.92 | 0.51 | ខ្ពស់ |
| សរុប | | 3.82 | 0.84 | ខ្ពស់ |

តារាងទី១១បានបង្ហាញថា លទ្ធផលចំណុចទី១បានផ្តល់ឱកាសដល់សិស្សអភិវឌ្ឍចំណុចខ្សោយរបស់គេនិងចំណុចទី៣ព្រមទាំងចំណុចទី៦បានផ្តល់សេវាប្រឹក្សអាជីពដល់សិស្ស មានការចែករំលែកពីបទពិសោធន៍នៃរបៀបជោគជ័យដែលបានលទ្ធផលកម្រិតខ្ពស់(M=3.92)។ ចំពោះចំណុចលេខ២សិស្សមានទំនាក់ទំនងជាមួយគ្រូយ៉ាងជិតស្និទ្ធនិងរក្សាការសម្ងាត់របស់សិស្ស រួមទាំងចំណុចទី៦មានការចែករំលែកពីបទពិសោធន៍នៃរបៀបជោគជ័យទទួលបានកម្រិតខ្ពស់(M=3.83)។ សរុបមក ចំណុចកសាងសមត្ថភាពសិស្សបានលទ្ធផលកម្រិតខ្ពស់(M=3.82)។

**តារាងទី១២៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យនៃបញ្ហាប្រឈមរបស់នាយក**

| | ឃ.បញ្ហាប្រឈមរបស់គ្រូ | | | |
|---|---|---|---|---|
| ១ | សិស្សមិនមានភាពច្បាស់លាស់នៅជម្រើសអាជីព។ | 3.42 | 1.10 | មធ្យម |
| ២ | ខ្វះការជំរុញពីភាគីពាក់ព័ន្ធដែលមានឥទ្ធិពលលើអាជីពរបស់សិស្ស។ | 3.50 | 0.90 | ខ្ពស់បង្គួរ |
| ៣ | ខ្វះព័ត៌មានអប់រំ និងសេវាប្រឹក្សាអាជីពញឹកញាប់។ | 3.17 | 1.03 | មធ្យម |
| ៤ | នៅមានកម្រិតពីការស្វែងយល់ពីចំណាប់អារម្មណ៍ និងវិធីកាត់បន្ថយសម្ពាធ | 3.25 | 0.87 | មធ្យម |
| ៥ | ផ្តល់វគ្គបណ្តុះបណ្តាលជំនាញប្រឹក្សាអាជីពបានតិចតួច។ | 3.33 | 0.99 | មធ្យម |
| សរុប | | 3.33 | 0.97 | មធ្យម |

តារាងទី១២បានបង្ហាញថា នាយកជួបបញ្ហាប្រឈមកម្រិតមធ្យមខ្វះព័ត៌មានអប់រំនៅមានកម្រិតស្វែងយល់ពីចំណាប់

អារម្មណ៍និងវិធីកាត់បន្ថយសម្ពាធទទួលបានលទ្ធផលកម្រិតមធ្យម(Mean=3.25 3.17)។ ដូចគ្នាដែរសិស្សមានភាពមិនច្បាស់លាស់ក្នុងការជ្រើសរើសអាជីពមានកម្រិតមធ្យមកម្រិតខ្ពស់(Mean=3.42)។ ខ្វះការជំរុញពីភាគីពាក់ព័ន្ធដែលមានឥទ្ធិពលលើអាជីពរបស់សិស្សបានកម្រិតបង្គួរ (Mean=3.50)។

**តារាងទី១៣៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យដំណោះស្រាយ របស់នាយក**

| | **ង.ដំណោះស្រាយ** | | | |
|---|---|---|---|---|
| ១ | អញ្ជើញអតីតសិស្សដែលបានជ្រើសរើសអាជីពបានត្រឹមត្រូវមកប្រឹក្សាបន្ថែម | 3.92 | 0.29 | ខ្ពស់បង្គួរ |
| ២ | បង្កើនទំនាក់ទំនងជាមួយគ្រូប្រឹក្សាអាជីព និងសិស្សដែលមានបញ្ហា។ | 3.92 | 0.67 | ខ្ពស់បង្គួរ |
| ៣ | បានកសាងប្រអប់សំបុត្រចំពោះសិស្សដែលត្រូវការជំនួយ។ | 3.67 | 0.89 | ខ្ពស់បង្គួរ |
| ៤ | បានបំពាក់សម្ភារបរិក្ខារដូចដូចជាកសាងដើមឈើគោលបំណងនិងអាជីព។ | 3.58 | 0.67 | ខ្ពស់បង្គួរ |
| ៥ | មានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់ដំណើការប្រឹក្សាអាជីព។ | 3.75 | 0.75 | ខ្ពស់បង្គួរ |
| ៦ | ពង្រឹងការចូលរួមគ្រប់ភាគីពាក់ព័ន្ធដែលជះឥទ្ធិពលលើជម្រើសអាជីពសិស្ស | 3.50 | 1.00 | ខ្ពស់បង្គួរ |
| សរុប | | 3.72 | 0.71 | ខ្ពស់បង្គួរ |

តារាងទី១៣បានបង្ហាញថា ចំណុចដំណោះស្រាយជាចំណុចដែលទទួលបានលទ្ធផលកម្រិតខ្ពស់បង្គួរជាងគេគឺចំណុចទី១អញ្ជើញអតីតសិស្ស ដែលបានជ្រើសរើសអាជីពបានត្រឹមត្រូវមកប្រឹក្សាអាជីពបន្ថែម(M=3.92)ស្មើគ្នានិងការបង្កើនទំនាក់ទំនងជាមួយគ្រូប្រឹក្សាអាជីពនិងសិស្សមានបញ្ហា។ ចំណុចលេខ៣បានកសាងប្រអប់សំបុត្រចំពោះសិស្សត្រូវការជំនួយបានកម្រិតខ្ពស់បង្គួរ(M=3.67)។ ចំពោះចំណុចការបំពាក់សម្ភារបរិក្ខាដូចជាការកាសាងដើមឈើគោលបំណងនិងអាជីពបានលទ្ធផលកម្រិតខ្ពស់បង្គួរ(3.58)។ មានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់ដំណើការប្រឹក្សាអាជីពបានពីលទ្ធផលខ្ពស់បង្គួរ(M=3.75) ។ ចំណែកមានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់ដំណើការប្រឹក្សាអាជីពបានលទ្ធផលខ្ពស់បង្គួរ (M=3.75) ចំណុចដែលទទួលបានលទ្ធផលខ្ពស់បង្គួរតែទាបជាងគេក្នុងចំណោមដំណោះស្រាយ (M=3.50)។ សរុបមក ដំណោះស្រាយដែលនាយកប្រើទទួលបានលទ្ធផលកម្រិតខ្ពស់បង្គួរ(M=3.72)។

| តារាងទី១៤៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យ ការពង្រឹងលើការអនុវត្តការងាររបស់នាយក | | | | |
|---|---|---|---|---|
| | **ច.ការពង្រឹងលើការអនុវត្តការងារ** | | | |
| ១ | មានការប្រឡងយកពិន្ទុជាប្រចាំលើមុខវិជ្ជាប្រឹក្សា។ | 3.17 | 1.03 | មធ្យម |
| ២ | បានវាយតម្លៃជាប្រចាំលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់សិស្ស។ | 3.67 | 0.65 | ខ្ពស់បង្គួរ |
| ៣ | មានការវាយតម្លៃ និងត្រួតពិនិត្យដំណើការបង្រៀនរបស់គ្រូ។ | 3.83 | 0..83 | ខ្ពស់បង្គួរ |
| ៤ | បានរៀបចំវគ្គតម្រង់ទិសអាជីព២ឬ៣ដងក្នុងមួយឆ្នាំ។ | 3.25 | 1.13 | មធ្យម |
| ៥ | មានការផ្តល់ព័ត៌មានអប់រំបានទូលំទូលាយ។ | 3.58 | 1.00 | ខ្ពស់បង្គួរ |
| ៦ | ពង្រឹងការស្គាល់ខ្លួនឯង។ | 3.92 | 0..79 | ខ្ពស់បង្គួរ |
| ៧ | បានបង្កើតការស្រាវជ្រាវផ្នែកចិត្តសាស្រ្តបន្ថែមទៀត។ | 3.58 | 0.79 | ខ្ពស់បង្គួរ |
| សរុប | | 3.57 | 0.88 | ខ្ពស់បង្គួរ |

តារាងទី១៤បានបង្ហាញថា ការពង្រឹងការអនុវត្តការងារមានកម្រិតខ្ពស់បង្គួរដែល(M=3.57)។ ចំណុចត្រង់មានការប្រឡងយកពិន្ទុជាប្រចាំលើមុខវិជ្ជាប្រឹក្សាបានកម្រិតមធ្យម(M=3.17)។ ចំពោះចំណុចបានវាយតម្លៃជាប្រចាំលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់សិស្សទទួលបានកម្រិតខ្ពស់បង្គួរ(M=3.67)។ ចំណុចដែលទទួលបានលទ្ធផលខ្ពស់បង្គួរជាងគេ ក្នុងចំណោមទាំង៧ចំណុចគឺមានការវាយតម្លៃនិងត្រួតពិនិត្យដំណើរការបង្រៀនរបស់គ្រូ(M=3.83) ចំពោះចំណុចដែលទទួលបានលទ្ធផលស្មើគ្នា គឺមានការផ្តល់ព័ត៌មានអប់រំបានទូលំទូលាយ និងបានបង្កើតការស្រាវជ្រាវផ្នែកចិត្តសាស្រ្តបន្ថែមទៀតទាំងពីរទទួលបានកម្រិតខ្ពស់បង្គួរ (M=3.58)។ ចំណុចដែលទទួលបានលទ្ធផលខ្ពស់បង្គួរជាងគេគឺពង្រឹងការស្គាល់ខ្លួនឯង(M=3.92)។

| តារាងទី១៥៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យការស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីពរបស់នាយក | | | | |
|---|---|---|---|---|
| | **ផ្នែកស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីព** | | | |
| ១ | ការសិក្សាត្រូវការធ្វើផែនការពេលវេលាច្បាស់លាស់ ដើម្បីឱ្យដឹងថាពេលណាត្រូវធ្វើលំហាត់នៅផ្ទះ ចាត់ចែងមេរៀនប្រឡង។ | 4.08 | 0.51 | ខ្ពស់ |
| ២ | បំណងប្រាថ្នាមិនមែនសុទ្ធតែគោលដៅនោះទេ។ គោលដៅមានភាពពិតប្រាកដជាង។ | 4.00 | 1.04 | ខ្ពស់ |
| ៣ | វិធីសាស្ត្ររៀនគឺជាធម្មជាតិនៃការចូលចិត្តពីរបៀបដែលយើងរៀនសូត្រនិងសិក្សា។ | 4.00 | 0.85 | ខ្ពស់ |
| ៤ | នាទីអ្នកប្រឹក្សាជួយផ្តល់ព័ត៌មានអំពីជីវិតសេដ្ឋកិច្ច ការងារ ព្រមទាំងសហគ្រិន។ | 4.08 | 0.90 | ខ្ពស់ |
| ៥ | ការវាយតម្លៃបុគ្គលិកលក្ខណៈ ដើម្បីតម្រង់ទិស និងជំនាញ។ | 3.83 | 0.83 | ខ្ពស់បង្គួរ |
| ៦ | មានគម្រោងច្បាស់លាស់ជួយបង្កើនឱកាសជោគជ័យនិងឈានមួយជំហានមុនអ្នកដទៃ។ | 3.92 | 1.20 | ខ្ពស់បង្គួរ |
| ៧ | ការកំណត់គោលដៅគឺជាការដាក់ផែនការដើម្បីសម្រេចបានក្នុងពេលកំណត់មួយ។ | 4.00 | 0.85 | ខ្ពស់ |
| ៨ | គោលដៅអាចជាលេចជារូបភាពផ្សេងៗ គោលដៅហិរញ្ញវត្ថុ គោលដៅផ្លាស់ប្តូរឥរិយាបថ គោលដៅអប់រំ គោលដៅសម្រាប់អាជីព។ | 4.00 | 0.95 | ខ្ពស់ |
| ៩ | ដែលជាបញ្ហាមិនមែនជាទំហំនៃសម្ពាធទេគឺត្រង់សិស្សមើលវាក្នុងទស្សនៈបែបណាហើយដោះស្រាយវាយ៉ាងដូចម្តេច ព្រោះសម្ពាធគឺជាផ្នែកមួយនៃជីវិត។ | 3.83 | 1.20 | ខ្ពស់បង្គួរ |
| ១០ | ស្រ្តេសក៏ជារឿងល្អដែរនៅពេលដែលវាមិនមានច្រើនពេក។ បរិមាណសមស្របនៃស្ត្រេសផ្តល់ឱ្យអ្នកនូវថាមពល និងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាព។ | 3.33 | 1.07 | មធ្យម |
| ១១ | ការសិក្សាទទួលបានជោគជ័យ អ្នកសិក្សាត្រូវស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយ ហើយយកបទពិសោធន៍នៃការសិក្សារបស់អ្នកដទៃ និងបទពិសោធន៍របស់ខ្លួនឯង ជាពិសេសត្រូវដឹងពីរបៀបសិក្សា។ | 4.33 | 0.89 | ខ្ពស់ |
| សរុប | | 3.94 | 0.93 | ខ្ពស់បង្គួរ |

តារាងទី១៥បានបង្ហាញថា ចំណុចការសិក្សាត្រូវការធ្វើផែនការពេលវេលាច្បាស់លាស់ដើម្បីឱ្យដឹងថាពេលណាត្រូវធ្វើលំហាត់នៅផ្ទះ ចាត់ចែងមេរៀនប្រឡងទទួលបានលទ្ធផលល្អបង្គួរដូចគ្នានិងចំណុចទី៣.៧.៨.១១ដែល(M =>4)។ ចំណែកចំណុចដែលបានលទ្ធផលមធ្យមគឺស្រ្តេសក៏ជារឿងល្អដែរនៅពេលដែលវាមិនមានច្រើនពេក។ បរិមាណសម

ស្របនៃស្ត្រេសផ្តល់ឱ្យអ្នកនូវថាមពលនិងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាព។ ចំពោះមានគម្រោងច្បាស់លាស់ជួយបង្កើនឱកាសជោគជ័យនិងឈានមួយជំហានមុនអ្នកដទៃលទ្ធផលទទួលបានល្អបង្គួរ(M=3.92)។ចំពោះចំណុចដែលជាបញ្ហាមិនមែនជាទំហំនៃសម្ពាធទេគឺត្រង់សិស្សមើលវាក្នុងទស្សនៈបែបណា ហើយដោះស្រាយវាយ៉ាងដូចម្តេចព្រោះសម្ពាធគឺជាផ្នែកមួយនៃជីវិតគឺទទួលលទ្ធផលកម្រិតខ្ពស់បង្គួរ(M=3.83)។ សរុបមក ចំណុចស៊ីជម្រៅលើខ្លឹមសារប្រឹក្សាអាជីពគឺបានកម្រិតខ្ពស់(M=3.94)។

**តារាងទី១៦៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យតារាងសរុប**

**តារាងលទ្ធផល**

| | តារាងសរុបន័យ | | | |
|---|---|---|---|---|
| ក | ការបែងចែកនិងអនុវត្តការងារបង្រៀន | 3.93 | 0.98 | ខ្ពស់បង្គួរ |
| ខ | ការកសាងសមត្ថភាពគ្រូ | 3.65 | 0.93 | ខ្ពស់បង្គួរ |
| គ | ការកសាងសមត្ថភាពសិស្ស | 3.82 | 0.84 | ខ្ពស់បង្គួរ |
| ឃ | បញ្ហាប្រឈមរបស់គ្រូ | 3.33 | 0.97 | មធ្យម |
| ង | ដំណោះស្រាយ | 3.72 | 0.71 | ខ្ពស់បង្គួរ |
| ច | ការពង្រឹងលើការអនុវត្តការងារ | 3.57 | 0.88 | ខ្ពស់បង្គួរ |
| | សរុប | 3.67 | 0.88 | ខ្ពស់បង្គួរ |

តារាងទី១៦បានបង្ហាញថា នាយកធ្វើការងារដើម្បីជួយគ្រូនិងការទទួលបានចំណេះដឹងប្រឹក្សាអាជីពបានកម្រិតខ្ពស់បង្គួរ (M=3.67)។ នៅក្នុងចំណោមចំណុចទាំង៦ចំណុចដែលទទួលបានលទ្ធផលទាបជាងគេនៅកម្រិតមធ្យមគឺការបញ្ហាប្រឈម។

| តារាងទី១៧៖ មធ្យម គម្លាតស្តង់ដានិងអត្ថន័យប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពសួរទៅលើសិស្ស | | | | |
|---|---|---|---|---|
| | ក.ការប្រឹក្សាជួយសិស្ស | | | |
| ១ | ចេះបង្កើតបណ្តាញក្នុងការរស់នៅនិងកន្លែងសិក្សា។ | 3.50 | 0.90 | ខ្ពស់បង្គួរ |
| ២ | ការសម្រេចចិត្តក្នុងការជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រ និងសង្គម មានភាពច្បាស់លាស់។ | 3.85 | 0.84 | ខ្ពស់បង្គួរ |
| ៣ | បានដឹងច្បាស់ពីភាពខ្លាំងនិងភាពខ្សោយរបស់ខ្លួន។ | 4.02 | 0.85 | ខ្ពស់ |
| ៤ | បានទទួលការប្រឹក្សាជាបុគ្គល និងជាក្រុម។ | 3.81 | 0.82 | ខ្ពស់បង្គួរ |
| ៥ | មានសណ្តាប់ធ្នាប់ក្នុងការរៀនសូត្រ។ | 3.99 | 0.87 | ខ្ពស់បង្គួរ |
| ៦ | ដឹងពីវិធីសិក្សាបានច្បាស់លាស់។ | 3.87 | 0.77 | ខ្ពស់បង្គួរ |
| ៧ | មេរៀនប្រឹក្សាជួយឱ្យការសិក្សាប្អូនទទួលលទ្ធផលល្អ។ | 3.88 | 0.85 | ខ្ពស់បង្គួរ |
| ៨ | ប្រឹក្សាមានផែនការក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ខ្លួន។ | 3.70 | 0.82 | ខ្ពស់បង្គួរ |
| ៩ | ចេះសរសេរកំណត់ហេតុ និងរៀបចំគោលដៅជីវិត។ | 3.64 | 1.07 | ខ្ពស់បង្គួរ |
| ១០ | មុខវិជ្ជាប្រឹក្សាអាជីពជួយអភិវឌ្ឍការសិក្សារបស់ខ្លួន។ | 3.73 | 0.86 | ខ្ពស់បង្គួរ |
| សរុប | | 3.79 | 0.86 | ខ្ពស់បង្គួរ |

តារាងទី១៧បានបង្ហាញថាការសិស្សចេះបង្កើតបណ្តាញក្នុងការរស់នៅ និងការសិក្សាបានលទ្ធផលខ្ពស់បង្គួ(M=3.5) ការសម្រេចចិត្តក្នុងការជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រ និងសង្គមមានការច្បាស់លាស់ដឹងពីវិធីសិក្សាបានច្បាស់លាស់ បានទទួលការប្រឹក្សាជាបុគ្គល និងជាក្រុមមេរៀនប្រឹក្សា ហើយជួយឱ្យការសិក្សាប្អូនទទួលលទ្ធផលល្អចំណុចទាំងនេះទទួលបានលទ្ធផលខ្ពស់បង្គួរគឺ(M=>3.81) ។ ចំពោះចំណុចការចេះសរសេរកំណត់ហេតុនិងរៀបចំគោលដៅជីវិតបានលទ្ធផលខ្ពស់បង្គួរ(M=3.70) និងចំណុចចេះសរសេរកំណត់ហេតុនិងរៀបចំគោលដៅជីវិតទទួលបានលទ្ធផលខ្ពស់បង្គួរ(M=3.64)។ ចំណែកចំណុចទី១០មុខវិជ្ជាប្រឹក្សាអាជីពជួយអភិវឌ្ឍការសិក្សារបស់ខ្លួនទទួលលទ្ធផលខ្ពស់បង្គួរ(M=3.73)។ សរុបមក ចំណុចការអនុវត្តរបស់សិស្សទទួលបានលទ្ធផលខ្ពស់បង្គួរ(M=3.79)។

| តារាងទី១៨៖ មធ្យម គម្លាតស្តង់ដា និងអត្ថន័យការប្រឹក្សាជួយឱ្យប្រែប្រួលបុគ្គលិកលក្ខណៈ | | | | |
|---|---|---|---|---|
| | ខ.ការប្រឹក្សាជួយឱ្យប្រែប្រួលបុគ្គលិកលក្ខណៈ | | | |
| ១ | មានការរីករាយក្នុងការរៀនសូត្រជាងមុន។ | 3.84 | 0.91 | ខ្ពស់បង្គួរ |
| ២ | ចេះធ្វើការជាក្រុមនិងជួយក្រុមបានច្រើន ចេះសហប្រតិបត្តិការគ្នា។ | 3.90 | 0.87 | ខ្ពស់បង្គួរ |
| ៣ | មានភាពក្លាហាននិងហ៊ានសម្រេចចិត្តរឿងផ្សេងបានរហ័សជាងមុន។ | 3.71 | 0.89 | ខ្ពស់បង្គួរ |
| ៤ | មានការវាយតម្លៃលើវឌ្ឍនភាពរបស់ខ្លួនជាប្រចាំ។ | 3.46 | 0.93 | មធ្យម |
| ៥ | មានការលើកទឹកចិត្តខ្លួនឯងជាប្រចាំ និងគិតវិជ្ជមាន។ | 3.89 | 0.88 | ខ្ពស់បង្គួរ |
| ៦ | មានទំនាក់ទំនងល្អជាមួយគ្រូ គ្រួសារ និងមិត្តភក្តិ។ | 4.03 | 0.81 | ខ្ពស់ |
| ៧ | រៀបចំពេលវេលាសិក្សាបានល្អ។ | 3.78 | 0.88 | ខ្ពស់បង្គួរ |
| ៨ | ចេះរៀបចំបទបង្ហាញ និងដឹងពីរបៀប។ | 3.60 | 0.88 | ខ្ពស់បង្គួរ |
| ៩ | ចេះសរសេរគម្រោង និងមានភាពជាសហគ្រិន។ | 3.44 | 0.99 | មធ្យម |
| សរុប | | 3.73 | 0.89 | ខ្ពស់បង្គួរ |

តារាងទី១៨បានបង្ហាញថា សិស្សរីករាយនៅក្នុងការរៀនសូត្រទទួលបានកម្រិតខ្ពស់បង្គួរ (M=3.84) ខ្ពស់ជាងភាពក្លាហាននិងហ៊ានសម្រេចចិត្តរឿងផ្សេងៗបានយ៉ាងរហ័ស(M=3.71)។ ចំណែកសិស្សចេះធ្វើការងារក្រុមទទួលបានលទ្ធផលកម្រិតខ្ពស់បង្គួរ(M=3.90)។ ចំណុចដែលបានលទ្ធផលប្រហាក់ប្រហែលគ្នាគឺចំណុចលេខ៤មានការវាយតម្លៃលើវឌ្ឍនភាពរបស់ខ្លួនជាប់ជាប្រចាំ និងចេះសរសេរគម្រោង ហើយនិងមានភាពជាសហគ្រិនបានកម្រិតមធ្យម (M=>3.44-3.46)។ ចំណុចដែលខ្ពស់បង្គួរជាងគេគឺមានទំនាក់ទំនងល្អជាមួយគ្រូ និងគ្រួសារ មិត្តភក្តិបានលទ្ធផលកម្រិតខ្ពស់(M=4.03) ខ្ពស់ជាងគេក្នុងចំណោមទាំង៩ចំណុចទាំងនេះ។

| | | | | |
|---|---|---|---|---|
| | **គ.ចំណេះដឹងនិងអាជីព** | | | |
| ១ | អភិវឌ្ឍចំណុចខ្សោយរបស់ខ្លួនដោយផ្តោតលើអាជីពអនាគត។ | 3.67 | 0.97 | ខ្ពស់បង្គួរ |
| ២ | ស្គាល់ខ្លួនឯងច្បាស់។ | 3.75 | 0.97 | ខ្ពស់បង្គួរ |
| ៣ | ចូលរួមធ្វើការស្ម័គ្រចិត្ត ចូលរួមសិក្ខាសាលា ឬកម្មវិធីហ្វឹកហ្វឺនផ្សេងៗ។ | 3.44 | 0.93 | មធ្យម |
| ៤ | ចង់ទទួលបានជំនាញ ការគិតសមហេតុផល ភាពជាអ្នកដឹកនាំ ជំនាញ។ | 3.64 | 0.93 | ខ្ពស់បង្គួរ |
| ៥ | ដោះស្រាយបញ្ហា ការធ្វើការងារជាក្រុម។ | 3.91 | 0.77 | ខ្ពស់បង្គួរ |
| ៦ | ចេះបណ្តុះផ្នត់គំនិតណាដែលមានសារៈប្រយោជន៍សម្រាប់ខ្លួន។ | 3.93 | 0.75 | ខ្ពស់បង្គួរ |
| ៧ | មានការពេញចិត្តចែករំលែកពីបទពិសោធន៍នៃរបៀបជោគជ័យ។ | 3.60 | 0.95 | ខ្ពស់បង្គួរ |
| | សរុប | 3.70 | 0.89 | ខ្ពស់បង្គួរ |

តារាងខាងលើបានបង្ហាញថា សិស្សមានចំណេះដឹងអាជីពចំណុចទី១អភិវឌ្ឍចំណុចខ្សោយរបស់ខ្លួនដោយផ្តោតលើអាជីពអនាគតនិងចង់ទទួលបានជំនាញ ការគិតសមហេតុផល ភាពជាអ្នកដឹកនាំ ជំនាញទទួលបានលទ្ធផលកម្រិតប្រហាក់ប្រហែលគ្នា(M=3.63) ។ ចំណុចស្គាល់ខ្លួនឯងច្បាស់បានកម្រិតខ្ពស់បង្គួរ(M=3.75) ហើយការដោះស្រាយបញ្ហា ការធ្វើការងារជាក្រុម និងចេះបណ្តុះផ្នត់គំនិតណា ដែលមានសារៈប្រយោជន៍សម្រាប់ខ្លួនបានកម្រិតខ្ពស់បង្គួរប្រហាក់ប្រហែលគ្នា(M=3.91 - 3.93)។

| | | | | |
|---|---|---|---|---|
| | **ឃ.បញ្ហាប្រឈម** | | | |
| ១ | មិនមានភាពច្បាស់លាស់នៅជម្រើសអាជីព។ | 3.35 | 1.04 | មធ្យម |
| ២ | ខ្វះការជំរុញពីភាគីពាក់ព័ន្ធដែលមានឥទ្ធិពលលើអាជីពរបស់សិស្ស។ | 3.27 | 0.98 | មធ្យម |
| ៣ | ខ្វះព័ត៌មានអប់រំ និងសេវាប្រឹក្សាអាជីពញឹកញាប់។ | 3.39 | 0.86 | មធ្យម |
| ៤ | នៅមានកម្រិតពីការស្វែងយល់ពីចំណាប់អារម្មណ៍ និងវិធីកាត់បន្ថយសម្ពាធ | 3.51 | 0.92 | ខ្ពស់ |
| ៥ | ទទួលវគ្គបណ្តុះបណ្តាលជំនាញប្រឹក្សាបានតិចតួច។ | 3.49 | 0.92 | មធ្យម |
| | សរុប | 3.40 | 0.94 | មធ្យម |

តារាងខាងលើបានបង្ហាញថា ចំណុចបញ្ហាប្រឈមលទ្ធផលទទួលបានកម្រិតមធ្យម(M=3.42) ដែលចំណុចទី១មិនមានភាពច្បាស់លាស់នៅជម្រើសអាជីពបានលទ្ធផលមធ្យម(M=3.35)។ ចំណែកឯចំណុចទី២លទ្ធផលទទួលបាន

| | | | | |
|---|---|---|---|---|
| កម្រិតមធ្យម(M=3.27)។ចំពោះចំណុចទី៣បានកម្រិតខ្ពស់(M=3.51)។ចំពោះចំណុចទី៥ទទួលវគ្គបណ្តុះបណ្តាលជំនាញប្រឹក្សាបានតិចតួចហើយលទ្ធផលទទួលបានកម្រិតមធ្យម(M=3.49)។ | | | | |
| | **ង.ដំណោះស្រាយ** | | | |
| ១ | ចូលរួមប្រឹក្សាឱ្យបានច្រើនជាង។ | 3.75 | 0.96 | ខ្ពស់បង្គួរ |
| ២ | បង្កើនទំនាក់ទំនងជាមួយគ្រូ និងរៀមច្បងដែលមានភាពជោគជ័យ។ | 3.77 | 0.87 | ខ្ពស់បង្គួរ |
| ៣ | បណ្តុះផ្នត់គំនិត និងឥរិយាបថល្អៗសម្រាប់អភិវឌ្ឍខ្លួនឯង។ | 3.81 | 0.84 | ខ្ពស់បង្គួរ |
| ៤ | ដាក់ចិត្តរៀនដើម្បីសម្រេចគោលដៅណាមួយ និងមានជំនឿជាក់លើខ្លួន។ | 3.88 | 0.76 | ខ្ពស់បង្គួរ |
| ៥ | ចេះស្វែងរកព័ត៌មានអប់រំបានត្រឹមត្រូវ។ | 3.70 | 0.77 | ខ្ពស់បង្គួរ |
| ៦ | ពង្រឹងការចូលរួមគ្រប់ភាគីពាក់ព័ន្ធដែលជះឥទ្ធិពលលើជម្រើសអាជីព។ | 3.56 | 0.79 | ខ្ពស់បង្គួរ |
| សរុប | | 3.74 | 0.83 | ខ្ពស់បង្គួរ |
| តារាងខាងលើបានបង្ហាញថា ផ្នែកដំណោះស្រាយចំណុចទី១ចូលរួមប្រឹក្សាឱ្យបានច្រើនជាងបានទទួលលទ្ធផលកម្រិតខ្ពស់បង្គួរ(M=3.75)។ ចំណែកចំណុចទី២ បង្កើនទំនាក់ទំនងជាមួយគ្រូ និងរៀមច្បងដែលមានភាពជោគជ័យដែលលទ្ធផលកម្រិតខ្ពស់បង្គួរ(M=3.77) ច្រើនជាងលទ្ធផលចំណុចទី៥ចេះស្វែងរកព័ត៌មានអប់រំបានត្រឹមត្រូវបានលទ្ធផលកម្រិតខ្ពស់បង្គួរ(M=3.70) និងចំណុចទី៦ ពង្រឹងការចូលរួមគ្រប់ភាគីពាក់ព័ន្ធដែលជះឥទ្ធិពលលើជម្រើសអាជីពបានលទ្ធផលកម្រិតខ្ពស់បង្គួរ(M=3.56)។ ចំពោះលេខ៤ទទួលបានលទ្ធផលខ្ពស់បង្គួរជាងគេ(M=3.88)ខ្ពស់ជាងលេខ៣បណ្តុះផ្នត់គំនិតនិងឥរិយាបថល្អៗសម្រាប់អភិវឌ្ឍខ្លួនឯងបន្តិច(M=3.81)។ ចំណែកលទ្ធផលសរុបនៅចំណុចដំណោះស្រាយលទ្ធផលទទួលបានកម្រិតខ្ពស់បង្គួរ (M=3.74)។ | | | | |
| | **ច.ការពិនិត្យតាមដានលទ្ធផល** | | | |
| ១ | ទទួលបានពិន្ទុល្អស្មើរគ្រប់មុខវិជ្ជា។ | 3.31 | 0.86 | មធ្យម |
| ២ | បានវាយតម្លៃជាប្រចាំលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់ខ្លួន។ | 3.55 | 0.79 | ខ្ពស់បង្គួរ |
| ៣ | ចេះក្តាប់ឱកាសជាងមុន។ | 3.51 | 0.83 | ខ្ពស់បង្គួរ |
| ៤ | បានចូលរួមវគ្គតម្រង់ទិសអាជីព២ឬ៣ដងក្នុង១ឆ្នាំ។ | 3.45 | 0.88 | មធ្យម |
| ៥ | ចេះគ្រប់គ្រងសម្ពាធ និងរកវិធីដោះស្រាយ។ | 3.68 | 0.72 | ខ្ពស់បង្គួរ |
| ៦ | ធ្វើការងារមានប្រយោជន៍ច្រើន។ | 3.71 | 0.86 | ខ្ពស់បង្គួរ |
| ៧ | កំណត់ពីជម្រើសអាជីពទៅអនាគត។ | 3.86 | 0.87 | ខ្ពស់បង្គួរ |
| សរុប | | 3.58 | 0.83 | ខ្ពស់បង្គួរ |

តារាងខាងលើបានបង្ហាញថា ការការពិនិត្យតាមដានលទ្ធផលបានកម្រិតខ្ពស់(M=3.58) ចំពោះចំណុចទី១បណ្តុះផ្នត់គំនិតនិងឥរិយាបថល្អៗសម្រាប់អភិវឌ្ឍខ្លួនឯង លទ្ធផលបានកម្រិតមធ្យម(M=3.31)។ ចំណែកចំណុចទី២បានវាយតម្លៃជាប្រចាំលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់ខ្លួនបានលទ្ធផលកម្រិតខ្ពស់បង្គួរ (M=3.51)។ ចំពោះចំណុចទី៣ចេះក្តាប់ឱកាសជាងមុនបានលទ្ធផលកម្រិតខ្ពស់បង្គួរ(M=3.51) លើសចំណុចទី៤បានចូលរួមវគ្គតម្រង់ទិសអាជីព២ឬ៣ដងក្នុង១ឆ្នាំ បានលទ្ធផលមធ្យម (M=3.45)។ ចំពោះចំណុចទី៥ចេះគ្រប់គ្រងសម្ពាធ និងរកវិធីដោះស្រាយបានកម្រិតខ្ពស់បង្គួរM=3.68 តិចជាងចំណុចទី៦ធ្វើការងារមានប្រយោជន៍ច្រើន (M=3.71) ហើយចំណុចដែលបានលទ្ធផលខ្ពស់បង្គួរជាងគេគឺចំណុចទី៧ (M=3.86)។

| | **ផ្នែកស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីព** | | | |
|---|---|---|---|---|
| ១ | ការសិក្សាត្រូវការធ្វើផែនការពេលវេលាច្បាស់លាស់ ដើម្បីឱ្យដឹងថាពេលណាត្រូវធ្វើលំហាត់នៅផ្ទះ ចាត់ចែងមេរៀនប្រឡង។ | 3.92 | 0.84 | ខ្ពស់បង្គួរ |
| ២ | បំណងប្រាថ្នាមិនមែនសុទ្ធតែគោលដៅនោះទេ គោលដៅមានភាពពិតប្រាកដជាង | 3.73 | 0.83 | ខ្ពស់បង្គួរ |
| ៣ | វិធីសាស្ត្ររៀនគឺជាធម្មជាតិនៃការចូលចិត្តពីរបៀបដែលយើងរៀនសូត្រនិងសិក្សា។ | 3.71 | 0.76 | ខ្ពស់បង្គួរ |
| ៤ | ជ្រើសរើសអាជីពត្រូវមើលលើគុណតម្លៃ ចំណង់ចំណូលចិត្ត ជំនាញ បទពិសោធន៍ | 3.99 | 0.73 | ខ្ពស់បង្គួរ |
| ៥ | ការវាយតម្លៃបុគ្គលិកលក្ខណៈ ដើម្បីតម្រង់ទិសជំនាញ។ | 3.51 | 0.81 | ខ្ពស់បង្គួរ |
| ៦ | មានគម្រោងច្បាស់លាស់ជួយបង្កើនឱកាសជោគជ័យឈានមួយជំហានមុនអ្នកដទៃ | 3.63 | 0.86 | ខ្ពស់បង្គួរ |
| ៧ | ការកំណត់គោលដៅគឺជាការដាក់នូវផែនការ ដើម្បីសម្រេចបានក្នុងពេលកំណត់មួយ។ | 3.76 | 0.83 | ខ្ពស់បង្គួរ |
| ៨ | គោលដៅអាចលេចជារូបភាពផ្សេងៗគោលដៅហិរញ្ញវត្ថុ គោលដៅផ្លាស់ប្តូរឥរិយាបថ គោលដៅអប់រំ គោលដៅសម្រាប់អាជីព។ | 3.73 | 0.76 | ខ្ពស់បង្គួរ |
| ៩ | អ្វីដែលជាបញ្ហាមិនមែនទំហំសម្ពាធទេ គឺត្រង់សិស្សមើលវាក្នុងទស្សនៈបែបណា ហើយដោះស្រាយវាយ៉ាងដូចម្តេច ព្រោះសម្ពាធគឺជាផ្នែកមួយនៃជីវិត។ | 3.68 | 0.78 | ខ្ពស់បង្គួរ |
| ១០ | ស្ត្រេសក៏អាចជារឿងល្អដែរនៅពេលដែលវាមិនមានច្រើនពេក។ បរិមាណសមស្របនៃស្ត្រេសផ្តល់ឱ្យអ្នកនូវថាមពល និងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាព។ | 3.35 | 0.87 | មធ្យម |
| ១១ | ការសិក្សាទទួលបានជោគជ័យអ្នក សិក្សាត្រូវស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយ ហើយយកបទពិសោធន៍នៃការសិក្សារបស់អ្នកដទៃនិងបទពិសោធន៍ខ្លួនឯងជាពិសេសត្រូវយល់ពីរបៀបសិក្សា។ | 4.13 | 0.89 | ខ្ពស់ |
| សរុប | | 3.74 | 0.88 | ខ្ពស់បង្គួរ |

តារាងខាងលើបានបង្ហាញថា លទ្ធផលការសិក្សាត្រូវការធ្វើផែនការពេលវេលាច្បាស់លាស់ ដើម្បីឱ្យដឹងថាពេលណាត្រូវធ្វើលំហាត់នៅផ្ទះ ចាត់ចែងមេរៀនប្រឡងបានលទ្ធផលកម្រិតល្អបង្គួរ(M=3.92)។ ចំណុចទី២បំណងប្រាថ្នាមិនមែនសុទ្ធតែគោលដៅនោះទេ។ គោលដៅមានភាពពិតប្រាកដជាងបានលទ្ធផលល្អបង្គួរ(M=3.73)។វិធីសាស្ត្ររៀនគឺជាធម្មជាតិនៃការចូលចិត្តពីរបៀបដែលយើងរៀនសូត្រ និងសិក្សាបានលទ្ធផលល្អជ្រើសរើសអាជីពត្រូវមើលលើគុណតម្លៃ ចំណង់ចំណូលចិត្ត ជំនាញ និងបទពិសោធន៍បានលទ្ធផលខ្ពស់បង្គួរ(M=3.71)។ ចំណែកចំណុចទី៤ជ្រើសរើសអាជីពត្រូវមើលលើគុណតម្លៃ ចំណង់ចំណូលចិត្ត ជំនាញ និងបទពិសោធន៍។ បានទទួលលទ្ធផលល្អបង្គួរ(M=3.99)។ ការវាយតម្លៃបុគ្គលិកលក្ខណៈ ដើម្បីតម្រង់ទិសជំនាញបានទទួលលទ្ធផលខ្ពស់បង្គួរ (M=3.51)។ ចំណែកចំណុចទី៦មានគម្រោងច្បាស់លាស់ជួយបង្កើនឱកាសជោគជ័យនិងឈានមួយជំហាន មុនអ្នកដទៃលទ្ធផលបានកម្រិតខ្ពស់បង្គួរ(M=3.63)។ ចំពោះចំណុចទី៧ការកំណត់គោលដៅ គឺជាការដាក់នូវផែនការដើម្បីសម្រេចបានក្នុងពេលកំណត់មួយបានលទ្ធផលល្អបង្គួរ(M=3.73)។ ចំណែកចំណុចទី៨អ្វីដែលជាបញ្ហាមិនមែនទំហំសម្ពាធទេ គឺត្រង់សិស្សមើលវាក្នុងទស្សនៈបែបណាហើយដោះស្រាយវាយ៉ាងដូចម្តេច ព្រោះសម្ពាធគឺជាផ្នែកមួយនៃជីវិតបានទទួលលទ្ធផលល្អបង្គួរ(M=3.68)។ ចំពោះចំណុចទី១០ស្ត្រេស ក៏អាចជារឿងល្អដែរនៅពេលដែលវាមិនមានច្រើនពេក។ បរិមាណសមស្របនៃស្ត្រេស ផ្តល់ឱ្យអ្នកនូវថាមពលនិងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាព លទ្ធផលបានកម្រិតមធ្យម(M=3.35)។ ចំណុចទទួលបានលទ្ធផលល្អខ្ពស់ជាងគេគឺចំណុចទី១១ ការសិក្សាបានជោគជ័យគឺអ្នកសិក្សាត្រូវស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយ យកបទពិសោធន៍នៃការសិក្សាអ្នកដទៃនិងបទពិសោធន៍ខ្លួនឯងពិសេសត្រូវយល់ពីរបៀបសិក្សាលទ្ធផលកម្រិតល្អ (M=4.13)។ សរុបមក ផ្នែកទី២នេះលទ្ធផលល្អបង្គួរ(M=3.74)។

| | **តារាងសរុប** | | | |
|---|---|---|---|---|
| ក | ការបែងចែក និងអនុវត្តការងារបង្រៀន | 3.79 | 0.86 | ខ្ពស់បង្គួរ |
| ខ | ការកសាងសមត្ថភាពគ្រូ | 3.73 | 0.89 | ខ្ពស់បង្គួរ |
| គ | ការកសាងសមត្ថភាពសិស្ស | 3.70 | 0.89 | ខ្ពស់បង្គួរ |
| ឃ | បញ្ហាប្រឈមរបស់គ្រូ | 3.40 | 0.94 | មធ្យម |
| ង | ដំណោះស្រាយ | 3.74 | 0.83 | ខ្ពស់បង្គួរ |
| ច | ការពង្រឹងលើការអនុវត្តការងារ | 3.58 | 0.83 | ខ្ពស់បង្គួរ |
| សរុប | | 3.65 | 0.87 | ខ្ពស់បង្គួរ |

តារាងខាងលើបានបង្ហាញថា សមាសភាគទាំង៦នៃប្រសិទ្ធភាពនៃការអនុវត្តការងាររបស់នាយកសាលាមានតម្លៃមធ្យមខុសៗគ្នា ដែលសមាសភាគចំនួន៦មានកម្រិតល្អ បង្គួរ និងសមាសភាគចំនួន១ទទួលបានកម្រិតមធ្យម។ ផ្នែកដែលមានលំដាប់ពិន្ទុខ្ពស់ជាច់គេនៅក្នុងលំដាប់ទី១ គឺជាការបែងចែក និងការអនុវត្តការងារបង្រៀនដែលមាន Mean = 3.79 ទទួលបានកម្រិតល្អបង្គួរហើយផ្នែកដំណោះស្រាយ និងការកសាងសមត្ថភាពគ្រូស្ថិតក្នុងលំដាប់ទី២ មាន Mean = 3.74។ ចំណែកផ្នែកដែលទទួលបានកម្រិតទាបជាងគេគឺបញ្ហាប្រឈមដែល Mean = 3.40។ ចំពោះការពង្រឹងលើការអនុវត្តការងារបានលទ្ធផលល្អបង្គួរ Mean =3.58។

## ៤.៣-ការពិភាក្សាការស្រាវជ្រាវ

តាមលទ្ធផលនៃការស្រាវជ្រាវខាងលើបង្ហាញថា ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីព និងយោបល់លើសិស្សនៅមធ្យមសិក្សាទុតិយភូមិ មិនទាន់ឆ្លើយតបតាមស្តង់ដាប្រឹក្សាអាជីពក្នុងការជួយសិស្សនៅឡើយទេ ដោយសារលទ្ធផលនៃការអនុវត្តការងារបង្រៀន និងបញ្ហាប្រឈមទទួលបានលទ្ធផលស្មើគ្នាបង្គួរដូចគ្នា។ មូលហេតុដោយសារកម្មវិធីប្រឹក្សាអាជីពទើបនឹងមាននៅមធ្យមសិក្សាទុតិយភូមិ ហើយគ្រូប្រឹក្សាទទួលការបណ្តុះបណ្តាលបានតិចតួចខ្វះបទពិសោធន៍។ ដូចនេះ ទាមទារឱ្យគ្រូប្រឹក្សានិងអ្នកពាក់ព័ន្ធជួយរកដំណោះស្រាយបន្ថែមទៀតនិងកាត់បន្ថយបញ្ហាប្រឈមដែលខ្លួនមាន និងរិះរកវិធីសាស្ត្រល្អៗ នៅក្នុងការជួយសិស្សនិងអភិវឌ្ឍអាជីពរបស់ខ្លួន។ ហើយពន្យល់ណែនាំសិស្សពីប្រយោជន៍នៃមុខវិជ្ជានេះឱ្យបានទូលំទូលាយ។ នៅក្នុងសន្និបាតពិភពលោកស្តីពីការអភិវឌ្ឍនៃសេវាកម្មប្រឹក្សាអាជីពក្នុងការអប់រំដែលមានលោក Komlavi F,Seddoh ជានាយកបានលើកឡើងថា ការប្រឹក្សាអាជីពនៅមានកម្រិតប្រឈមដែរ។ ដូច្នេះ តម្រូវឱ្យអ្នកប្រឹក្សាត្រូវតែជាអ្នកឯកទេសមានបទពិសោធន៍និងចេះសម្របសម្រួលដោះស្រាយរាល់បញ្ហាប្រឈម។ តាមរយៈការសិក្សារបស់ Wendy J.L.Thornton and Heike A.Dumke(2005)បានបង្ហាញថា ដើម្បីដោះស្រាយបញ្ហា និងប្រសិទ្ធភាពនៃការសម្រេចចិត្តដែលត្រឹមត្រូវទាមទារឱ្យមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ និងមានវិធីសាស្ត្រមួយច្បាស់លាស់។ ទន្ទឹមនឹងនេះដែរ ការស្រាវជ្រាវរបស់លោក RadhikaKapur (2016)បានរកឃើញថា ប្រសិទ្ធភាពនៃការប្រឹក្សារបស់អ្នកប្រឹក្សាត្រូវផ្តល់ការតម្រង់ទិសនិងជាអ្នកដោះស្រាយបញ្ហារបស់សិស្ស ហើយអាណាព្យាបាលត្រូវស្វែងយល់ពីតម្រូវការរបស់សិស្ស។ តាមការស្រាវជ្រាវរបស់Ojo (2006) បានលើកឡើងថា អ្នកប្រឹក្សាត្រូវតែជាអ្នកជំនាញនៅក្នុងមុខវិជ្ជា ហើយគាត់មានចំណេះដឹងទូលំទូលាយ និងមានទស្សនៈវិស័យច្បាស់លាស់ ជាពិសេសត្រូវយល់ពីតួនាទីនិងភារកិច្ចអ្នកប្រឹក្សា។

# ជំពូកទី៥

# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១-សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការស្រាវជ្រាវនិងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើលទ្ធផលនេះ អ្នកស្រាវជ្រាវអាចទាញសេចក្ដីសន្និដ្ឋានបានថា ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីព និងយោបល់លើសិស្សមធ្យមសិក្សាទុតិយភូមិនៅខេត្តបន្ទាយមានជ័យបានកម្រិតល្អបង្គួរ Mean=3.77 ,SD=0.72 ហើយក្នុងដំណាក់កាលទាំង៦នៃការអនុវត្តវិធីសាស្ត្រនេះមានលក្ខណៈមិនខុសគ្នាខ្លាំងនិងបញ្ហាប្រឈមទេ។ នេះសបញ្ជាក់ឱ្យឃើញថាការអនុវត្តការងាររបស់គ្រូស្តង់ដាប្រឹក្សាអាជីពមិនទាន់ឆ្លើយតបនិងស្តង់ដាប្រឹក្សាក្នុងការជួយសិស្សនៅមធ្យមសិក្សាទុតិយភូមិបានល្អនៅឡើយទេ បើទោះជា លោកគ្រូ អ្នកគ្រូ សិស្ស គណៈគ្រប់គ្រងនៅក្នុងខេត្តបន្ទាយមានជ័យបានធ្វើការវាយតម្លៃដូចៗគ្នាថា ពួកគាត់បានចំណាយពេលដើម្បីរកដំណោះស្រាយ និងពង្រឹងការអនុវត្តការងាររបស់ពួកគាត់ក៏ដូចជាការកសាងសមត្ថភាពសិស្សមកកម្រិតល្អបង្គួរ គឺអាចបណ្ដាលមកពីពេលវេលាក្នុងការសិក្សារៀនសូត្របាន តិចគ្រូនៅ មានសមត្ថភាពមិនទាន់បានល្អកសាងផែនការអាជីព និងសហគ្រិនភាពបាន ដោយការចូលរួមពីភាគីពាក់ព័ន្ធនៅមានកម្រិត។ ជាក់ស្តែង លោកគ្រូ អ្នកគ្រូមិនទាន់បានអនុវត្តបានល្អក្នុងការរិះរកវិធីសាស្ត្រល្អៗក្នុងការជួយសិស្ស តែគាត់ធ្វើបានល្អបង្គួរក្នុងការជួយជំរុញសិស្សឱ្យហ៊ឺកហាត់ធ្វើសកម្មភាពកាត់បន្ថយសម្ពាធ និងបានជួយប្រឹក្សាយោបល់សិស្ស បានបង្កើតទំនាក់ទំនងដ៏ល្អជាមួយគ្រូនិងសិស្ស សិស្សនិងសិស្សបានប្រើវិធីសាស្ត្រ ការផ្លាស់ប្តូរឥរិយាបទច្រើនក្នុងការរៀនសូត្រ និងរីករាយក្នុងការរៀនសូត្រនិងដោះស្រាយបញ្ហាប្រឈមនានា។ ប៉ុន្តែបើយើងក្រឡេកមើលសកម្មភាពជាក់ពិន្ទុវិញ នៅក្នុងការអនុវត្តការការបង្រៀននៅក្នុងដំណើរការបង្រៀនវិញយើងសង្កេតឃើញថា គ្រូយកចិត្តទុកដាក់ទៅលើពិន្ទុរបស់សិស្សបានត្រឹមកម្រិតមធ្យម ។

សរុបមក លោកគ្រូ អ្នកគ្រូ នៅក្នុងខេត្តបន្ទាយមានជ័យ អនុវត្តការងារប្រឹក្សាអាជីពនិងប្រឹក្សាយោបល់លើសិស្ស នៅមធ្យមសិក្សាទុតិយភូមិមិនទាន់បានល្អតាមស្តង់ដាប្រឹក្សានៅឡើយទេ ដែលតម្រូវឱ្យគ្រូនិងអ្នកពាក់ព័ន្ធជួយសហការជួយរកដំណោះស្រាយបន្ថែមទៀត។

## ៥.២-សំណូមពរ

នៅក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង

ក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ ក៏ដូចជាសកលលោកផងដែរដោយបានដាក់ចេញនូវគោលការណ៍គោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាច្រើន។ ក្រសួងអប់រំ យុវជន និងកីឡាបានផ្លាស់ប្តូរប្រព័ន្ធអប់រំពីការអប់រំដោយការបង្រៀនសិស្ស ឱ្យចេះរកវិធីរៀនសូត្រ និងមានគំនិតម្ចាស់ការដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួនតាមរយៈការបង្រៀនមេរៀនប្រឹក្សាអាជីព ដែលសិស្សជាអ្នកកសាងគម្រោងអាជីពនិងវិធីសាស្ត្រដើម្បីសម្រេចតាមគោលដៅរបស់ខ្លួន ជាពិសេសត្រូវចេះរកវិធីរៀនសូត្រនិងកាត់បន្ថយសម្ពាធ។ ជាជាងរៀនគ្មានគោលដៅលទ្ធផលមិនបានល្អគ្មានបានត្រៀមលក្ខណៈជាមុន។ គ្រូគ្រាន់តែជាអ្នកដឹកនាំ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ណែនាំ និងត្រួតត្រាយផ្លូវឱ្យសិស្សប៉ុណ្ណោះ ដើម្បីឱ្យសិស្សចេះសិក្សាស្រាវជ្រាវ ស្វែងយល់ទាំងចំណេះដឹង ចំណេះធ្វើព្រមទាំងបទពិសោធន៍ដែលប្រកបដោយភាពថ្លៃថ្នូរ វិជ្ជាជីវៈ សីលធម៌ គុណធម៌ និងវិន័យ ក៏ប៉ុន្តែការប្រឹក្សាអាជីពនេះត្រូវប្រឈមបញ្ហាមួយចំនួនដូចជា កង្វះខាតបទពិសោធន៍និងការចូលរួមដែលធ្វើឱ្យការអនុវត្តមិនទាន់មានប្រសិទ្ធភាពខ្ពស់។ យោងតាមលទ្ធផល និងការសន្និដ្ឋាននៃការសិក្សាស្រាវជ្រាវនេះដើម្បីឱ្យការអនុវត្តការងារប្រឹក្សានេះមានដំណើរការល្អ និងទទួលបានប្រសិទ្ធភាពតាមរយៈសំណូមពរមួយចំនួនដូចខាងក្រោម៖

**១.ក្រសួងអប់រំ យុវជន និងកីឡា**

- សូមឱ្យមានកម្មវិធីប្រឹក្សាអាជីព និងយោបល់គ្រប់វិទ្យាល័យនៅក្នុងប្រទេសកម្ពុជា។
- ជួយសម្រួលដោយផ្តល់វគ្គបំប៉នបន្ថែមទៀត ដល់គ្រូសម្រាប់បម្រើឱ្យការបង្រៀន និងការរៀនរបស់សិស្ស ព្រោះថាបើខ្វះបទពិសោធន៍និងវិធីសាស្ត្រល្អៗនោះដំណើរការនៃការបង្រៀនក៏មិនអាចប្រព្រឹត្តទៅបានល្អដែរ
- ផ្សព្វផ្សាយពីសារៈសំខាន់ នៃការអនុវត្តមេរៀនប្រឹក្សាអាជីព និងយោបល់លើសិស្សឱ្យបានទូលំទូលាយ ជាពិសេសសិស្សដែលមានបញ្ហាប្រឈម។
- បើកវគ្គប្រឹក្សាដែលមានអ្នកជំនាញ និងមានបទពិសោធន៍ល្អៗក្នុងការប្រឹក្សាអាជីពលើសិស្ស។

**២.នាយកសាលា**

- ជួយសម្របសម្រួលដល់ការរៀបចំម៉ោងឱ្យបានសមស្រប ដើម្បីជួយបង្កលក្ខណៈងាយស្រួលដល់ការបង្រៀន និងការរៀនរបស់សិស្ស និងការផ្តល់កន្លែងសមរម្យសម្រាប់គ្រូ សិស្សអាចធ្វើប្រឹក្សា ជាក្រុម និងជាបុគ្គលបាន។
- ជួយជំរុញនិងលើកទឹកចិត្តសិស្សឱ្យខិតខំប្រឹងប្រែងរៀនសូត្រ ស្រាវជ្រាវ និងចេះពង្រឹងភាពខ្លាំងរបស់ខ្លួន
- ត្រូវធ្វើអធិការកិច្ចលើគ្រូបង្រៀនឱ្យបានច្រើន។

- ធ្វើស្វ័យវាយតម្លៃនិងកែលម្អទៅលើគ្រូបង្រៀនជាប្រព័ន្ធ។
- ចូលរួមក្នុងការងារប្រជុំបច្ចេកទេសជាមួយប្រធានក្រុមបច្ចេកទេសប្រឹក្សា ដើម្បីពិនិត្យឡើងវិញ និងកែលម្អវិធីសាស្ត្របង្រៀន។
- លើកទឹកចិត្តដល់គ្រូបង្រៀនដែលលះបង់ពេលវេលាជួយសិស្ស និងធ្វើការងារល្អ។

**៣.គ្រូបង្រៀន**

- គ្រូបង្រៀនផ្ទាល់ត្រូវមានការប្រជុំបច្ចេកទេសរិះរកវិធីសាស្ត្រល្អៗជួយសិស្ស ហើយធ្វើការវាយតម្លៃលើការសិក្សា និងផ្តល់មតិកែតម្រូវរាល់កិច្ចការដែលបានវាយតម្លៃ ព្រោះថាការវាយតម្លៃ និងមតិកែតម្រូវនេះអាចជាផ្លូវសម្រាប់សិស្សស្វែងយល់ពីកំហុសរបស់ខ្លួននិងអភិវឌ្ឍន៍ខ្លួនឱ្យរឹងមាំ។

**៤.អ្នកស្រាវជ្រាវបន្ត**

ដោយការស្រាវជ្រាវនេះបានសិក្សាផ្តោតតែទៅលើប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីព និងយោបល់លើសិស្សនៅមធ្យមសិក្សាទុតិយភូមិ លទ្ធផលស្រាវជ្រាវអាចបង្ហាញបានត្រឹមលក្ខណៈទូទៅ ពុំបានបង្ហាញពីលទ្ធផលសិក្សារបស់សិស្សដែលសាលាមានប្រឹក្សានៅជនបទ និងលទ្ធផលសិក្សារបស់សិស្សដែលមានប្រឹក្សាអាជីពនៅទីប្រជុំជនទេ។ ដូច្នេះ អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀតអាចពិនិត្យមើលថា តើការអនុវត្តការងារប្រឹក្សាអាជីពនិងយោបល់លើសិស្ស មានភាពខុសគ្នាដូចម្តេចលើលទ្ធផលសិក្សារបស់សិស្សមានប្រឹក្សានៅជនបទ និងនៅទីប្រជុំជនហើយពង្រីកភាគសំណាកនិងទីតាំងបន្ថែមទៀត។

# ឯកសារយោង

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) ការផ្តល់ប្រឹក្សាអាជីពព័ត៌មានស្តីពីការសិក្សាជំនាញ ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) វិជ្ជាជីវៈទាំង២០របស់stem នៅក្នុងប្រទេសកម្ពុជា Stem Career with future ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៧)សេចក្តីណែនាំស្តីពីការអនុវត្តសេវាប្រឹក្សាអាជីពនៅតាមគ្រឹះស្ថានមធ្យមសិក្សា ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៨) សៀវភៅណែនាំស្តីពីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិ ភ្នំពេញ

-ហង់ជួន ណារ៉ុន(២០១៥) កំណែទម្រង់វិស័យអប់រំ ភ្នំពេញ

-ហង់ជួន ណារ៉ុន(២០១៨) កំណែទម្រង់វិស័យអប់រំ ភ្នំពេញ

-ជួន ណាត(១៩៣៨) វចនានុក្រមខ្មែរ ភ្នំពេញ

-Mariu Pold (2019) Career Counselling Strategies practical hand book what Really MATTERS http /wrmcloud eu/ Authers Dana Balas –Timar (Camelar Bugariu office @btmres ources.so)

-Virve Kihkar Mariu Pold Tallinn (2019) Guidenline for Career Councellors on addressing gender . equality and gender shereo typical Career choices in career Counselling

-Radhikal Kapur (2012) Career Guidance and Student Counselling

-September, 12 (2016) Carreer Development Guide for HR Practitiona at ANU(nd) Retrieved

-JohnD. KRUM BoIT2 (2013) tep Research Series No1 Career Guidance and counselling the bridge from secondary school to Tertiary Education

-Scientific and Cultural Organization (2002) Hanbook on Career counselling a practical mannual for developing implementing and assessing career counselling Servies higher education setting

-Wedy JL .Thornnton and Heike A .Dumke Simon Fraser (2005) Age differences in Everyday Problem –solving and Decision –Making Effectiveness AMetta –Analytic Review University

-AKKermans ,J (2013) Well Began holf Done, investigating the work and career of long work force Enscheule, Ipskamp Drukkers

-JFM Koppenjan and EH . Klijn(1995) Making Uncertainties in Networks A network Approach to Problem solving and Decision Making

-TEVETA (Technical, Entreprener and Vocational Education and Trainning Authority) (2013). Poupose and objective of the Career Counselling

-The Council of the Eureopean Union (2015) Council decision (EU) the guidelines for the emlpoyment

-Wendy J. L. Thornton and Heike A.Dumke

-National Employment Agentcy (2015) Skills Shortage and Skill Gaps in the Cambodian Labour Maeket: Evidence from Employer Skills needs Survey

-Saint Blanquat & ASSociates, Co, Ltd, Funded by the British Embassy Phnom Penh (2016) Stem Career of the future

-KAMPUCHEAN ACTION FOR PRIMARY EDUCATION (2014) Career counseling training Manual

- Wendy Canning and Claire H .Hollowing ( 2014 ) Cambodai′Future Jobs : linking to the economy of tomorrow

- iResearchNet.com ( 2020 ). History of Career Counseling. Retrieved from iResearchNet.com website: http://psychology. iresearchnet.com/ counseling-psychology/ career-counseling/ history-of-career-counseling/ ( 08/June/2020 )

-Gaston College ( 2020 ). Who Needs Career Counseling - Counseling & Career Development. Retrieved from Gaston College website:https://www.gaston.edu/counseling-career-development/career-counseling/ who-needs-career-counseling/ ( 08/June/2020 )

- All psychology schools ( 2020 ). Learn About the Different Areas of Counseling Retrieved from All psychology schoolswebsite: https: //www.allpsychology schools.com /counseling/ types-of-counseling/ ( 08/June/2020 )

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ក្រសួងអប់រំ យុវជន និងកីឡា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

# កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់គ្រូប្រឹក្សាអាជីព នៅវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ

នាងខ្ញុំឈ្មោះ **ឡៀប ឆវិន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំកំពុងសរសេរនិក្ខេបបទស្តីពី «ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពនិងយោបល់លើសិស្សនៅវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ»ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីស្វែងយល់ពី ប្រសិទ្ធិភាពនៃការអនុវត្ត និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងការបង្រៀនរបស់គ្រូប្រឹក្សាអាជីពនៅខេត្តបន្ទាយមានជ័យ។ទិន្នន័យប្រមូលបានពីលោកគ្រូ-អ្នកគ្រូមានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគឆ្លើយតបទៅប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោកគ្រូអ្នកគ្រូ មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យនាងខ្ញុំអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រដើម្បីទាញអំណះអំណាងយកមកសិក្សាបកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម របស់លោកគ្រូ-អ្នកគ្រូ។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោក-លោកស្រី គូសសញ្ញា✓ក្នុងប្រអប់ខាងក្រោមនេះ

១.តួនាទី៖..........................................................................................................................

២.បម្រើការងារនៅ៖……………………………………..ឃុំ/សង្កាត់៖…………………………………..

ក្រុង/ស្រុក/ខណ្ឌ៖…………………… …………………..ខេត្ត៖………..………………………………..

៣.ភេទ ប្រុស☐ ស្រី☐

៤.អាយុ ☐ ២៥-៣០ ឆ្នាំ ☐ ៣១-៣៥ឆ្នាំ ☐ ៣៦-៤០ឆ្នាំ ☐ លើសពី៤០ឆ្នាំ

៥.កម្រិតវប្បធម៌ ☐ សញ្ញាបត្រទុតិយភូមិ ☐បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ ផ្សេងៗ ...........

៦ .មុខជំនាញឯកទេស៖.........................................................................................................

៧.បទពិសោធន៍ការងារ ៖ ☐១ដល់៥ឆ្នាំ ☐៦ទៅ១០ ឆ្នាំ ☐១ទៅ១៥ ឆ្នាំ ☐លើសពី១៥ឆ្នាំ

**ផ្នែកទី២៖ ប្រសិទ្ធភាពនៃការអនុវត្តការបង្រៀនរបស់គ្រូប្រឹក្សាអាជីព**

ការណែនាំ៖ សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់បន្ទាប់មកគូសសញ្ញា✓ ទៅតាមកម្រិតនៃការយល់ស្រប របស់លោក-លោកស្រី។

កម្រិតចង្អុលបង្ហាញ៖

១.មិនយល់ស្របទាល់តែសោះ

២.មិនយល់ស្រប

៣.ពុំមានយោបល់

៤.យល់ស្រប

៥.យល់ស្របខ្លាំង

| ល.រ | **បរិយាយ** | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| **ក.ការបែងចែកនិងអនុវត្តការងារបង្រៀន** | | | | | | |
| ១ | ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូមានរៀបចំកិច្ចតែងការបានល្អ។ | | | | | |
| ២ | គ្រូបង្រៀនមេរៀនបានទាន់កម្មវិធីសិក្សា។ | | | | | |
| ៣ | បានអនុវត្តការងារឆ្លើយតបទៅតាមតម្រូវការសិស្ស។ | | | | | |
| ៤ | មានផ្តល់ប្រឹក្សាឱ្យសិស្សជាបុគ្គលនិងជាក្រុម។ | | | | | |
| ៥ | រៀបចំល្បែងសិក្សា ដើម្បីទាញចំណាប់អារម្មណ៍សិស្ស។ | | | | | |
| ៦ | គ្រូបានរៀបចំសម្ភារឧបទេសសម្រាប់បង្រៀនប្រឹក្សាអាជីពបានត្រឹមត្រូវ។ | | | | | |
| ៧ | យល់ដឹងពីខ្លឹមសារ និងសកម្មភាពក្នុងមេរៀនប្រឹក្សាអាជីពបានច្បាស់។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | មានផែនការក្នុងការដោះស្រាយបញ្ហាប្រឈមរបស់សិស្ស។ | | | | | |
| ៩ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ក្នុងការប្រឹក្សាអាជីព។ | | | | | |
| ១០ | មុខវិជ្ជាប្រឹក្សាអាជីពជួយអភិវឌ្ឍការសិក្សារបស់សិស្ស។ | | | | | |
| **ខ.ការកសាងសមត្ថភាពគ្រូ** | | | | | | |
| ១ | បានទៅទទួលការបណ្ដុះបណ្ដាល ដើម្បីអភិវឌ្ឍគុណភាពនិងសមត្ថភាពជំនាញប្រឹក្សាអាជីព។ | | | | | |
| ២ | មានការពិភាក្សាគ្នាជាមួយគ្រូដទៃ ដើម្បីដោះស្រាយបញ្ហាប្រឈម។ | | | | | |
| ៣ | មានការលើកទឹកចិត្តពីនាយកសាលាបានច្រើន។ | | | | | |
| ៤ | បានរៀបចំការប្រជុំបច្ចេកទេសលើមុខវិជ្ជាប្រឹក្សារៀងរាល់ខែ។ | | | | | |
| ៥ | មានការលើកទឹកចិត្តសិស្សជាប្រចាំ។ | | | | | |
| ៦ | គ្រូបានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា។ | | | | | |
| ៧ | បានរៀបចំកិច្ចតែងការបង្រៀនជាប្រចាំ។ | | | | | |
| ៨ | សិស្សអាចកសាងផែនការអាជីព និងសហគ្រិនភាពបាន។ | | | | | |
| ៩ | បានប្រើវិធីសាស្ត្រទំនើបៗ និងបង្រៀនដោយច្នៃប្រឌិត។ | | | | | |
| **គ.ការកសាងសមត្ថភាពសិស្ស** | | | | | | |
| ១ | បានផ្ដល់ឱកាសដល់សិស្សអភិវឌ្ឍចំណុចខ្សោយរបស់គេ។ | | | | | |
| ២ | សិស្សមានទំនាក់ទំនងជាមួយខ្លួនយ៉ាងជិតស្និទ្ធ។ | | | | | |
| ៣ | បានផ្ដល់សេវាប្រឹក្សាអាជីពដល់សិស្ស។ | | | | | |
| ៤ | រក្សាការសម្ងាត់របស់សិស្ស។ | | | | | |
| ៥ | សិស្សមានការអភិវឌ្ឍចំណុចខ្លាំង និងជំនាញទំនាក់ទំនង។ | | | | | |
| ៦ | មានការពេញចិត្តចែករំលែកពីបទពិសោធន៍នៃរបៀបជោគជ័យ។ | | | | | |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ឃ.បញ្ហាប្រឈមរបស់គ្រូ | | | | | | |
| ១ | សិស្សមិនមានភាពច្បាស់លាស់នៅជម្រើសអាជីព។ | | | | | |
| ២ | ខ្វះការជំរុញពីភាគីពាក់ព័ន្ធដែលមានឥទ្ធិពលលើអាជីពរបស់សិស្ស។ | | | | | |
| ៣ | ខ្វះព័ត៌មានអប់រំ និងសេវាប្រឹក្សាអាជីពញឹកញាប់។ | | | | | |
| ៤ | គ្រូនៅមានកម្រិតពីការស្វែងយល់ពីចំណាប់អារម្មណ៍ និងវិធីកាត់បន្ថយសម្ពាធ | | | | | |
| ៥ | ផ្តល់វគ្គបណ្តុះបណ្តាលជំនាញប្រឹក្សាបានតិចតួច។ | | | | | |
| ង .ដំណោះស្រាយ | | | | | | |
| ១ | អញ្ជើញអតីតនិស្សិតដែលបានជ្រើសរើសអាជីពបានត្រឹមត្រូវមកប្រឹក្សាបន្ថែម។ | | | | | |
| ២ | បង្កើនទំនាក់ទំនងជាមួយគ្រូប្រឹក្សាដូចគ្នា និងសិស្សដែលមានបញ្ហា។ | | | | | |
| ៣ | តាមដានប្រអប់សំបុត្រចំពោះសិស្សដែលត្រូវការជំនួយ។ | | | | | |
| ៤ | ជំរុញឱ្យមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ ដើម្បីជួយសិស្សទាន់ពេលវេលា។ | | | | | |
| ៥ | ទទួលកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការប្រឹក្សាអាជីព។ | | | | | |
| ៦ | ស្វែងយល់ពីអ្វីដែលជះឥទ្ធិពលលើជម្រើសអាជីពសិស្សបានច្បាស់។ | | | | | |
| ច.ការពង្រឹងលើការអនុវត្តការងារ | | | | | | |
| ១ | មានការប្រឡងយកពិន្ទុជាប្រចាំលើមុខវិជ្ជាប្រឹក្សា។ | | | | | |
| ២ | បានវាយតម្លៃជាប្រចាំលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់សិស្ស។ | | | | | |
| ៣ | មានការវាយតម្លៃ និងត្រួតពិនិត្យដំណើរការបង្រៀនរបស់ខ្លួន។ | | | | | |
| ៤ | បានរៀបចំវគ្គតម្រង់ទិសអាជីព២ឬ៣ដងក្នុង១ឆ្នាំ។ | | | | | |
| ៥ | មានការផ្តល់ព័ត៌មានអប់រំបានទូលំទូលាយ។ | | | | | |
| ៦ | ពង្រឹងការស្គាល់ខ្លួនឯង។ | | | | | |
| ៧ | បានបង្កើតការស្រាវជ្រាវផ្នែកចិត្តសាស្ត្របន្ថែមទៀត។ | | | | | |

**មតិយោបល់បន្ថែម**

………………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………………

## ផ្នែកស៊ីជំរៅលើខ្លឹមសារប្រឹក្សាអាជីព

ការណែនាំ៖ សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់បន្ទាប់មកគូសសញ្ញា✓ ទៅតាមកម្រិតនៃការយល់ស្រប របស់លោក-លោកស្រី។

កម្រិតចង្អុលបង្ហាញ៖

១.មិនយល់ស្របទាល់តែសោះ

២.មិនយល់ស្រប

៣.ពុំមានយោបល់

៤.យល់ស្រប

៥.យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | ការសិក្សាត្រូវការធ្វើផែនការពេលវេលាច្បាស់លាស់ ដើម្បីឱ្យដឹងថាពេលណាត្រូវធ្វើលំហាត់នៅផ្ទះ ចាត់ចែងមេរៀនប្រឡង។ | | | | | |
| ២ | បំណងប្រាថ្នាមិនមែនសុទ្ធតែគោលដៅនោះទេ។គោលដៅមានភាពពិតប្រាកដជាង។ | | | | | |
| ៣ | វិធីសាស្ត្ររៀនគឺជាធម្មជាតិនៃការចូលចិត្តពីរបៀបដែលយើងរៀនសូត្រនិងសិក្សា។ | | | | | |
| ៤ | តួនាទីអ្នកប្រឹក្សាជួយផ្តល់ព័ត៌មានអំពីជីវិតសេដ្ឋកិច្ច និងការងារព្រមទាំងសហគ្រិន។ | | | | | |
| ៥ | ការវាយតម្លៃបុគ្គលិកលក្ខណៈ ដើម្បីតម្រង់ទិសជំនាញ។ | | | | | |
| ៦ | មានគម្រោងច្បាស់លាស់ជួយបង្កើនឱកាសជោគជ័យ និងឈានមួយជំហានមុនអ្នកដទៃ។ | | | | | |
| ៧ | ការកំណត់គោលដៅ គឺជាការដាក់នូវផែនការដើម្បីសម្រេចបានក្នុងពេលកំណត់មួយ | | | | | |
| ៨ | គោលដៅអាចលេចជារូបភាពផ្សេងៗគោលដៅហិរញ្ញវត្ថុ គោលដៅផ្លាស់ប្តូរឥរិយាបថ គោលដៅអប់រំ គោលដៅសម្រាប់អាជីព។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | អ្វីដែលជាបញ្ហាមិនមែនទំហំសម្ពាធទេ គឺត្រង់សិស្សមើលវាក្នុងទស្សនៈបែបណា ហើយដោះស្រាយវាយ៉ាងដូចម្តេច ព្រោះសម្ពាធគឺជាផ្នែកមួយនៃជីវិត។ | | | | | |
| ១០ | ស្ត្រេសក៏អាចជារឿងល្អដែរនៅពេលដែលវាមិនមានច្រើនពេក។ បរិមាណសមស្រប នៃស្ត្រេសផ្តល់ឱ្យអ្នកនូវថាមពល និងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាព។ | | | | | |
| ១១ | ការសិក្សាទទួលបានជោគជ័យអ្នកសិក្សា ត្រូវស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយ ហើយយកបទពិសោធន៍នៃការសិក្សារបស់អ្នកដទៃ និងបទពិសោធន៍ខ្លួនឯង ជាពិសេសត្រូវយល់ពីរបៀបសិក្សា។ | | | | | |

សូមអរគុណ!

**ព្រះរាជាណាចក្រកម្ពុជា**

**ក្រសួងអប់រំ យុវជន និងកីឡា ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

# កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់សិស្សវិទ្យាល័យ នៅខេត្តបន្ទាយមានជ័យ

អ្នកគ្រូ **ឡៀប ឆវិន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្ដីពី «ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពនិងយោបល់លើសិស្សនៅវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ»ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីស្វែងយល់ពីប្រសិទ្ធិភាពនៃការអនុវត្ត និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងការបង្រៀនរបស់គ្រូប្រឹក្សាអាជីពនៅខេត្តបន្ទាយមានជ័យ។ ទិន្នន័យប្រមូលបានពីប្អូនៗ មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគឆ្លើយតបទៅប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមប្អូនៗមេត្តាជួយផ្ដល់ព័ត៌មានពិតជាក់ស្ដែង ដើម្បីឱ្យអ្នកគ្រូអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

អ្នកគ្រូ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះចំពោះការចូលរួមរបស់ប្អូនៗ។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

ការណែនាំ៖ សូមប្អូនៗ គូសសញ្ញា✓ក្នុងប្រអប់ខាងក្រោម៖

១.ថ្នាក់ ៖.................................................................................................................

២.កំពុងសិក្សានៅ៖……………………………………ឃុំ/សង្កាត់....................................................

ក្រុង/ស្រុក/ខណ្ឌ៖……………………………………ខេត្ត៖…………………………………………

៣.ភេទ ប្រុស☐ ស្រី☐

៤.អាយុ ☐ ១២-១៤ ឆ្នាំ ☐ ១៥-១៦ឆ្នាំ ☐ ១៧-១៨ឆ្នាំ ☐ លើសពី១៨ឆ្នាំ

៥.  □ បណ្តុំមុខវិជ្ជាសង្គម □បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ

៦.ភាសាបរទេស………………………………….

## ផ្នែកទី២៖ ប្រសិទ្ធភាពនៃការអនុវត្តការបង្រៀនរបស់គ្រូប្រឹក្សាអាជីព

ការណែនាំ៖ សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់បន្ទាប់មកគូសសញ្ញា✓ ទៅតាមកម្រិតនៃការយល់ស្រប របស់ប្អូនៗ។

កម្រិតចង្អុលបង្ហាញ៖

១.មិនយល់ស្របទាល់តែសោះ

២.មិនយល់ស្រប

៣.ពុំមានយោបល់

៤.យល់ស្រប

៥.យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ក.ការជួយប្រឹក្សាសិស្ស | | | | | | |
| ១ | ចេះបង្កើតបណ្តាញក្នុងការរស់នៅ និងកន្លែងសិក្សា។ | | | | | |
| ២ | ការសម្រេចចិត្តក្នុងការជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រ និងសង្គមមានភាពច្បាស់លាស់។ | | | | | |
| ៣ | បានដឹងច្បាស់ពីភាពខ្លាំង និងភាពខ្សោយរបស់ខ្លួន។ | | | | | |
| ៤ | បានទទួលការប្រឹក្សាជាបុគ្គល និងជាក្រុម។ | | | | | |
| ៥ | មានសណ្តាប់ធ្នាប់ក្នុងការរៀនសូត្រ។ | | | | | |
| ៦ | ដឹងពីវិធីសិក្សាបានច្បាស់លាស់។ | | | | | |
| ៧ | មេរៀនប្រឹក្សាជួយឱ្យការសិក្សាប្អូនទទួលលទ្ធផលល្អ។ | | | | | |
| ៨ | ប្រឹក្សាមានផែនការក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ខ្លួន។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | ចេះសរសេរកំណត់ហេតុ និងរៀបចំគោលដៅជីវិត។ | | | | | |
| ១០ | មុខវិជ្ជាប្រឹក្សាអាជីពជួយអភិវឌ្ឍការសិក្សារបស់ខ្លួន។ | | | | | |
| **ខ .ការប្រឹក្សាជួយឱ្យប្រែប្រួលបុគ្គលិកលក្ខណៈ** | | | | | | |
| ១ | មានភាពរីករាយក្នុងការរៀនសូត្រជាងមុន។ | | | | | |
| ២ | ចេះធ្វើការជាក្រុម និងជួយក្រុមបានច្រើន ចេះសហប្រតិបត្តិការគ្នា។ | | | | | |
| ៣ | មានភាពក្លាហាន និងហ៊ានសម្រេចចិត្តរឿងផ្សេងបានរហ័សជាងមុន។ | | | | | |
| ៤ | មានការវាយតម្លៃលើវឌ្ឍនភាពរបស់ខ្លួនជាប្រចាំ។ | | | | | |
| ៥ | មានការលើកទឹកចិត្តខ្លួនឯងជាប្រចាំ និងគិតវិជ្ជមាន។ | | | | | |
| ៦ | មានទំនាក់ទំនងល្អជាមួយគ្រូ គ្រួសារ និងមិត្តភក្តិ។ | | | | | |
| ៧ | រៀបចំពេលវេលាសិក្សាបានល្អ។ | | | | | |
| ៨ | ចេះរៀបចំបទបង្ហាញ និងដឹងពីរបៀបស្រាវជ្រាវ។ | | | | | |
| ៩ | ចេះសរសេរគម្រោង និងមានភាពជាសហគ្រិន។ | | | | | |
| **គ.ចំណេះដឹងនិងអាជីព** | | | | | | |
| ១ | អភិវឌ្ឍចំណុចខ្សោយរបស់ខ្លួនដោយផ្តោតលើអាជីពអនាគត។ | | | | | |
| ២ | ស្គាល់ខ្លួនឯងច្បាស់។ | | | | | |
| ៣ | ចូលរួមធ្វើការស្ម័គចិត្ត ចូលរួមសិក្ខាសាលា ឬកម្មវិធីហ្វឹកហ្វឺនផ្សេងៗ។ | | | | | |
| ៤ | ចង់ទទួលបានជំនាញ ការគិតសមហេតុផល ភាពជាអ្នកដឹកនាំ ជំនាញដោះស្រាយបញ្ហា ការធ្វើការងារជាក្រុម។ | | | | | |
| ៥ | ចេះបណ្តុះផ្នត់គំនិតណាដែលមានសារៈប្រយោជន៍សម្រាប់ខ្លួន។ | | | | | |
| ៦ | មានការពេញចិត្តចែករំលែកពីបទពិសោធន៍នៃរបៀបជោគជ័យ។ | | | | | |
| **ឃ.បញ្ហាប្រឈម** | | | | | | |
| ១ | មិនមានភាពច្បាស់លាស់នៅជម្រើសអាជីព។ | | | | | |
| ២ | ខ្វះការជំរុញពីភាគីពាក់ព័ន្ធដែលមានឥទ្ធិពលលើអាជីពរបស់សិស្ស។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | ខ្វះព័ត៌មានអប់រំ និងសេវាប្រឹក្សាអាជីពញឹកញាប់ ។ | | | | | |
| ៤ | នៅមានកម្រិតពីការស្វែងយល់ពីចំណាប់អារម្មណ៍ និងវិធីកាត់បន្ថយសម្ពាធ។ | | | | | |
| ៥ | ទទួលវគ្គបណ្តុះបណ្តាលជំនាញប្រឹក្សាបានតិចតួច។ | | | | | |
| **ង.ដំណោះស្រាយ** | | | | | | |
| ១ | ចូលរួមប្រឹក្សាឱ្យបានច្រើនជាងមុន។ | | | | | |
| ២ | បង្កើនទំនាក់ទំនងជាមួយគ្រូ និងរៀមច្បងដែលមានភាពជោគជ័យ។ | | | | | |
| ៣ | បណ្តុះផ្នត់គំនិតនិងឥរិយាបថល្អៗសម្រាប់អភិវឌ្ឍខ្លួនឯង។ | | | | | |
| ៤ | ដាក់ចិត្តរៀន ដើម្បីសម្រេចគោលដៅណាមួយនិងមានជំនឿជាក់លើខ្លួន។ | | | | | |
| ៥ | ចេះស្វែងរកព័ត៌មានអប់រំបានត្រឹមត្រូវ។ | | | | | |
| ៦ | ពង្រឹងការចូលរួមគ្រប់ភាគីពាក់ព័ន្ធដែលជះឥទ្ធិពលលើជម្រើសអាជីព។ | | | | | |
| **ច.ការពិនិត្យតាមដានលទ្ធផល** | | | | | | |
| ១ | ទទួលបានពិន្ទុល្អស្មើរគ្រប់មុខវិជ្ជា។ | | | | | |
| ២ | បានវាយតម្លៃជាប្រចាំលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់ខ្លួន។ | | | | | |
| ៣ | ចេះក្តាប់ឱកាសជាងមុន។ | | | | | |
| ៤ | បានចូលរួមវគ្គតម្រង់ទិសអាជីព២ឬ៣ដងក្នុង១ឆ្នាំ។ | | | | | |
| ៥ | ចេះគ្រប់គ្រងសម្ពាធ និងរកវិធីដោះស្រាយ។ | | | | | |
| ៦ | ធ្វើការងារមានប្រយោជន៍ច្រើន។ | | | | | |
| ៧ | កំណត់ពីជម្រើសអាជីពទៅអនាគត។ | | | | | |

**មតិយោបល់បន្ថែម**

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

## ផ្នែកស៊ើបអង្កេតលើខ្លឹមសារប្រឹក្សាអាជីព

ការណែនាំ៖ សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់បន្ទាប់មកគូសសញ្ញា✓ ទៅតាមកម្រិតនៃការយល់ស្រប របស់ប្អូនៗ។

កម្រិតចង្អុលបង្ហាញ៖

១.មិនយល់ស្របទាល់តែសោះ

២.មិនយល់ស្រប

៣.ពុំមានយោបល់

៤.យល់ស្រប

៥.យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | ការសិក្សាត្រូវការធ្វើផែនការពេលវេលាច្បាស់លាស់ ដើម្បីឱ្យដឹងថាពេលណាត្រូវធ្វើលំហាត់នៅផ្ទះ ចាត់ចែងមេរៀនប្រឡង។ | | | | | |
| ២ | បំណងប្រាថ្នាមិនមែនសុទ្ធតែគោលដៅនោះទេ។ គោលដៅមានភាពពិតប្រាកដជាង។ | | | | | |
| ៣ | វិធីសាស្ត្ររៀនគឺជាធម្មជាតិនៃការចូលចិត្តពីរបៀបដែលយើងរៀនសូត្រនិងសិក្សា។ | | | | | |
| ៤ | ជ្រើសរើសអាជីពត្រូវមើលលើគុណតម្លៃ ចំណង់ចំណូលចិត្ត ជំនាញនិងបទពិសោធន៍ | | | | | |
| ៥ | ការវាយតម្លៃបុគ្គលិកលក្ខណៈ ដើម្បីតម្រង់ទិសជំនាញ។ | | | | | |
| ៦ | មានគម្រោងច្បាស់លាស់ជួយបង្កើនឱកាសជោគជ័យ និងឈានមួយជំហានមុនអ្នកដទៃ។ | | | | | |
| ៧ | ការកំណត់គោលដៅ គឺជាការដាក់នូវផែនការ ដើម្បីសម្រេចបានក្នុងពេលកំណត់មួយ | | | | | |
| ៨ | គោលដៅអាចលេចជារូបភាពផ្សេងៗគោលដៅហិរញ្ញវត្ថុ គោលដៅផ្លាស់ប្តូរឥរិយាបថ គោលដៅអប់រំ គោលដៅសម្រាប់អាជីព។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | អ្វីដែលជាបញ្ហាមិនមែនទំហំសម្ពាធទេគឺត្រង់សិស្សមើលវាក្នុងទស្សនៈបែបណា ហើយដោះស្រាយវាយ៉ាងដូចម្តេច ព្រោះសម្ពាធគឺជាផ្នែកមួយនៃជីវិត។ | | | | | |
| ១០ | ស្ត្រេសក៏អាចជារឿងល្អដែរនៅពេលដែលវាមិនមានច្រើនពេក។ បរិមាណសមស្របនៃស្ត្រេសផ្តល់ឱ្យអ្នកនូវថាមពល និងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាព។ | | | | | |
| ១១ | ការសិក្សាទទួលបានជោគជ័យអ្នកសិក្សាត្រូវស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយហើយយកបទពិសោធន៍នៃការសិក្សារបស់អ្នកដទៃ និងបទពិសោធន៍ខ្លួនឯងជាពិសេសត្រូវយល់ពីរបៀបសិក្សា។ | | | | | |

សូមអរគុណ!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ: ១៧៨ វជអ.**

**គោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ**

**កម្មវត្ថុ៖** សម្រួលដល់ការស្រាវជ្រាវរបស់និស្សិតឈ្មោះ **ទៀប ផនៃ** នៅវិទ្យាល័យ និងមហាវិទ្យាល័យ នៅខេត្តបន្ទាយមានជ័យ។

**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថា កញ្ញា ទៀប ផនៃ ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំ មានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្តីពី"**ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គ្រូប្រឹក្សាអាជីពនិងយោបល់លើសិស្សនៅមធ្យមសិក្សាទុតិយភូមិ**"ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។ កញ្ញា **ទៀប ផនៃ** នឹងសម្ភាសន៍តាមប្រព័ន្ធ ONLINE ដល់នាយក គ្រូបង្រៀន និស្សិតមហាវិទ្យាល័យ និងសិស្សានុសិស្សដែលកំពុងសិក្សានៅវិទ្យាល័យ និងមហាវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ។ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ **២០២០**។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។
សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

17.07-20

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :......./......ខជអ.

### បំណែងចែកគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ
### ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧
### ដែលប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០
### នៅវិទ្យាស្ថានជាតិអប់រំ

**គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ**

| **ក្រុមទី១** | | **ក្រុទី២** | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | ១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម |
| ២- ឯកឧត្តម | នៀ សុផន | ២-លោកបណ្ឌិត | នូវ វ៉ា |
| ៣-លោក | ឌី បុណ្ណា | ៣-លោកស្រី | ប៊ុន សុផានី |
| ៤-លោក | ថៃ ហេង | ៤-លោក | ចាប រតនា |
| ៥-លោក | ម៉ន មុនិន្ទ | ៥-លោកបណ្ឌិត | អាន វ៉ូប្រាវ |
| ៦-លោកបណ្ឌិត | នី រដ្ឋា | ៦-លោកស្រី | នូ ចន្ទី |
| ៧-លោកបណ្ឌិត | ឈាង សង្វាត | ៧-លោក | សៀង វិសនា |

**គណៈកម្មការកណ្តាល និងរៀបចំ**

| **ក្រុមទី១** | | **ក្រុមទី២** | |
|---|---|---|---|
| ៨-លោក | លឹម វ៉ាន់ | ៨-លោក | ឡេង បុរី |
| ៩-លោក | លន លីណា | ៩-លោកស្រី | ហង់ ស្រីម៉ាច |
| ១០-លោក | ឡុច ចាន់ថន | ១០-លោក | ហ៊ីង សារៈបុត្រ |
| ១១-លោកស្រី | ទ្រី វីណា | ១១-លោក | ម៉ែន សុខសុន្ទី |

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០
នាយកវិទ្យាស្ថានជាតិអប់រំ

បណ្ឌិត.សៀង សុវណ្ណា

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៨ គេហទំព័រ៖ www.nie.edu.kh